## សាកលវិទ្យាល័យភូមិន្ទ
## នីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

## សារណាបញ្ចប់ការសិក្សា

# មតកសាសន៍

ស្រាវជ្រាវពីថ្ងៃ០១ ខែមេសា ឆ្នាំ២០១៥ ដល់ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៥


តាក់តែងឡើងដោយ

និស្សិតឈ្មោះ **ហ៊ីង គីមឡេង**

**ទេព សុខ**

សាស្ត្រាចារ្យណែនាំ

លោក **រុន ពណ្ណារិទ្ធិ**


ថ្នាក់បរិញ្ញាបត្រ *នីតិសាស្ត្រ*

ជំនាន់ទី១៥

ឆ្នាំចូលរៀន ២០១១

ឆ្នាំសរសេរណា ២០១៥

# សេចក្ដីថ្លែងអំណរគុណ

.............

យើងខ្ញុំ ឈ្មោះ **ហ៊ីង គីមឡេង និង ទេព សុខ** ជានិស្សិតជានិស្សិតបរិញ្ញាបត្រ ឆ្នាំទី៤ ជំនាន់ទី១៥ នៃសាកលវិទ្យាល័យភូមិន្ទនិតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច។

## សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពុតជូន

លោកមានគុណទាំងពីរ ដែលបានផ្ដល់កំណើត និង ចិញ្ចឹមបីបាច់ថែរក្សាយើងខ្ញុំ ព្រមទាំងឧបត្ថមគ្រប់បែបយ៉ាង ទាំងសម្ភារៈនិងស្មារតី ជាពិសេសលោកទាំងពីរបានលើកទឹកចិត្តកូន ឲ្យចេះតស៊ូក្នុងការសិក្សារៀនសូត្រ ទើបពួកកូន មានថ្ងៃនេះ ជាថ្ងៃដែលកូនៗមានកិត្តិយស និង មានមោទនភាពបំផុត ដែលកូនបានសិក្សាទទួលបានពិន្ទុល្អ ហើយត្រូវបានសាលា អនុញ្ញាតឲ្យ ពួកយើងខ្ញុំ បានសរសេរសារណា បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ និង បានការពារនូវស្នាដៃដែលពួក កូនបានធ្វើការស្រាវជ្រាវ ផ្នែក នីតិសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលទទួលបានលទ្ធផលប្រកបដោយជោជ័យជាស្ថាពរ។

យើងខ្ញុំក៏សូមថ្លែងអំណរគុណផងដែរចំពោះ លោក លោកស្រីសាស្ត្រាចារ្យទាំងអស់ លើគ្រប់មុខវិជ្ជាចាប់ពីឆ្នាំទី១ ដល់ ឆ្នាំទី៤ ដែលពួកគាត់តែងតែចំណាយអស់នូវកំលាំងកាយ ចិត្ត ស្មារតី និង បញ្ចេញអស់នូវ ចំណេះដឹង បទពិសោធន៍ និង ទេពកោសល្យគ្រប់បែបយ៉ាង ដើម្បីឲ្យនិស្សិតបានចេះដឹង ប្រកបដោយកិត្តិយសថ្លៃថ្នូរ ។

ជាងនេះទៀតយើងខ្ញុំក៏សូមថ្លេងអំណរគុណ ចំពោះឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ប្រធានការិយាល័យ និង បុគ្គលិកមន្ត្រីរាជការទាំងអស់ ដែលលោក អ្នកទាំងបានខិតខំ បំពេញភារកិច្ច និង បានផ្ដល់សេវាដ៏ល្អ ដែលជាឱកាសដ៏ប្រពៃដើម្បីឲ្យយើងខ្ញុំ អាចសម្រេចនូវគោលដៅក្នុងការសិក្សានៅទីនេះប្រកបដោយលក្ខណៈងាយស្រួល។

ជាពិសេសយើងខ្ញុំសូមថ្លែង អំណរគុណ យ៉ាងជ្រាលជ្រៅបំផុត ចំពោះលោកសាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** ដែលលោកបានចំណាយអស់នូវកំលាំងកាយ កំលាំងចិត្ត ប្រាជ្ញាស្មារតី និង វិៈរកវិធីសាស្ត្របង្រៀនល្អៗ ងាយយល់ ប្រកបដោយទេពកោសល្យក្នុងការបង្រៀនដល់និស្សិត ដែលនាំពួកគេទទួលបាននូវ ចំណេះដឹងមួយពិតប្រាកដ ដែលធនធានមនុស្សពិតៗ ដើម្បីកសាងប្រទេសជាតិ និង អភិវឌ្ឍខ្លួននាពេលអនាគត។

ជាទីបញ្ចប់យើងខ្ញុំសូមប្រសិទ្ធិពរជ័យ ដល់ឯកឧត្តម លោក-លោកស្រី សាស្ត្រាចារ្យ និង អ្នកមានគុណទាំងអស់ជួបប្រទះនូវពុទ្ធពរ បួនប្រការ គឺ វណ្ណ: សុខ: ពល: និង បដិភាណ:កុំបីឃ្លាតឃ្លាឡើយ។

......................................

# អារម្ភកថា

ការលើកយក ប្រធានបទស្តីពី **មតកសាសន៍** មកធ្វើការស្រាវជ្រាវ ក្នុងបំណងពង្រីកចំណេះដឹងផ្នែកនេះឲ្យកាន់តែស៊ីជម្រៅ ពីព្រោះ បញ្ហាបច្ចុប្បន្នភាព នៅក្នុងជីវភាពជាក់ស្តែងគឺបញ្ហា វិវាទឈ្លោះប្រកែកគ្នា តែពីរឿងមតិក ដែលបន្សល់មតកជន បានធ្វើបណ្តាំមតកសាសន៍ទុកឲ្យសន្តតិជនរបស់អ្នកស្លាប់។ មតកសាសន៍ ជាការបង្ហាញឆន្ទៈឯកតោភាគី ដោយពុំមានភាគីម្ខាងទៀត ដែលធ្វើឡើងដោយម្ចាស់បណ្តាំពាក់ព័ន្ធនឹងចំណុចពិសេសស្តីពីទំនាក់ទំនង ទ្រព្យសម្បត្តិរបស់ជននោះ ឬស្តីពីទំនាក់ទំនងឋានៈបុគ្គល ក្នុងគោលបំណងបង្កើតអានុភាព។ មនុស្សយើងអាច អាចចាត់ចែងដោយសេរី នូវទ្រព្យសម្បត្តិរបស់ខ្លួនបាន តាមរយៈមតកសាសន៍។

ប្រធានបទនេះ បានចូលរួមពង្រីក និង អភិវឌ្ឍ ចំណេះដឹង លើផ្នែកមតកសាន៍ប្រកបដោយភាពច្បាស់លាស់ ដោយមានការពន្យល់យ៉ាងលំអិ្អត និតិវិធី ខ្លឹមសារ អានុភាព លក្ខខណ្ឌចាំបាច់ក្នុងការបង្កើត មតកសាសន៍ជាដើម។ ប្រធានបទនេះ មានបំណាង ចូលរួមជួយឲ្យនិស្សិត ដែល សិក្សាផ្នែកច្បាប់ក្នុងមហាវិទ្យាល័យច្បាប់ និង និស្សិតផ្នែក ផ្សេងទៀតរួមទាំង ប្រជាពលរដ្ឋទូទៅងាយ យល់ និង ងាយយកមកអនុវត្ត ក្នុងជីវភាពប្រចាំថ្ងៃ។ ម្យ៉ាងទៀត ដើម្បីចូលរួមក្នុងការកសាងនីតិរដ្ឋ នៅកម្ពុជា បើកាលណាប្រជាពលរដ្ឋបានយល់ដឹងផ្នែកច្បាប់នេះបានជ្រួតជ្រាបល្អ នោះប្រទេសជាតិ កាត់បន្ថយនូវជម្លោះដណ្តើមទ្រព្យ នាំឲ្យពួកគាត់ចេះរស់នៅប្រកបដោយសុខដុមរម្យនា ជាមួយគ្នាក្នុងសង្គម។

ជាងនេះទៀតប្រធានបទនេះ មានគោលបំណង ឲ្យប្រជាពលមានសីលធម៌ គោរពគ្នាទៅវិញទៅមក។ ជាពិសេសជាងនេះទៀតនោះគឺ ចង់ឲ្យកូនៗ ឬសាច់ញាតិដែលនៅរស់ចេះគោរពវិញ្ញាណខ័ន្ធ អ្នកដែលធ្វើបណ្តាំមតកសាសន៍ ដែលកាលគាត់នៅរស់គាត់បានចំណាយអស់នូវ កម្លាំងកាយ កម្លាំងចិត្ត ប្រាជ្ញា ស្មារតី ដើម្បីរកទ្រព្យសម្បត្តិ ទុកសម្រាប់កសាង និង អភិវឌ្ឍ គ្រួសារ លុះគាត់មរណភាពទៅបែរជាកូនៗ ឬ សាច់ញាតិឈ្លោះដណ្តើមទ្រព្យគ្នាទៅវិញ។ តើវិញ្ញាណខ័ន្ធ បានសុខអត់? តើការខិតខំរកទ្រព្យសម្បត្តិ និង បន្សល់ទុកនូវទ្រព្យឲ្យសន្តតិជន វាជាកំហុស ឲ្យពួកគេបែកបាក់សាមគ្គី លែងស្គាល់បង ប្អូន ឪពុក ម្តាយ ឬយ៉ាងណា?

# មាតិកា

**សេចក្តីផ្តើម** ........ **១**

**ជំពូកទី១៖ លក្ខខណ្ឌចាំបាច់នៃការបង្កើតមតកសាសន៍** ........ ៦

**ផ្នែកទី១៖ លក្ខខណ្ឌចាំបាច់ជាគ្រឹះនៃការបង្កើត** ........ **៩**

**កថាខណ្ឌទី១៖ ភាពពិតប្រាកដនៃឆន្ទជាលក្ខខណ្ឌគ្រឹះតែមួយគត់នៃមតកសាសន៍** ........ ៩

ក. ការជៀសផុតអំពីវិការៈនៃឆន្ទៈ ........ ១០

ខ. សមត្ថភាពគ្រប់គ្រាន់នៃមតកជន ........ ១១

**កថាខណ្ឌទី២៖ អប្រសិទ្ធិភាពនៃឆន្ទៈរបស់មតកជន** ........ ១២

ក. ការផ្លាស់ប្តូរឆន្ទៈ នៃមតកជន ........ ១៣

ខ. ការបដិសេធនៃអត្តគាហក ........ ១៥

គ.ការបាត់បង់ទ្រព្យ ឬមរណភាពនៃអត្តគាហក ........ ១៦

**ផ្នែកទី២៖ លក្ខខណ្ឌចាំបាច់ជាទម្រង់នៃការបង្កើត** ........ **១៩**

**កថាខណ្ឌទី១៖ទម្រង់នៃមតកសាសន៍ក្នុងស្ថានភាពធម្មតា** ........ ២០

ក.មតកសាសន៍ដោយលិខិតយថាភូត ........ ២០

ខ.មតកសាសន៍ដោយលិខិតឯកជន ........ ២២

គ. មតកសាសន៍ដោយលិខិតសម្ងាត់ ........ ២៣

**កថាខណ្ឌទី២៖ ទម្រង់នៃមតកសាសន៍ក្នុងស្ថានភាពពិសេស** ........ ២៤

ក. មតកសាសន៍នៃជនដែលកំពុងជួបគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត ........ ២៥

ខ.មតកសាសន៍នៃជនដែលត្រូវជាប់ឃុំឃាំងឬដែលនៅក្នុងនាវា ឬយន្តហោះ ........ ២៥

គ. មតកសាសន៍នៃជនដែលមិនអាចនិយាយស្តីបាន ........ ២៦

ឃ. មតកសាសន៍នៃជនជាតិខ្មែរដែលរស់នៅបរទេស ........ ២៦

**ជំពូកទី២៖ ខ្លឹមសារសំខាន់នៃមតកសាសន៍** ........ **២៨**

**ផ្នែកទី១៖ ខ្លឹមសារជាវិជ្ជមាននៃមតកសាសន៍** ........ **៣១**

**កថាខណ្ឌទី១៖ ការបង្កើតសិទ្ធិលើមត៌កដល់អត្តគាហក** ........ ៣១

ក.តាមរបបសន្តតិកម្ម ........ ៣២

ខ. តាមរបបអច្ច័យទាន ........ ៣៣

**កថាខណ្ឌទី២៖ ការបង្កើតសិទ្ធិចាត់ចែងមត៌កដល់អ្នកប្រតិបត្តិមតកសាសន៍** ................ ៣៥
ក. ការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍........................................................ ៣៦
ខ. សិទ្ធិអំណាចនៃអ្នកប្រតិបត្តិមតកសាសន៍ ..................................................... ៣៧
**ផ្នែកទី២៖ ខ្លឹមសារជារអវិជ្ជមាននៃមតកសាសន៍ ............................................ ៣៩**
**កថាខណ្ឌទី១៖ ការផ្ដាច់មត៌កពីសន្តតិជនដែលច្បាប់ទទួលស្គាល់សិទ្ធិ** ......................... ៣៩
ក.ការផ្ដាច់មត៌កដោយផ្ទាល់ពីសន្តតិជន.............................................................. ៣៩
ខ. ការផ្ដាច់មត៌កដោយប្រយោលពីសន្តតិជន ....................................................... ៤០
**កថាខណ្ឌទី២៖ សិទ្ធិលើភាគបម្រុងនៃសន្តតិជនជាដែនកម្រិតនៃការផ្ដាច់មត៌ក** ............. ៤៣
**សេចក្ដីសន្និដ្ឋាន**................................................................................................... ៤៧
ឯកសារពិគ្រោះ និងយោង ...................................................................................... ៤៩
ឧបសម្ព័ន្ធ (ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ពីមាត្រា ១១៦៨ ដល់ ១២២៩)................................. ៥០

# សេចក្តីផ្តើម

# សេចក្តីផ្តើម

តាមគោលការណ៍ច្បាប់ បុគ្គលម្នាក់ៗមានបេតិកភណ្ឌតែមួយគត់។ ហើយ បេតិកភណ្ឌនៃបុគ្គលម្នាក់ៗនឹងត្រូវ រលត់ទៅ ដោយការផ្ទេរបន្តទៅក្នុង បេតិកភណ្ឌ នៃម្នាក់ទៀត ចាប់ពីពេលដែលបុគ្គលនោះបានស្លាប់។ ការផ្ទេរនេះហៅថា សន្តតិកម្ម។ ជា ទូទៅ បើសន្តតិកម្មដំណើរការ ដោយ សន្តិភាពរវាងអ្នកស្នងបន្តទាំងឡាយ នោះនឹងពុំចោទជាបញ្ហាអ្វី ឡើយ។ ប៉ុន្តែបើការបែងចែក បេតិកភណ្ឌទាំងនោះពុំមានការស្រុះស្រួលគ្នាទេ សន្តតិកម្មនឹងក្លាយជាប្រភពនៃវិវាទ នាពេលក្រោយមរណភាពនៃម្ចាស់បេតិកភណ្ឌ ហើយ វិវាទ នេះនឹងរឹតតែស្រួចស្រាវថែមទៀត រវាងសាច់ញាតិ លោហិត និង ឬអ្នកជិតស្និទនឹងខ្មោច កាលបើចំនួនទ្រព្យដែលបន្សល់ទុកនោះ រឹតតែច្រើនឡើងនោះ។ ហេតុនេះ ដើម្បីបញ្ចៀសនូវវិវាទទាំងនោះផង និងដើម្បីបំពេញចិត្តម្ចាស់ទ្រព្យ ដែលចង់បែងចែកទ្រព្យ ចុងក្រោយ របស់ ខ្លួនក្រោយពេលស្លាប់តាម ឆន្ទៈរបស់ខ្លួនផង ទើបវត្តមាននៃលិខិតបណ្តាំ របស់ម្ចាស់ បេតិកភណ្ឌដែលធ្វើទុកមុននាពេលនៅរស់ បានលេចឡើង ហើយនឹងត្រូវបានទទួលស្គាល់។ ដោយ សារជាតិទាក់ទងនឹងទ្រព្យហើយម្ចាស់នៃទ្រព្យបានចែកឋាន ទៅហើយ ដូចនេះ ទាំងមានបណ្តាំ ទាំងឥតបណ្តាំ សន្តតិកម្មតែងបង្កើតឲ្យមានវិវាទជាញឹកញាប់។ គិតដល់ ចំណុចនេះ ហើយ ជាហេតុនាំ ឲ្យច្បាប់នៃប្រទេសណាក៏ដោយ រមែងចូលអន្តរាគមន៍ ក្នុង វិស័យនេះជានិច្ចដែរ។

ក្នុងន័យច្បាប់ សន្តតិកម្ម គឺជាប្រតិបត្តិការគតិយុត្តិមួយសំដៅដល់ ការផ្ទេរនូវសិទ្ធិ និងករណីយកិច្ចរបស់បុគ្គល ដែលស្លាប់ (មតកជន) ទៅឲ្យបុគ្គលម្នាក់ ឬច្រើន នាក់ដែលនៅរស់ ដើម្បី ទទួលបន្តតាមយន្តការនៃច្បាប់ (ព្រោះឥត មានបណ្តាំ) ឬនៃឆន្ទៈ របស់មតកជននោះ (កាលបើ មានបណ្តាំ)។ និយាយឲ្យពិតទៅច្បាប់ស្តីពីសន្តតិកម្មនៅកម្ពុជា ពុំមែនជាសញ្ញាណមួយថ្មី សម្រាប់កម្ពុជា នោះឡើយ។ ជាក់ស្តែងដូចជា បទបញ្ញត្តិ នៅក្នុងក្រមរដ្ឋប្បវេណីខ្មែរឆ្នាំ១៩៦៧ ត្រង់គន្លីទី១ ជំពូកទី៤ ស្តីពីសន្តតិកម្មបណ្តាំ និង ជំពូកទី៥ស្តីពីការកាន់យកនូវមត៌តក ហើយដែលមាត្រា ៥២៣ ចែងថា៖ " បណ្តាំ ឬ មតកសាសន៍ គឺសេចក្តីដែលមនុស្សម្នាក់ហៅថាម្ចាស់បណ្តាំ សំដែងនូវឆន្ទៈ ណា មួយរបស់ខ្លួន ដើម្បីឲ្យគេយកទៅប្រតិបត្តិ ក្រោយពេលដែលខ្លួនស្លាប់ទៅ"។ ដោយឡែក ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៨៩ ហាក់បានបំភ្លេចទាំងស្រុង ដោយមិនបានចែង នៅក្នុងមាត្រាណាមួយរបស់ខ្លួន អំពីសន្តតិកម្មនេះឡើយ។ លុះរហូតដល់ឆ្នាំ១៩៩២ ទើបយើងឃើញមានវត្តមាននៃបទបញ្ញត្តិទាក់ទងនឹងសន្តតិកម្មនេះ នៅក្នុងអតីតច្បាប់ភូមិបាល របស់ខ្មែរ ពោលគឺចាប់ពីមាត្រា១៧០ ដល់ មាត្រា១៧៦។ បន្តមកទៀត ច្បាប់ភូមិបាលថ្មី ឆ្នាំ២០០១ និង ជានីតិវិជ្ជមាន សព្វថ្ងៃបានបញ្ញត្តិអំពី សន្តតិកម្មនេះផងដែរ ប៉ុន្តែគ្រាន់តែ សន្តតិកម្មនេះ មានឧបនិស្ស័យ អនុវត្តចំពោះតែអចលវត្ថុ ប៉ុណ្ណោះ ពីព្រោះវិធាននេះ

ជាវិធាន ដោយឡែកនៃអចលនវត្ថុ។ ដូចនេះ យើងឃើញថា បទបញ្ញត្តិរបស់ខ្មែរ ដែលទាក់ទង នឹង សន្តតិកម្ម ហាក់មានភាពខ្វះចន្លោះច្រើន ហើយក៏ហាក់មិនបានបញ្ជាក់ឲ្យបានច្បាស់ លាស់នូវ លក្ខខណ្ឌ ក៏ដូចជានីតិ វិធីក្នុងការអនុវត្តន៍ សន្តតិកម្មនោះទេ។ ការណ៍នេះ ជាហេតុ ធ្វើឲ្យអ្នក ច្បាប់ដូចជា ចៅក្រម ឬមេធាវីជាដើមនោះ ពិបាក នឹងយកវិធាននេះ ទៅអនុវត្តណាស់ ពិសេសកាលបើ ប្រជាពលរដ្ឋ ទូទៅច្រើន ប្រើប្រពៃណី ច្រើនជាង ការអនុវត្តវិធាន ច្បាប់។ ជាវិបាកគេសង្កេតឃើញថា នៅពេលមានសំណុំ រឿងដែលទាក់ទង នឹង សន្តតិកម្មម្តងៗ ចៅក្រម ឬ មេធាវី តែងតែយកវិធានចាស់ ដែលមានចែង ដើម្បី ដោះស្រាយវិវាទ លើមតិកនេះ ឬផ្អែកលើទម្លាប់ជាធំប៉ុណ្ណោះ។ ក្នុងករណីនេះ តើ នីតិរដ្ឋនៅឯណា?

ដោយមើលឃើញពីភាពខ្វះខាត និងតម្រូវការយ៉ាងចាំបាច់នៃវិធាន ដែលគ្រប់ គ្រងលើ វិស័យដ៏សំខាន់នេះហើយ ទើបអ្នកតាក់តែងច្បាប់ខ្មែរ បានខិតខំប្រឹងប្រែង រៀបចំ និង តាក់តែងរហូត សម្រេចបាននូវក្រមរដ្ឋប្បវេណីថ្មីមួយ។ ក្រមនេះ បានក្លាយជា មូលដ្ឋាន គ្រឹះគតិយុត្តិយ៉ាងសំខាន់ ក្នុង ការផ្តល់នូវវិធានដែលគ្រប់គ្រងនូវសន្តតិកម្មនេះ។ ក្រមរដ្ឋប្បវេណីថ្មីចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០០៧ ហើយ នឹងក្លាយជាអនាគតវិធានធរមាន នាពេលឆាប់ៗខាងមុខនេះ[1] បានបញ្ញត្តិអំពីវិធាន ស្តីពី សន្តតិកម្មនេះ នៅត្រង់គន្ថីទី៨ ផងដែរ។

អនុលោមតាមក្រមរដ្ឋប្បវេណីថ្មីនេះ សន្តតិកម្មអាចដើរតាម យន្តការពីរយ៉ាងគឺ សន្តតិកម្ម ឥតបណ្តាំ និងសន្តតិ កម្មមានបណ្តាំ។ សន្តតិកម្មឥតបណ្តាំ ឬអាចហៅថា ជាសន្តតិកម្ម តាមច្បាប់ ពោល គឺជាសន្តតិកម្មដែលត្រូវអនុវត្តទៅ តាមបទបញ្ញត្តិនៃច្បាប់ ក្នុងការបែង ចែកនូវទ្រព្យ ដែលនៅសេសសល់ ពីអ្នកស្លាប់ ទៅឲ្យទាយាទ របស់អ្នកស្លាប់ នោះ ជំនួសឲ្យឆន្ទៈនៃអ្នកស្លាប់ ដោយហេតុថា អ្នកស្លាប់នោះ មិនបានសម្តែងឆន្ទៈ របស់ខ្លួនសំដៅបែងចែង មតិកនេះនាពេលខ្លួនស្លាប់ទេ។ ក្នុងន័យនេះរបបនៃ សន្តតិកម្មតាម ច្បាប់ត្រូវយកមកអនុវត្តតែក្នុង ល័ក្ខខ័ណ្ឌដែលសន្តតិជន ន័យអ្នកស្លាប់ ពុំមានការព្រម ព្រៀងគ្នាលើការបែងចែកនេះប៉ុណ្ណោះ។

ផ្ទុយទៅវិញ សន្តតិកម្មមានបណ្តាំ គឺជាសន្តតិកម្មដែលធ្វើឡើងស្រប ទៅតាម បណ្តាំ របស់អ្នកស្លាប់ (មតកជន)ក្នុងការបែងចែកនូវមតិករបស់ខ្លួនទៅឲ្យទាយាទ ឬ តតិជនណាមួយ។ សន្តតិ កម្មនេះ អាចហៅម្យ៉ាងទៀតបានថា " មតកសាសន៍" នេះឯង។ មតកសាសន៍ គឺជាលិខិត បណ្តាំ ដែល

[1] ក្រមថ្មីនេះបានអនុម័ត ថ្ងៃទី៨ ខែ ធ្នូ ឆ្នាំ ២០០៧ ត្រូវបានប្រកាសឲ្យប្រើក៏ដោយ ក៏បញ្ញត្តិនៃក្រមនេះ មិនទាន់បានអនុវត្ត នៅឡើយទេ ដោយរងចាំនូវច្បាប់ស្តីពីការអនុវត្តន៍ក្រមរដ្ឋប្បវេណី ដែលជាច្បាប់មួយដើម្បីធ្វើការសម្របសម្រួល ជាមួយបទ ប្បញ្ញត្តិច្បាប់ និង បទដ្ឋានគតិយុត្តធរមាន នានា ឲ្យមានភាពស៊ីសង្វាក់នឹងគ្នាក្នុងការអនុវត្ត។ ជាលទ្ធផលច្បាប់ស្តីពីការអនុវត្ត ក្រមរដ្ឋប្បវេណីក៏ត្រូវបានរដ្ឋសភាអនុម័ត្រពីថ្ងៃទី ៦ ខែ មេសា ឆ្នាំ ២០១១ នាសម័យប្រជុំពេញអង្គលើកទី៩ នីតិកាលទី២ និង ប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/០៥១១/00៧ ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១១។

តាមនោះបុគ្គលម្នាក់បានធ្វើ ឡើងតាមទម្រង់ ដែលកំណត់ដោយច្បាប់ ក្នុងការសម្តែងឆន្ទៈចុងក្រោយអំពីការចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួន ជាអាទិ៍ បន្ទាប់ពីមរណភាពរបស់គាត់[2]។ ដូចនេះ វាគឺជាបណ្តាំ នៃការចាត់ ចែងទុកមុន។ និយមន័យនេះ ហាក់ដូចគ្នាទៅនឹងនិយមន័យដែល ផ្តល់ឲ្យដោយ ក្រម រដ្ឋប្បវេណីសង្គមចាស់បេះបិទ។

ម្យ៉ាងវិញទៀត មតកសាសន៍នវ ក៏ពុំគួរត្រូវបានភាន់ច្រឡំ ជាមួយនឹងសញ្ញាណ នៃប្រទានកម្មដោយមូលហេតុ មរណភាពនោះទេ។បើយោងទៅលើ និយមន័យ ដែលបានបង្ហាញខាងលើ យើងអាចធ្វើការបែងចែកអោយដាច់ពីគ្នា រវាងមតកសាសន៍នេះ និង ប្រទានកម្ម ដោយមូលហេតុ មរណភាពបាន។ ក្នុងន័យនេះ ប្រទានកម្មដោយមូលហេតុមរណភាពនេះ គឺជាកិច្ចសន្យា សំដៅធ្វើអំណោយ (ធ្វើទាន) ហើយដែល នឹងអាច បង្កើតអានុភាព លុះណាតែមានមរណភាពរបស់ទាយក (អ្នកធ្វើទាន)[3]។ ដូចនេះ យើងអាច កំណត់ថា សញ្ញាណទាំងពីរនេះ សុទ្ធតែបង្កើតអានុភាពគតិយុត្តរបស់ វាបានតែនាពេល មរណភាពរបស់ម្ចាស់ទ្រព្យដូចគ្នា។ ប៉ុន្តែចំណុចដែល សំខាន់ក្នុងការបែងចែកសញ្ញាណទាំងពីរនេះ ឲ្យដាច់ស្រឡះពីគ្នាបាន គឺត្រង់សារជាតិផ្ទាល់ នៃកិច្ចគតិយុត្តតែម្តង។ មានន័យថា តាមសារជាតិ ប្រទានកម្មដែល បង្កើតអានុភាព ដោយ មរណភាពនេះ គឺជាកិច្ចសន្យា ដែលកើតឡើងបាន លុះណាតែមាន ការសម្តែងឆន្ទៈព្រមព្រៀងគ្នា រវាងទាយក(អ្នកធ្វើទាន) និងអគ្គាហក (អ្នកទទួលទាន)ហើយអានុភាពរបស់វានឹងកើត ចាប់ពីថ្ងៃ មរណភាព នៃទាយកនោះ។ ដូច្នេះ ការណ៍ដែលទាយកគ្រាន់ តែសម្រេចថា ប្រគល់ទ្រព្យរបស់ខ្លួន ឲ្យទៅបុគ្គលណាម្នាក់ ក្រោយ\មរណកាលរបស់ខ្លួន ពុំអាចនឹងនាំឲ្យមាន ការផ្ទេរទ្រព្យពីបេតិកភណ្ឌរបស់គាត់ ទៅបេតិកភណ្ឌនៃបុគ្គលម្នាក់នោះបានទេ តែត្រូវរង់ចាំទាល់តែ បុគ្គលម្នាក់នោះ យល់ព្រមថែមទៀតទើបបាន។ ហើយបើការយល់ព្រមនេះ កើតមានឡើងក្រោយមរណភាពនៃទាយកនោះ វាក៏នឹងពុំអាចមានអានុភាពអ្វីបានដែរ ព្រោះឆន្ទៈនឹង ពុំអាចជួបគ្នាទាល់តែសោះ។ រីឯមតកសាសន៍វិញ គឺជាកិច្ចគតិយុត្តឯកតោភាគីដែល កើតចេញពីឆន្ទៈនៃមតកជន (អាចប្រដូចនឹងទាយកក្នុងន័យនៃប្រ ទានកម្ម) តែម្ខាងប៉ុណ្ណោះ ប៉ុន្តែអានុភាពរបស់វានេះ ពោលគឺការផ្ទេរព្រទ្យចូលទៅក្នុងបេតកភណ្ឌនៃអ្នកដែលត្រូវទទួល(អគ្គាហក) នឹងចាប់មាន ពីពេលដែលមតកជន នោះស្លាប់ទៅ ដោយមិនខ្វល់ពីឆន្ទៈយល់ព្រម ឬមិនយល់ព្រម នៃអ្នកទទួលនោះទេ។ សំណួរអាចចោទ ឡើងថា ចុះបើនៅក្រោយមរណភាព អ្នកដែលត្រូវទទួលនោះបដិសេធ តើមតកសាសន៍នេះ អាចបង្កើតអានុភាពម្តេចបានទៅ? ការពិតឆន្ទៈព្រមព្រៀងពីអ្នកដែលត្រូវទទួល ក្រោយមរណ ភាពនៃមតកជន មិនបានកែប្រែ

[2] សូមអាន សន្ទានុក្រមផ្នែករដ្ឋប្បវេណីថ្មីឆ្នាំ ២០០៧

[3]សូមអានមាត្រា ៥៧៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

សារជាតិជាកិច្ចឯកតោភាគី នៃមតកសាសន៍នោះទេ តែវាគ្រាន់តែជាយន្តការនៃការងារ និង ការផ្តល់សេរីភាពឲ្យដល់អ្នកដែលអានុភាពនៃកិច្ចនេះ ត្រូវមានលើតែបណ្តាំប៉ុណ្ណោះ ពោលគឺ លទ្ធភាព ក្នុងការសម្រេច ទទួល ឬ មិនទទួលយកនូវអំណាចនៃមតកសាសន៍នេះ ហើយ ការបដិសេធ ជា យថាហេតុណាមួយ គឺគ្រាន់តែជាការរុញច្រានចេញទៅវិញនូវទ្រព្យទាំងនោះអំពីបេតិកភណ្ឌរបស់ខ្លួន វិញប៉ុណ្ណោះ។

ដូចបានបញ្ជាក់ខាងលើដែលថា កិច្ចគតិយុត្តប្រភេទនេះ មានគោលដៅតែមួយគត់គឺ បង្កើតឲ្យមាននូវការផ្ទេរ ទ្រព្យពីបេតិកភណ្ឌនៃមតកជន ទៅបុគ្គលដែលមតកជន នោះ ចង់ផ្តល់ឲ្យ ដូចនេះអានុភាពរបស់កិច្ចនេះក៏មានតែមួយ គត់ដែរ គឺជាការផ្ទេរទ្រព្យចូលទៅក្នុង បេតិកភណ្ឌនៃអ្នកដែលត្រូវទទួលនោះ។ ដោយសារតែជា កិច្ចឯកតោភាគីផង និងដោយដសារ តែកិច្ចនឹងមានអានុភាព តែនៅក្រោយ មរណភាពនៃម្ចាស់ទ្រព្យផង អានុភាពនៃមតកសាសន៍ នេះ ហាក់ងាយស្រួលបង្កើតណាស់ ហើយវាហាក់ដូចជាពុំសូវសំខាន់សម្រាប់ ការសិក្សា បង្ហាញណាមួយ នៅទីនេះឡើយ។ អានុភាពនេះទៀតសោតហាក់អាស្រ័យជាសំខាន់ ទៅលើ កត្តាដ៏ទៃផ្សេងទៀតទៅវិញ។ផ្តើមចេញពីចំណុចនេះហើយ ទើបយើងសូមមិនលើកយកមក បង្ហាញឲ្យក្បោះក្បាយអំពីអានុភាពនៃមតកសាសន៍នេះទេ ដោយសម្រួចការសិក្សាលើប្រធានបទ "មតកសាសន៍"នេះជាសំខាន់តែទៅលើការបង្កើតកិច្ចនេះ ពោលគឺអំពីបណ្តាធាតុ សំខាន់ៗទាំងឡាយ សម្រាប់កំណត់ពីអត្ថិភាពតាមវិធាននៃមតកសាសន៍នេះ ដើម្បីអាចឲ្យ ច្បាប់ទទួលស្គាល់នូវការបង្កើតអានុភាពរបស់វា ប៉ុណ្ណោះ។ ច្បាប់ក្នុងន័យនេះ យើងនឹងផ្តោត ជាសំខាន់ទៅលើក្រមរដ្ឋប្បវេណីថ្មីឆ្នាំ ២០០៧ ដែលជាអនាគតនៃច្បាប់វិជ្ជ មានរបស់ យើងប៉ុណ្ណោះ។

ការពិតទៅ និយមន័យដែលលើកឡើងខាងលើ ក៏ហាក់នោពុំទាន់ច្បាស់លាស់ សម្រាប់ការស្វែងយល់អំពីមតក សាសន៍នេះនៅឡើយទេ។ ហេតុនេះ ការសិក្សានេះ នឹងមាន មហិច្ឆិតា បំភ្លឺឲ្យកាន់តែស៊ីជម្រៅថែមទៀតស្តីពីមតក សាសន៍នេះ។ តើមតកសាសន៍ ដែលជាកិច្ចឯកតោភាគីនេះជាអ្វីឲ្យប្រាកដ? ហេតុអ្វីបានជាកិច្ចដែលកើតពីបុគ្គលតែ ម្នាក់អាច មានអានុភាពគតិយុត្តបានដែរ? តើវាជាកិច្ចពិសេស? តើវាបញ្ញត្តិអំពីអ្វីខ្លះទៅនៅក្នុងនោះ? ចុះតើកិច្ចប្រភេទ នេះ ទាមទារនូវល័ក្ខខ័ណ្ឌអ្វីខ្លះ សម្រាប់ការបង្កើតដើម្បីអាចឲ្យ ច្បាប់ ទទួលស្គាល់ថាត្រឹមត្រូវបាន? ហើយបើមតក សាសន៍ មិនបានបំពេញឲ្យត្រឹមត្រូវ តាមល័ក្ខខ័ណ្ឌតម្រូវនេះទេ តើវានឹងមានផលវិបាកយ៉ាងដូចម្តេចដែរ?

ដើម្បីអាចឆ្លើយតបបាន នឹងសំណួរទាំងអម្បាលមានខាងលើ យើងសូមធ្វើ ការ សិក្សាជា ដំបូងនូវបណ្តា ល័ក្ខខ័ណ្ឌ ទាំងឡាយដែលក្រមរដ្ឋប្បវេណីថ្មីរបស់យើងបានតម្រូវ ដើម្បីឲ្យកិច្ច ពិសេស បែបមតកសាសន៍នេះ អាចបង្កើត បាននូវអានុភាពគតិយុត្តពិតប្រាកដ មួយតាមផ្លូវច្បាប់បាន ពោលគឺថា តើវាពិសេសយ៉ាងដូចម្តេច (**ជំពូកទី១**) មុននឹងធ្វើ ការវិភាគបង្ហាញជាបន្ទាន់ អំពីខ្លឹមសារសំខាន់ៗ នៃកិច្ចនេះ

ក្នុងបំណាងឲ្យរឹត តែអាចយល់ បានកាន់តែស៊ីជម្រៅអំពីកិច្ច គតិយុត្តបែបមតកសាសន៍នេះ បាន ផងដែរ (**ជំពូកទី២**)។

# ជំពូកទី១
# លក្ខខណ្ឌចាំបាច់នៃការបង្កើតមតកសាសន៍

# ជំពូកទី១
## លក្ខខណ្ឌចាំបាច់នៃការបង្កើតមតកសាសន៍

ដូចគ្នានឹងកិច្ចគតិយុត្តដទៃទៀតដែរ ដើម្បីអាចបង្កើតបាននូវអានុភាពតាមផ្លូវច្បាប់ មតកសាសន៍ត្រូវគោរពជាចាំបាច់នូវល័ក្ខខ័ណ្ឌនៃការបង្កើតលិខិត។ ជាគោលការណ៍ យើងអាចធ្វើការបែងចែក ល័ក្ខខ័ណ្ឌនេះជាពីរយ៉ាងគឺ ៖ ល័ក្ខខ័ណ្ឌជាគ្រឹះ និងល័ក្ខខ័ណ្ឌ ជាទម្រង់។

ចំពោះកិច្ចគតិយុត្តទាំងឡាយ ល័ក្ខខ័ណ្ឌជាគ្រឹះដើរតួនាទី អាអ្នកកំណត់ពីភាពចាំបាច់ ទាំងឡាយនៃសុពលភាព ផ្ទាល់របស់លិខិត។ ចំណែកឯការបំពានដោយ មិនបំពេញឲ្យបានគ្រប់ត្រឹមត្រូវនូវ ល័ក្ខខ័ណ្ឌជាទម្រង់គ្រាន់តែប្រើជា ល័ក្ខខ័ណ្ឌភស្តុតាង សម្រាប់បញ្ជាក់ពី អត្ថិភាពពិតប្រាកដ នៃកិច្ចគតិយុត្តប៉ុណ្ណោះ។ ពោលគឺប្រសិនបើអ្នកបង្កើតកិច្ចគតិយុត្ត ពុំបានគោរពតាមល័ក្ខខ័ណ្ឌជាទម្រង់នេះទេ វាពុំមានន័យថាកិច្ចដែលធ្វើឡើង នោះគ្មានសុពលភាពឡើយ ប៉ុន្តែក្នុងករណីមានការប្តឹងជំទាស់ នឹងសុពភាពរបស់លិខិតនេះ គេនឹងតម្រូវឲ្យ អ្នកបង្កើតលិខិតនោះ បង្ហាញភស្តុតាងអំពីវត្ត មានពិតប្រាកដ នៃលិខិតគតិយុត្ត ដែលគោរព ត្រឹមត្រូវតាមល័ក្ខខ័ណ្ឌជាគ្រឹះនេះរួចហើយប៉ុណ្ណោះ។ ដូចនេះ មានន័យថា ច្បាប់កំណត់ល័ក្ខខ័ណ្ឌគ្រឹះ ទុកដូចជាល័ក្ខខ័ណ្ឌចាំបាច់ និងដាច់ខាតសម្រាប់ សុពលភាពរបស់កិច្ច គតិយុត្តទាំងឡាយ ដែលត្រូវតែគោរព ក្នុងពេលបង្កើត។ រីឯល័ក្ខខ័ណ្ឌជាទម្រង់ប្រើសម្រាប់ គ្រាន់តែ ជាភស្តុតាងនៃសុពលភាពនេះ ក្រោយ ពេលបង្កើតប៉ុណ្ណោះ។

តើមតកសាសន៍ដែលគ្រាន់តែជាប្រភេទមួយនៃកិច្ចគតិយុត្តដែរនោះ ចាំបាច់ត្រូវ តែ បំពេញឲ្យបានជាធម្មតាតាម គោលការណ៍ខាងលើនេះ ដើម្បីឲ្យលិខិតមានសុពលភាពបាន ឬយ៉ាងណា?ពិតណាស់! ដោយហេតុថា មតកសាសន៍ នេះគឺជាកិច្ចសំដែងឆន្ទៈ ចុងក្រោយ នៃមតកជនសំដៅចាត់ចែងកិច្ចការ (ជាទូទៅ គឺចាត់ចែងទ្រព្យមតិក) ក្រោយពេល ស្លាប់ របស់គាត់ នោះល័ក្ខខ័ណ្ឌនៃការបង្កើតលិខិតនេះ នឹងដើរតួរឹតតែសំខាន់ និងរឹតតែជា សារវ័ន្តទៅទៀត។ ដោយ យោងតាមស្មារតីនៃក្រមរដ្ឋប្បវេណីថ្មីឆ្នាំ២០០៧ វាហាក់ដូចជាទាំង ល័ក្ខខ័ណ្ឌគ្រឹះ និងទាំងល័ក្ខខ័ណ្ឌទម្រង់ សុទ្ធសឹងជា ល័ក្ខខ័ណ្ឌនៃសុពលភាព របស់មតកសាសន៍ទាំងអស់ ពីព្រោះថា តាមក្រមនេះ ការមិនគោរពតាមល័ក្ខខ័ណ្ឌទាំងពីរសុទ្ធ សឹងជាមូលហេតុផ្ទាល់ នៃមោឃភាព របស់មតកសាសន៍ដូចគ្នា។ ហេតុនេះហើយ សំណួរចោទសួរថា តើមតកសាសន៍ នេះគឺពិតជាកិច្ចគតិយុត្តស្ថិតក្រោមល័ក្ខខ័ណ្ឌតម្រូវពិសេស ជាងកិច្ច គតិយុត្តផ្សេងទៀត ឬយ៉ាងណា? ចម្លើយនៃ ចំណោទនេះ នឹងក្លាយជាកម្មវត្ថុ នៃការបក ស្រាយក្នុងជំពូកនេះ។

ដើម្បីងាយស្រួលសិក្សាអំពីល័ក្ខខ័ណ្ឌតម្រូវ សម្រាប់ការបង្កើតលិខិតគតិយុត្តប្រភេទ មតកសាសន៍ យ៉ាងដូចម្ដេចខ្លះ និង ថាតើវាដូចនឹងកិច្ចគតិយុត្ត ឯទៀត ឬយ៉ាងណានោះយើងសូមធ្វើការបែងចែកការវិភាគតាមទិដ្ឋភាព ដូច បានបញ្ជាក់ខាងលើគឺះលក្ខ័ខ័ណ្ឌគ្រឹះផង **(ផ្នែកទី១)** និងល័ក្ខខ័ណ្ឌទម្រង់ផង**(ផ្នែកទី២)**។

## ផ្នែកទី១
## ល័ក្ខខ័ណ្ឌចាំបាច់ជាគ្រឹះនៃការបង្កើត

ជាគោលការណ៍ កិច្ចគតិយុត្តឯកតោភាគីទាំងអស់ តែងបិតនៅក្រោមល័ក្ខខ័ណ្ឌ តម្រូវជាគ្រឹះដូចគ្នានឹងល័ក្ខ ខណ្ឌតម្រូវចំពោះកិច្ចសន្យាដែរគឺ ល័ក្ខខ័ណ្ឌគ្រឹះនៃឆន្ទៈ សមត្ថភាព កម្មវត្ថុ និង មូលហេតុ[4]។ ហេតុនេះ តើកិច្ចគតិយុត្តបែបមតកសាសន៍ពិត ជាត្រូវស្ថិតនៅក្រោមល័ក្ខខ័ណ្ឌតម្រូវជាគ្រឹះ តាមគោលការណ៍នេះដែរ ឬយ៉ាងណា? ចម្លើយនោះគឺថា គោលការណ៍នេះ នឹងត្រូវបានកាត់បន្ថយ ចំពោះ កិច្ចគតិយុត្ត បែបមតកសាសន៍ នេះ[5]។

តាមពិតទៅ ការកាត់បន្ថយនេះបានកពីមូលហេតុដែលថា មតកសាសន៍ជាលិខិត កើតពីឆន្ទៈនៃបុគ្គលតែម្នាក់តែអាចបង្កើតអានុភាព (សិទ្ធិនិងករណីកិច្ច) ឲ្យដល់បុគ្គលដទៃទៀត (សន្តតិជន ឬ អច្ច័យលាភី) ហេតុនេះហើយ ទៀបល័ក្ខខ័ណ្ឌ ចាំបាច់គឺមាន តែម្យ៉ាង ប៉ុណ្ណោះដែលតម្រូវចំពោះ សុពលភាពនៃលិខិតបែបនេះ[6]ពោលគឺភាពពិតប្រាកដនៃឆន្ទៈរបស់មតកជនតែម្តង(**កថាខណ្ឌទី១**) ។ ប៉ុន្តែដោយសារឆនទៈនេះគ្រាន់តែជាឆន្ទៈនៃមតកជននោះផង និង ដោយហេតុថាលិខិតនេះអាចបង្កើតអានុភាពគតិយុត្តតែនៅក្រោយពេលស្លាប់នៃមតកជននោះផង បញ្ហាប្រសិទ្ធភាពនៃឆន្ទៈនេះ ក៏ត្រូវបានចោទឡើង ក្នុងក្របខ័ណ្ឌគតិយុត្តផងដែរ(**កថាខណ្ឌទី២**)។

### កថាខណ្ឌទី១ ៖ ភាពពិតប្រាកដនៃឆន្ទៈជាល័ក្ខខ័ណ្ឌគ្រឹះតែមួយគត់នៃមតកសាសន៍

ភាពពិតប្រាកដនៃឆន្ទៈ[7]គឺជាគុណភាពចាំបាច់ ដើម្បីធានា នូវខ្លឹមសាររបស់មតកសាសន៍ផង និងដើម្បីឲ្យការប្រតិបត្តិមតកសាសន៍ អាចស្របតាមអ្វី ដែលមតកជនប្រាថ្នាមុនពេលស្លាប់ផង។ ភាពស្របតាមនេះ គឺជា

---

[4]សូមបញ្ជាក់ថា ល័ក្ខខ័ណ្ឌមូលហេតុនៃការបង្កើតលិខិតនេះ ត្រូវបានទទួលស្គាល់ ជាល័ក្ខខ័ណ្ឌគ្រឹះ នៅក្នុងនីតិរដ្ឋមានបារាំងប៉ុណ្ណោះ ប៉ុន្តែ នីតិរដ្ឋមានខ្មែរពុំចាត់ទុកល័ក្ខខ័ណ្ឌនេះ ជាល័ក្ខខ័ណ្ឌមួយនៃការបង្កើតរាល់លិខិតគតិយុត្តឡើយ។

[5]សូមមើលសៀវភៅរបស់ Jacques Flour, Jean-Jean Aubert, Eric Savauxមានចំណងជើងថា " Les obligations, 1.L'acte juridique"បោះពុម្ពលើកទី៩ នាឆ្នាំ២០០០ ទំព័រ៣៦១។

[6]ជាការពិតណាស់ ល័ក្ខខ័ណ្ឌផ្សេងទៀតក៏អាចមានឥទ្ធិពលចំពោះសុពលភាពនៃមតកសាសន៍នេះផងដែរ តួយ៉ាងដូចជាក្នុងករណីបើមតក សាសន៍នោះធ្វើឡើង សំដៅចាត់ចែងទ្រព្យរបស់អ្នកដទៃ ឬទ្រព្យជាផលនៃបទល្មើសព្រហ្មទណ្ឌជាដើម នោះមតកសាសន៍នោះ អាចនឹងត្រូវប្រកាសមោឃភាពដោយមូលហេតុកម្មវត្ថុខុសច្បាប់។ប៉ុន្តែនៅទីនេះ យើងសូមមិនធ្វើការពិចារណាចំពោះល័ក្ខខ័ណ្ឌនៃទ្រព្យដោយធ្វើការសន្មត ថា ទ្រព្យចាត់ចែងដោយមតកសាសន៍គឺស្របច្បាប់។

[7]ភាសាឡាតាំងថា <<Animus testandi>>មានន័យសំដៅដល់ឆន្ទៈពិតប្រាកដនៃម្ចាស់បណ្តាំក្នុងការផ្តាំផ្ញើតាមរយៈមតកសាសន៍។

ចំនុចសំខាន់តែមួយគត់ ដែលនាំឲ្យច្បាប់ ព្រមទទួលយកអានុភាពនៃលិខិតនេះ។ ហេតុនេះ ឆន្ទៈត្រូវតែបញ្ចេញមក ដោយពិតប្រាកដ ជៀសផុតឲ្យបានដាច់ខាងអំពីវិការៈទាំងឡាយផង(ក) ហើយមតកជនផ្ទាល់ក៏ត្រូវមានសមត្ថភាពតាមច្បាប់គ្រាប់គ្រាន់ ដើម្បីអាចកំណត់ពីភាពត្រឹមត្រូវ ពិតប្រាកដនៃឆន្ទៈ នេះបានផង(ខ)។

**ក..ការជៀសផុតអំពីវិការៈនៃឆន្ទៈ**

ជាទូទៅការសិក្សាអំពីកិច្ចសន្យា តែងបង្ហាញថាឆន្ទៈមានវិការៈលុះណាតែឆន្ទ់នោះកើតឡើង ដោយមានការភាន់ច្រឡំ ការបន្លំ ឬដោយការប្រើប្រាស់ហឹង្សាបង្ខំ។ ដូចនេះឆន្ទៈមួយអាចពិតប្រាកដទៅបាន លុះណាតែឆន្ទៈនោះសម្តែងឡើង ដោយចៀសផុតអំពីសម្មតិកម្មទាំងបីនេះ។ សម្មតិកម្មទាំងបីនេះ សុទ្ធតែអាច កើតឡើងដូចគ្នាដែរចំពោះករណីមតកសាសន៍នេះ ប៉ុន្តែដោយហេតុថាមតកសាសន៍ ជាលិខិតផ្ទាល់ខ្លួន របស់បុគ្គលតែម្នាក់ហើយជូនកាលសម្ងាត់[8]ផងនោះយើងកត់សម្គាល់ឃើញថា ករណីនៃការភាន់ច្រឡំ ហាក់ដូចជាអាចជា ដើមចមសំខាន់តែមួយគត់ដែលអាចកើតមានញឹកញាប់បំផុត ចំពោះវិការៈនៃឆន្ទៈ ក្នុងករណីគុណភាព នៃអត្តគាហក[9] ហើយសម្រេច ប្រគល់ទ្រព្យជាមត៌ក របស់ខ្លួន ទៅឲ្យជននោះ សន្តតិជននៃម្ចាស់ បណ្តាំនោះនៅតែអាច បដិសេធសុពលភាពនៃមតកសាសន៍នោះ ចោលបានដោយផ្អែកលើមូលដ្ឋាននៃមាត្រា ១១៦៩[10] នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។ ដូចគ្នានេះដែរក្នុង ករណីដែលឆន្ទៈបញ្ចេញនោះ ធ្វើឡើងក្នុងពេលម្ចាស់ បណ្តាំ ស្រវឹងស្រា ខ្លាំងឬមានជម្ងឺវង្វេងដោយភាពចាស់ជរា។ល។[11]

ដូច្នេះ ដើម្បីជៀសឲ្យផុតពីការភាន់ច្រឡំ ឬ ភាពមិនច្បាស់លាស់ណាមួយលើឆន្ទៈ របស់ម្ចាស់បណ្តាំជាយថាហេតុ ទើបជាគោលការណ៍ ម្ចាស់បណ្តាំតែងត្រូវបាន តម្រូវឲ្យ បញ្ជាក់ឲ្យបានច្បាស់លាស់នៅក្នុងមតកសាសន៍របស់ខ្លួន អំពីរបៀបនៃការចាត់ចែងទ្រព្យ មត៌ករបស់គាត់ផង និងអំពីអត្តសញ្ញាណ

---

[8] ត្រង់ចំណុចនេះ សូមអាននៅចំណុចខាងមុខ ស្តីពី ៖ "*ល័ក្ខខ័ណ្ឌចាំបាច់ជាទម្រង់នៃមតកសាសន៍*" ។

[9]ពាក្យ " អត្តគាហក " ក្នុងន័យនេះចង់សំដៅដល់បុគ្គលទាំងឡាយដែលទទួលបានផលប្រយោជន៍អំពីមតកសាសន៍នេះ។ ដូចនេះបុគ្គលទាំង នោះ អាចជាសន្តតិជនៃមតកជន ឬ/និងអាចជាអច្ច័យលាភីក្នុងករណីមានអច្ច័យទាន។

[10] មាត្រា១១៦៩ កថាខណ្ឌទី២ ចែងថា ៖ "*បុគ្គលដែលអះអាងអំពីខ្វះសមត្ថភាពរបស់ម្ចាស់បណ្តាំ ត្រូវបញ្ជាក់ភស្តុតាងអំពីហេតុផលនោះ [...]* "។ គួសបញ្ជាក់ដែរថា សមត្ថភាពក្នុងន័យនេះ សំដៅទាំងសមត្ថភាពខាងអាយុ និង ខាងទាំបញ្ញាស្មារតីផងដែរ។

[11] សូមមើល "*សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៦ គន្ថីទី៨ ទី៩* រៀបរៀងដោយក្រុមការងារជប៉ុន ដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី ឆ្នាំ ២០១០ កំណត់ពន្យល់ចំពោះមាត្រា ១១៦៩ ទំព័រ ៣១។

នៃបុគ្គលដែលត្រូវទទួលមតិករបស់គាត់ នោះផងពិសេសក្នុងករណីអច្ច័យទាន[12]។ ការមិនបានបញ្ជាក់ឲ្យច្បាស់នេះនឹងក្លាយជា មូលហេតុ នៃមោឃភាពលិខិត មតកសាសន៍នោះ[13]។

ភាពិតប្រាកដនៃឆន្ទៈ ក៏អាចត្រូវបានតម្រូវឲ្យ តាមរយៈរូបភាពនៃការកំណត់នូវល័ក្ខខ័ណ្ឌ សមត្ថភាពដល់ម្ចាស់បណ្ដាំ នាពេលបញ្ចេញឆន្ទៈនោះផងដែរ។

**ខ.សមត្ថភាពគ្រប់គ្រាន់នៃមតកជន**

ដូចកិច្ចគតិយុត្តដទៃទៀតដែរ មតកសាសន៍ ត្រូវតែធ្វើឡើងដោយបុគ្គលដែលមានសមត្ថភាព គ្រប់គ្រាន់ តាមផ្លូវច្បាប់។ ដោយឈរលើមូលដ្ឋាននៃសារជាតិរបស់លិខិត អាចអនុញ្ញាតឲ្យយើងបែងចែកដំណាក់កាលនៃការគិតអំពីសមត្ថភាពរបស់ម្ចាស់បណ្ដាំនេះជាពីរគឺ ៖ នៅពេលតាក់តែងមតកសាសន៍ និងនៅពេលមតកជន ទទួលមរណភាព។ សំណួរស្ថិតត្រង់ថា តើសមត្ថភាពនេះ ត្រូវគិតនៅថ្ងៃដែលម្ចាស់បណ្ដាំធ្វើលិខិត ឬក៏នៅថ្ងៃដែលគាត់ស្លាប់។ ពិតណាស់! ការគិតសមត្ថភាពនាថ្ងៃស្លាប់ពុំគ្រប់គ្រាន់ឡើយ។ ហេតុនេះហើយ យោងតាមមាត្រា ១១៦៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ម្ចាស់បណ្ដាំត្រូវមានសមត្ថភាពនៅពេលធ្វើមតកសាសន៍។ ហើយសមត្ថភាពនេះ បើតាមមាត្រា ១១៦៨ សំដៅដល់គុណភាពនៃបុគ្គលដែលត្រូវជា នីតិជន ឬ ជាអនីតិជន ដែលបានអត្តាធិនភាពរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ឬអំណាចមេបា[14]។

ក្នុងន័យនេះ មតកសាសន៍ ដែលត្រូវបាន ធ្វើឡើងដោយអនីតិជនគ្មានអត្តាធិនភាព ឬបានក្លាយជានីតិជនរួចហើយ ក៏ដោយ[15] លើកលែងតែនៅក្រោយពេលទទួលបាននោះ គាត់បានបញ្ចេញឆន្ទៈអះអាង សារជាថ្មី ដើម្បីធានា នូវគុណភាពរបស់បណ្ដាំ។

ជាគោលការណ៍ ការតម្រូវរបស់ច្បាប់ចំពោះសមត្ថភាព នៅក្នុងការបង្កើតលិខិត គតិយុត្តមួយពុំមានគោលដៅ សម្រាប់តែកំណត់អំពីគុណភាពនៃឆន្ទៈមួយមុខនោះទេ តែក៏នៅមានគោលដៅ ផ្សេងទៀតដូចជាការគិតទៅដល់ កត្តាជីវសាស្ត្ររបស់មនុស្សជាអាទិ៍ ៖ (សមត្ថភាពអាចបន្តពូជចំពោះកិច្ចសន្យាអាពាហ៍ពិពាហ៍ ឬសមត្ថភាពអាចលីសែង ឬធ្វើ ការងារធ្ងន់ចំពោះកិច្ចសន្យាការងារមួយចំនួន -ល-)។ ប៉ុន្តែចំពោះមតកសាសន៍នេះវិញ គោលដៅផ្សេងទៀតទាំងនេះ ត្រូវបានកាត់បន្ថយទាំងអស់។ ក្នុងន័យនេះ

---

[12]ត្រង់ចំណុចនេះ សូមអានទៅចំណុចខាងមុខ ស្ដីពី៖ *"របបអច្ច័យទាន"*។

[13] ខ្មែរយើងពុំធ្លាប់មានយុត្តិសាស្ត្របញ្ជាក់អំពីករណីនេះឡើយ។ ក៏ប៉ុន្តែយុត្តិសាស្ត្រ បារាំងធ្លាប់បានប្រកាសពីមោឃភាព នេះរួចមកហើយ ចំពោះអច្ច័យទានដែលគុណភាពនៃអច្ច័យលាភី ពុំត្រូវបាន បញ្ជាក់ច្បាស់ក្នុងមតកសាសន៍ (Cass civ.12 aout 1863)

[14]អត្តាធិនភាព សំដៅដល់ស្ថានភាពមួយដែលផ្ដល់ឲ្យអនីតិជនបានរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ឬរួចផុតពីអំណាចមេបា ហើយមានសមត្ថភាពដូចនីតិជនដែរ (តាមសទ្ធានុក្រមផ្នែករដ្ឋប្បវេណី នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧) ។

[15]នេះបើយើងធ្វើការបកស្រាយតាមន័យផ្ទុយ ទៅលើមាត្រា១១៦៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧)។

យើងអាចនិយាយបានថាសមត្ថភាពដែលតម្រូវចំពោះម្ចាស់បណ្ដាំគឺមាន គោលដៅគ្រាន់តែចង់ ធានាឲ្យបាន នូវគុណភាពពិតប្រាកដមួយចំពោះឆន្ទៈ ដែលបានបញ្ចេញដោយ ម្ចាស់បណ្ដាំតែម្យ៉ាង ប៉ុណ្ណោះ (សមត្ថភាពខាងឆន្ទៈ) ពីព្រោះថា មតកសាសន៍នេះ មិនមានឥទ្ធិពលទាល់តែសោះ ទៅលើជីវភាពរស់នៅរបស់ម្ចាស់បណ្ដាំ ដោយសារអានុភាពរបស់វា កើតមានតែនៅ ក្រោយពេលម្ចាស់បណ្ដាំស្លាប់ ហើយអានុភាពនេះសោតកើតតែទៅលើការចាត់ចែង ទ្រព្យសម្បត្តិដែលនៅសេសសល់ ក្រោយពេលស្លាប់របស់គាត់ប៉ុណ្ណោះ។ ហេតុនេះ ទើបតាមរយៈក្រមនេះទោះបី ជាអ្នកដែលត្រូវបាន កម្រិតសមត្ថភាពក៏ដោយ[16] ក៏នៅតែអាចធ្វើមតកសាសន៍បានជាដដែល គ្រាន់តែត្រូវបន្ថែមល័ក្ខខ័ណ្ឌមួយចំនួន ដើម្បីអាចបញ្ជាក់ពីភាពពិតប្រាកដនៃឆន្ទៈ ដែលបញ្ចេញមកនោះប៉ុណ្ណោះ[17] ។

ទោះជាយ៉ាងនេះក្ដី ក្រមនេះបានទទួលស្គាល់ សមត្ថភាពនៃម្ចាស់បណ្ដាំ ទុកដូចជា គោលការណ៍ រីឯការ បដិសេធសមត្ថភាពវិញ ត្រូវចាត់ទុកត្រឹមជា អញ្ញត្រកម្មមួយ ប៉ុណ្ណោះដែលអ្នក អះអាងត្រូវតែបង្ហាញភស្តុតាងអំពី អសមត្ថភាពនៃមតកជន នាពេល ធ្វើលិខិតមតកសាសន៍[18] ។

លក្ខណៈពិសេសដោយឡែកមួយទៀត នៃកិច្ចគតិយុត្តបែបមតកសាសន៍នេះ គឺស្ថិតត្រង់ថាបើទោះបីជាកិច្ចនេះ បង្កើតឡើងដោយបំពេញបានត្រឹមត្រូវគ្រប់គ្រាន់រួចហើយ នូវល័ក្ខខ័ណ្ឌពិតប្រាកដនៃឆន្ទៈដែលជាល័ក្ខខ័ណ្ឌគ្រឹះ តែមួយគត់នេះក៏ដោយ ក៏បញ្ហាប្រសិទ្ធភាពនៃឆន្ទៈ នៅតែអាចចោទឡើងចំពោះសុពលភាពនៃលិខិតជាដរាប។

**កថាខណ្ឌទី២ ៖ អប្រសិទ្ធភាពនៃឆន្ទៈរបស់មតកជន**

---

[16] ជនដែលច្បាប់កម្រិតសមត្ថភាពនេះសំដៅដល់អ្នកដែលនៅក្រោមអាណាព្យាបាលទូទៅ ឬ អ្នកនៅក្រោមហិត្តូបត្ថម្ភ ដែលបានទទួលការប្រកាសចាប់ផ្ដើមអាណាព្យាបាល ឬហិត្តូបត្ថម្ភ។ ប៉ុន្តែតាមមាត្រា ១១៧៦ នៃក្រមនេះ ជននេះក៏នៅមានលទ្ធភាពធ្វើមតកសាសន៍ផងដែរ ដោយគ្រាន់តែបំពេញឲ្យបាននូវល័ក្ខខ័ណ្ឌបន្ថែមមួយចំនួន ដើម្បីអាចបញ្ជាក់បាន ពីគុណភាពនៃ ឆន្ទៈនេះ ប៉ុណ្ណោះ ពោលគឺ ការតម្រូវឲ្យមានវត្តមានរបស់វេជ្ជបណ្ឌិតយ៉ាងតិចពីរនាក់ នៅពេលធ្វើមតកសាសន៍នោះ ។ វេជ្ជបណ្ឌិតនោះសរសេរបញ្ជាក់នៅលើលិខិតមតកសាសន៍ថា "*នៅពេលដែលម្ចាស់បណ្ដាំ បានធ្វើមតកសាសន៍នោះ ម្ចាស់បណ្ដាំពុំបានស្ថិត ក្នុងស្ថានភាពខ្វះសមត្ថភាព ក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសមត្ថភាពរបស់ខ្លួន ដោយសារមានវិបត្តិ ស្មារតីនោះទេ*"រួចហើយត្រូវចុះហត្ថលេខាដោយបញ្ជាក់ថា "*ខ្លួនជាវេជ្ជបណ្ឌិត*"ផងដែរ។

[17] សូមមើល " សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីភាគី៦ , គន្ថីទី៨-ទី៩ រៀបរៀងដោយក្រុមការងារជប៉ុនដែលទទួលបន្ទុក ធ្វើសេចក្ដីព្រាងក្រមរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្ដីព្រាងក្រមរដ្ឋប្បវេណី, ឆ្នាំ២០១០ កំណត់ពន្យល់ចំពោះមាត្រា១១៥៨,ទំព័រ៣០ និង៣១។

[18] កថាខណ្ឌទី២នៃមាត្រា១១៦៨ ចែងថា៖ " បុគ្គលដែលអះអាងអំពីការខ្វះសមត្ថភាពរបស់ម្ចាស់បណ្ដាំ ត្រូវបញ្ជាក់ភស្តុតាងអំពីហេតុនោះ។ ប៉ុន្តែ បញ្ញត្តិនេះមិត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលបានកំណត់នៅក្នុងមាត្រា១១៧៦ (មតកសាសន៍នៃជននៅក្រោមអាណាព្យាបាល ទូទៅ) នៃក្រមនេះ"។

ពិតណាស់ថា មតកសាសន៍ ដែលបានបំពេញនូវល័ក្ខខ័ណ្ឌគ្រឹះ នឹងអាចក្លាយជាកិច្ចដែលច្បាប់ព្រមទទួលស្គាល់នូវអនុភាពគតិយុត្ត ក៏ប៉ុន្តែអានុភាពនេះ ពុំសុទ្ធតែមានប្រសិទ្ធភាពបរិបូរណ៍ នោះឡើយ ដោយហេតុថាចាប់តាំងពីដំណាក់កាល នៃការតាក់តែងរហូតដល់ការស្លាប់ របស់ម្ចាស់បណ្តាំ មតកសាសន៍ត្រូវបានចាត់ទុកគ្រាន់តែជាគម្រោង នៃការព្យាករណ៍មួយ របស់ម្ចាស់បណ្តាំប៉ុណ្ណោះ។ ដូចនេះ ប្រសិទ្ធភាពនៃឆន្ទៈរបស់ម្ចាស់បណ្តាំនេះអាចប្រែប្រួល ទាំងនៅមុន និង ក្រោយមរណភាពរបស់គាត់។ ដោយមិនរាប់បញ្ចូលនូវ អប្រសិទ្ធភាព ក្នុងករណីដែលឆន្ទៈនៃមតកជននោះ បានបំពានដល់ ភាគបម្រុង[19] និង ក្នុងករណីដែលល័ក្ខខ័ណ្ឌជាបន្ទុកនៃមតកសាសន៍ មិនត្រូវបានបំពេញដោយ អត្ថគាហក បើជាមតកសាសន៍ ជាប់បន្ទុក ឬល័ក្ខខ័ណ្ឌបង្អង់[20] មានសម្មតិកម្មតែបី យ៉ាងប៉ុណ្ណោះ ដែលអាចជា មូលហេតុបណ្តាលឲ្យ ប្រសិទ្ធិភាពនៃមតកសាសន៍ ដែលកើតពី ឆន្ទៈពិតប្រាកដរបស់មតកជន ត្រូវបានកាត់បន្ថយ (អប្រសិទ្ធភាព ដោយផ្នែក) ឬអាចបណ្តាលឲ្យអស់ប្រសិទ្ធភាពទាំងស្រុងតែម្តង[21] ។ សម្មតិកម្មទាំងបីនោះរួមមាន៖ ជូនកាល ម្ចាស់បណ្តាំខ្លួនឯងបានលុបឆន្ទៈនោះចោលវិញ (**ក**) ឬជួនកាល អត្ថគាហកនៃមតកសាសន៍នោះ បានបដិសេធន៍អានុ ភាពគតិយុត្ត នៃមតកសាសន៍ នោះចោលនៅក្រោយមរណភាពនៃមតកជន(**ខ**) ឬជួនកាលទៀត ទ្រព្យជាកម្មវត្ថុនៃ មតកសាសន៍ នោះបានវិនាសបង់ ឬក៏អត្ថគាហក នៃ មតកសាសន៍នោះបានស្លាប់ នៅពេលចាប់ផ្តើមមតកសាសន៍(**គ**)។

**ក.ការផ្លាស់ប្តូរឆន្ទៈរបស់មតកជន**

ដោយសារមតកសាសន៍អាចបង្កើតអានុភាពតែក្រោយ ការអស់ជីវិតនៃមតកជន ច្បាប់បានទទួលស្គាល់សិទ្ធិផ្តាច់មុខរបស់ម្ចាស់បណ្តាំ ក្នុងការកែប្រែ ឬលុបចោលនូវមតកសាសន៍ដែលខ្លួនបានធ្វើ រួចរាល់ហើយ នៅគ្រប់ពេលវេលាទាំងអស់នៅមុនថ្ងៃមរណភាពរបស់គាត់។ មាត្រា ១១៨៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ

[19] ត្រង់ចំណុចនេះសូមមើលទៅចំណុចខាងមុខស្តីពី៖ "ដែលកម្រិតនៃការលុបសិទ្ធិលើមតិកពីសន្តតិជន"។

[20] ជាគោលការណ៍ ច្បាប់តែងទទួលស្គាល់នូវឆន្ទៈក្នុងការបង្កើតបន្ទុក សម្រាប់ជាល័ក្ខខ័ណ្ឌទទួលបានទ្រព្យជាមតិក តែនៅក្នុងករណីនៃអច្ច័យ ទានប៉ុណ្ណោះ (សូមអានមាត្រា១២១១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧) ពីព្រោះថា អច្ច័យទាននេះត្រូវបានប្រដូចទៅនឹងអំណោយ (ប្រទានកម្ម) ដែលកើតចេញពីឆន្ទៈសេរីរបស់មតកជន ក្នុងការចាត់ចែងទ្រព្យសម្បត្តិរបស់គាត់ ហេតុនេះហើយ ទើបឆន្ទៈបង្កើតអច្ច័យទាននៃមតកជននេះអាចភ្ជាប់ជាមួយនូវបន្ទុកណាមួយជាថ្នូរនឹង ការទទួលបាន នូវអំណោយនេះ (ដូចក្នុងករណីអំណោយមានល័ក្ខខ័ណ្ឌដែរ)។ ប៉ុន្តែចំពោះសន្តតិកម្ម ការផ្ទេរនូវទ្រព្យ គឺជាកិច្ចដែល ត្រូវតែកើតមានក្រោយមរណភាពនៃមតកជនទោះជាមាន ឬគ្មានមតកសាសន៍ក៏ដោយ ដូចនេះឆន្ទៈក្នុងការដាក់ ល័ក្ខខ័ណ្ឌ ជាបន្ទុកណាមួយដែលអាចជាឧបសគ្គដល់ការផ្ទេរនេះនឹងត្រូវហាមគាត់។ ត្រង់ចំណុចនេះ សូមអានសៀវភៅរបស់ Jean-Louis Baudouin, Pierre-Gabriel Jobinមានចំណងជើងថា៖ << Les obligations >>បោះពុម្ពលើកទី៥ នាឆ្នាំ១៩៩៨ ទំព័រ ៤៦២។

[21] ក្នុងករណីបើមានអច្ច័យទាន អប្រសិទ្ធភាពនៃមតកសាស្ត្រនេះ ពុំមានន័យតែត្រឹមថា មតកសាសន៍បាត់បង់អនុភាព គតិយុត្តអនុវត្តនោះទេ ប៉ុន្តែក៏មានន័យដោយមិនផ្ទាល់ដែរថា វានឹងបង្កើតផលប្រយោជន៍ ខាងមតិកឲ្យដល់សន្តតិជនតាមច្បាប់ នៃ មតកជននោះ។ ត្រង់ចំណុចនេះ សូមអាន នូវចំណុចស្តីពី៖ "*ល័ក្ខខ័ណ្ឌចាំបាច់ជាទម្រង់នៃមតកសាសន៍*"។

២០០៧ ចែងថា៖ " *ម្ចាស់បណ្ដាំអាចលុបចោល នូវមតកសាសន៍មួយភាគ ឬទាំងមូលនៅពេលណាក៏បាន*"។ ក្រមនេះទទួលស្គាល់ផងដែរនូវរូបភាពពីរយ៉ាងនៃការកែប្រែ ឬលុបនេះពោលគឺ ៖ ដោយជាក់លាក់ និង ដោយតុណ្ហីភាព។

ត្រូវចាត់ទុកជាការកែប្រែ ឬលុបដោយជាក់លាក់ប្រសិនបើម្ចាស់បណ្ដាំ ធ្វើលិខិតមតកសាសន៍ថ្មីដោយបញ្ជាក់សេចក្ដីច្បាស់ថា៖ " *លុបមតកសាសន៍មុនចោល*"[22] ។ ដោយមិនមានល័ក្ខខ័ណ្ឌកម្រិតអ្វីផ្សេងឡើយ មតកសាសន៍ដែលធ្វើឡើងដោយទម្រង់ណាក៏ដោយ[23] សុទ្ធតែអាចលុបចោលដោយមតកសាសន៍ថ្មីតាមទម្រង់ នៃមតកសាសន៍ដែលត្រូវលុបនោះក៏បាន ឬតាមទម្រង់ដែលខុសពីទម្រង់នៃមតកសាសន៍មុននោះក៏បាន។ ក្នុងន័យនេះមតកជន អាចលុបមតកសាសន៍ដែលខ្លួនធ្វើឡើងតាមទម្រង់យថាភូតដោយការបង្កើតមតកសាសន៍ថ្មី ដែលមានខ្លឹមសារជាការលុប មតកសាសន៍ចាស់ចោល តាមទម្រង់យថាភូតដូចគ្នាក៏បាន ឬតាមទម្រង់នៃលិខិតឯកជនក៏បាន។ ករណីនេះបញ្ហាចោទនៅត្រង់ថាបើមតកជនសំដែងឆន្ទៈកែប្រែ ឬលុបមតកសាសន៍ចោល តាមរយៈពាក្យសំដី តែពុំបានសរសេរជាលាយលក្ខណ៍អក្សរ តើចាត់ទុកជាការលុបដោយជាក់លាក់ដែរឬទេ? ក្រមរដ្ឋប្បវេណីហាក់ពុំបានបញ្ញត្តិករណីនេះឡើយ ប៉ុន្តែក្រមហាក់ពុំទទួលស្គាល់សុពលភាពនៃការកែប្រែ ឬលុបចោលតាមរូបភាពនេះដែរ។

ចំណែកការកែប្រែ ឬលុបមតកសាសន៍ដោយតុណ្ហីភាពវិញ សំដៅដល់ទម្រង់បីយ៉ាង ដែលកំណត់ក្នុងក្រមរដ្ឋប្បវេណីថ្មី ៖

*ទីមួយ* ក្នុងករណីដែលម្ចាស់បណ្ដាំគ្រាន់តែបង្កើតមតកសាសន៍ថ្មី ដែលមាន ខ្លឹមសារដែលផ្ទុយពីមតកសាសន៍ដែលខ្លួនបានធ្វើជាមុនជាការស្រេច។ ទាក់ទងនឹងចំណុចនេះ ច្បាប់ទទួលស្គាល់អត្ថិភាព នៃមតកសាសន៍ក្រោយនេះថាបានកែប្រែ ឬលុបចោលមតកសាសន៍ដែលបានធ្វើមុន ចំពោះផ្នែកដែលផ្ទុយគ្នានោះប៉ុណ្ណោះ[24]។

---

[22]សូមមើលមាត្រា១១៨៩ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

[23]ត្រង់ចំណុចនេះ សូមអានទៅចំណុចខាងមុខ ស្ដីពី៖" *ល័ក្ខខ័ណ្ឌចាំបាច់ជាទម្រង់នៃមតកសាសន៍*"។

[24]យោងតាមមាត្រា១១៨៩ កថាខណ្ឌទី២ ចែងថា៖ "*បើមតកសាសន៍ដែលបានធ្វើក្រោយនេះ មានភាពផ្ទុយនឹង តមកសាសន៍ដែលបានធ្វើមុន ត្រូវចាត់ទុកថា មតកសាសន៍ដែលបានធ្វើក្រោយនោះ បានលុបចោល មតកសាសន៍ដែលបានធ្វើមុនចំពោះផ្នែកដែលផ្ទុយគ្នានេះ*"។

*ទីពីរ* គឺក្នុងករណីដែលម្ចាស់បណ្តាំ នាពេលនៅរស់ បានចាត់ចែងទ្រព្យជាកម្មវត្ថុនៃ មតកសាសន៍នោះហើយបណ្តាលឲ្យ ខ្លឹមសារនៃមតកសាសន៍នោះពុំអាចអនុវត្តកើត[25] ។ តាមសន្តតិកម្មនេះ យើងអាចយល់បានថាបើតាមរយៈមតកសាសន៍ ម្ចាស់បណ្តាំ បាន បញ្ញត្តិច្បាស់ថា ប្រគល់ផ្ទះមួយខ្នងឲ្យទៅលោក "ក" ប៉ុន្តែនាពេលនៅរស់ ម្ចាស់បណ្តាំ បានលក់ ឬបានធ្វើអំណោយផ្ទះមួយខ្នងនោះបាត់ទៅហើយ ដូច្នេះនាក្រោយពេល ម្ចាស់ បណ្តាំស្លាប់ បើទោះជាបញ្ញត្តិ នៅមានសុពលភាពនាថ្ងៃបើកមតកសាសន៍ ក៏ដោយក៏ច្បាប់ ចាត់ទុកថា ខ្លឹមសារនៃមតកសាសន៍ដែលថា ប្រគល់ផ្ទះ មួយខ្នងនោះទៅឲ្យលោក"ក" គឺបានត្រូវលុបចោលដោយម្ចាស់បណ្តាំតាមរយៈ ការចាត់ចែងនាពេលនៅរស់ រួចបាត់ទៅហើយ ហើយ អានុភាព នៃខ្លឹមសារនេះ ក៏បានបាត់បង់លែងអនុវត្តកើតរួចហើយដែរ។

*ទីបី* គឺក្នុងករណីនៃអច្ច័យទានដែលមានភ្ជាប់បន្ទុក ឬល័ក្ខខ័ណ្ឌ ហើយអច្ច័យលាភី ពុំបានបំពេញតាមបន្ទុក ឬ ល័ក្ខខ័ណ្ឌនោះ។ ក្នុងករណីនេះ ច្បាប់ចាត់ទុកថា ការមិនបំពេញ ឲ្យបាននូវបន្ទុក ឬល័ក្ខខ័ណ្ឌតាមឆន្ទៈរបស់ម្ចាស់បណ្តាំ នឹងត្រូវចាត់ទុកជាម្ចាស់ បណ្តាំបាន លុបចោលនូវអច្ច័យទាននោះ ហើយមតកសាសន៍ ដែលមានខ្លឹមសារជាអច្ច័យទាន ក៏ពុំមាន ប្រសិទ្ធភាពអនុវត្តបានដែរ។ប៉ុន្តែការលុបចោលនេះ ក្រមរដ្ឋប្បវេណីហាក់ តម្រូវឲ្យធ្វើតាមផ្លូវតុលាការ និងត្រូវនៅពេលមានការដាស់តឿនឲ្យ អច្ច័យលាភីបំពេញករណីកិច្ចនេះរួចហើយ តែគ្មានប្រសិទ្ធិភាព[26] ។

**ខ.ការបដិសេធនៃអត្តគាហក**

ទោះបីជាក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានប្រកាន់យកគោលការណ៍ទទួលបន្ទុក ដោយស្វ័យប្រវត្តិនូវមតិកធ្វើ ជាមូលដ្ឋានក៏ដោយ ក៏ក្រមនេះទទួលស្គាល់ផងដែរ នូវគោលការណ៍ ជម្រះបញ្ជី មតិកជាមុនក្នុងគោលដៅបញ្ចៀសនូវ ភាពធ្ងន់ធ្ងរនៃកាតព្វកិច្ច ដែលបន្សល់ ទុកដោយមតកជន[27] ។ ដូចនេះ

[25] យោងតាមមាត្រា ១១៩០ ចែងថា ៖ " *បើម្ចាស់បណ្តាំបានធ្វើអនុប្បទាន ឬ បានធ្វើសកម្មភាពផ្សេងទៀត ចំពោះវត្ថុ ដែលជាកម្មវត្ថុ នៃមតកសាសន៍ នាពេលនៅរស់ ត្រូវចាត់ទុកថា ម្ចាស់បណ្តាំបានលុបចោលមតកសាសន៍ ចំពោះផ្នែកដែលផ្ទុយនឹង អនុប្បទាន ឬសកម្មភាពផ្សេងនោះ។*

[26]យោងតាមមាត្រា ១១៩៣ ចែងថា៖ "*បើអច្ច័យលាភីពុំបានអនុវត្តករណីកិច្ចដែលម្ចាស់បណ្តាំបានតម្រូវឲ្យអច្ច័យលាភីនោះទទួលបន្ទុកជាថ្នូ និងអច្ច័យទានទេ អ្នកប្រតិបត្តិមតកសាសន៍ ឬបើគ្មានអ្នកប្រតិបត្តិមតកសាសន៍នោះទេ សន្តតិជនអាចដាស់តឿនឲ្យអច្ច័យលាភីនោះ អនុវត្ត ករណីកិច្ច នៅក្នុងអំឡុងពេលនោះទេ អ្នកប្រតិបត្តិមតកសាសន៍ ឬសន្តតិជននោះអាចទាមទារទៅតុលាការឲ្យលុបចោលអច្ច័យទាននោះបាន" សូមមើលមាត្រា១២០២ ស្តីអំពីការដាស់តឿនរបស់ជន ដែលពាក់ព័ន្ធនឹងផលប្រយោជន៍ផងដែរ។*

[27]សូមមើល "សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី ភាគ៦ , គន្លឹះទី៨-ទី៩, "រៀបរៀងដោយក្រុមការងារជប៉ុនដែលទទួល បន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, ឆ្នាំ២០១០ កំនត់ពន្យល់ក្នុងផ្នែកទី១, ទំព័រ១។

សន្តតិជន ឬ អច្ច័យលាភី នៅតែអាចបដិសេធ ទទួលយក សន្តតិកម្ម ឬអច្ច័យទាន ដែលជាចំណែក របស់ខ្លួនចោលបាននៅក្រោយពេលដឹងថា កាតព្វកិច្ច ដែលត្រូវធ្លាក់ មកលើខ្លួនធ្ងន់ធ្ងរពេល។ ឬមួយក៏អាចបដិសេធចោលផងដែរ កាលបើសន្តតិជន ឬ អច្ច័យលាភីនោះពុំមានឆន្ទៈទៅពាក់ព័ន្ធ នឹងមតកសាសន៍នោះ ដោយសារតែមតកសាសន៍នេះគ្រាន់តែជាកិច្ចឯកតោភាគី របស់មតកជនប៉ុណ្ណោះ ដូចនេះ អានុភាពរបស់វាក៏ពុំដាច់ខាតត្រូវតែទទួលយកនោះដែរ។ បដិសេធ ឬលុបចោលចំពោះ សន្តតិកម្ម អាចធ្វើឡើងដោយ សន្តតិជន លើខ្លឹមសារទាំងស្រុង ឬដោយផ្នែកនៃមតកសាសន៍ នៅក្រោយពេល ធ្វើការស្រាវជ្រាវមតិករួចរាល់អស់ ហើយ។ មាត្រា ១២៤៨ និងមាត្រា ១២៦០ នៃក្រម រដ្ឋប្បវេណី ឆ្នាំ២០០៧ បានកំណត់ថិរវេលាឲ្យតែបីខែ ដោយគិតចាប់ពីពេល ដែលបានដឹងថា សន្តតិកម្មចំពោះខ្លួន បានចាប់ផ្តើម។ ប៉ុន្តែថិរវេលានេះអាចពន្យារទៀតបានតាមពាក្យសុំ របស់សន្តតិជននោះទៅស្ថាប័ន តុលាការ។

ចំពោះអច្ច័យលាភីវិញ ក្រមរដ្ឋប្បវេណីបានបែងចែករបបនៃការបដិសេធនេះជាពីរ ទៅតាមប្រភេទនៃអច្ច័យទាន[28]។ បើជាអច្ច័យទានមានកំណត់ ការបោះបង់ដោយអច្ច័យ លាភីមានកំណត់អាចធ្វើឡើងនៅពេលណាក៏បាន ក្រោយពេលម្ចាស់បណ្តាំទទួលមរណភាព[29]។ ប៉ុន្តែបើជាអច្ច័យទានសកល ឬជាអច្ច័យទាន ឲ្យដល់សន្តតិជនវិញនោះ ការបដិសេធរបស់អច្ច័យលាភីសកល[30] ឬរបស់អច្ច័យលាភី ជាសន្តតិជន[31] ត្រូវអនុលោមតាមបញ្ញត្តិនៃការបោះបង់សន្តតិកម្មទៅវិញ។

ទោះជាយ៉ាងណាក៏ដោយ ការបដិសេធ ឬបោះបង់ចោលនូវអានុភាព នៃមតកសាសន៍ នេះ នឹងពុំអាចលុបចោល ទៅវិញតាមទំនើងចិត្តបានទេ[32]។ ហើយការបដិសេធ ឬបោះបង់អានុភាពនៃ មតកសាសន៍នេះសោត នឹងបង្កើតបាននូវអានុភាពប្រតិបត្តិសកម្មមួយ[33]។

---

[28]ត្រង់ចំណុចនេះ សូមអានទៅចំណុចខាងមុខ ស្តីពីៈ "របបអច្ច័យទាន"។

[29]មាត្រា ១២០១ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ចែងថា ៖ "*នៅក្រោយពេលដែលម្ចាស់បណ្តាំបានទទួល មរណភាព អច្ច័យលាភីអាចបោះបង់អច្ច័យទាន នៅពេលណាក៏បាន។ ប៉ុន្តែចំពោះការបោះបង់អច្ច័យទានសកល ត្រូវអនុលោមតាម បញ្ញត្តិស្តីពី ការបោះបង់សន្តតិកម្ម*"។

[30]សូមអានមាត្រា១២០១ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ និងអានចំណុចស្តីពីៈ "របបអច្ច័យទាន"។

[31]សូមអានមាត្រា ១២០៥ នៃក្រម។ តាមមាត្រានេះដែរ បើក្នុងពេលតែមួយ សន្តតិជនម្នាក់ទទួលបានទ្រព្យតាមសន្តតិកម្មផង និងតាមអច្ច័យទានផង នោះការបោះបង់សន្តតិកម្ម នឹងនាំឲ្យ ស្មើនឹងការបោះបង់អច្ច័យទានដែរ។ ប៉ុន្តែមាត្រានេះទទួល ស្គាល់សិទ្ធិបោះបង់អច្ច័យទានចោលដោយរក្សាទុកសន្តតិកម្ម ដែលខ្លួនត្រូវទទួលតាមមតកសាសន៍បាន។

[32]សូមអានមាត្រា១២០៤ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ អំពីការលុបចោលនូវការទទួលស្គាល់ ឬបោះបង់ចំពោះអច្ច័យទាន។ក្រមនេះ ពុំបានបញ្ញត្តិដូចគ្នានេះទេ ចំពោះការបោះបង់របស់សន្តតិជន ប៉ុន្តែក៏ពុំមានហេតុផលណាមួយអនុញ្ញាតឲ្យសន្តតិជនដែលសម្រេចបោះ បង់ចំណែកនៃសន្តតិកម្មរបស់ខ្លួនរួចហើយ អាចលុបចោលវិញនោះដែរ ពីព្រោះថា ការដែលអាចលុបចៅទៅវិញនេះ អាចនឹងធ្វើឲ្យខូចប្រយោជន៍ដល់សន្តតិជនដទៃទៀតផង និងពុំអាចធានាបាននូវការសម្រេចចិត្តបោះបង់មួយដែលពិតប្រាកដផង។

### គ. ការបាត់បង់ទ្រព្យ ឬមរណភាពនៃអត្ថគាហក

ជាគោលការណ៍ នាពេលចាប់ផ្តើមមតកសាសន៍បើទ្រព្យមតិកជាកម្មវត្ថុនៃ មតកសាសន៍នេះត្រូវបានវិនាសបាត់បង់(ទាំងស្រុងឬដោយផ្នែក)ដោយមូលហេតុ ប្រធានសក្តិ ឬបាត់អត្ថិភាព[34] ឬមួយក៏អត្ថគាហកដែលត្រូវទទួលរង នូវអានុភាពនៃមតកសាសន៍នោះ បានទទួលមរណភាព នាពេលចាប់ផ្តើមមតកសាសន៍ ហើយប្រសិទ្ធិភាពនៃមតក សាសន៍នោះក៏ត្រូវបានកាត់បន្ថយ ឬក៏ត្រូវបាត់បង់ទាំងស្រុងទៅតាមនោះដែរ។ ប៉ុន្តែចំពោះ ការស្លាប់នៃអត្ថគាហកនេះ លើកលែងតែម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្ទុយពីនេះ មតកសាសន៍អាចនឹងត្រូវបានចាត់ទុកជាមោឃៈ តែក្នុងករណីដែលអត្ថគាហក ពុំមានសន្តតិជន តាមច្បាប់សម្រាប់ទទួលបន្តសិទ្ធិនេះប៉ុណ្ណោះ ពីព្រោះថាក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានចែងច្បាស់អំពីសិទ្ធិទទួលបន្តនៃសន្តតិជនជំនួស (ចំពោះករណីមរណភាពរបស់សន្តតិជន នៃ មតកជន) និងអំពីសិទ្ធិ ទទួលបន្តនៃសន្តតិជនរបស់អច្ច័យលាភី (ចំពោះករណីមរណភាព នៃអច្ច័យលាភី)[35]។

ចំពោះករណីនៃមរណភាពរបស់អច្ច័យលាភីនេះ យើងគប្បីបែងចែកជាពីរពោលគឺ៖ ក្នុងករណីដែលអច្ច័យលាភី ស្លាប់ទៅមុន ឬព្រមពេលគ្នាជាមួយមរណភាពរបស់មតកជន និងក្នុងករណី ដែលអច្ច័យលាភីស្លាប់ក្រោយមរណ ភាពរបស់មតកជន។ ករណីទីមួយបញ្ជាក់ថា អច្ច័យទាននោះ ពុំអាច

[33]សូមអានមាត្រា ១២៦១ ថ្មីនៃក្រមរដ្ឋប្បវេណីឆ្នា២០០៧ ចំពោះសន្តតិកម្ម និងមាត្រា១២០១កថាខណ្ឌទី២ ចំពោះអច្ច័យទាន។ អានុភាព ប្រតិសកម្មនេះ មានន័យថា ចាប់ពីពេលដែលសន្តតិជន ឬអច្ច័យលាភីសម្រេចបោះបង់សន្តតិកម្ម ឬអច្ច័យទាននោះមកនឹងចាត់ទុកថាគាត់បាត់គុណភាពជាសន្តតិជន ឬជាអច្ច័យលាភី តាំងតែពីមុនមានមតកសាសន៍នេះទៅទៀត។

[34]សូមអានមាត្រា ១២០៥ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ អំពីការលុបចោលនូវការទទួលស្គាល់ ឬបោះបង់ ចំពោះអច្ច័យទាន។ ត្រង់នេះពុំបានបញ្ញត្តិដូចគ្នានោះទេ ចំពោះការបោះបង់របស់សន្តតិជន ប៉ុន្តែពុំមានហេតុផលណាមួយ អនុញ្ញាតឲ្យសន្តតិជនដែលសម្រេចបោះបង់ចំណែកនៃសន្តតិកម្មរបស់ខ្លួនរួចហើយ អាចលុបចោលវិញនោះដែរ ពីព្រោះថា ការដែលអាចលុប ចោលទៅវិញនេះ អាចនឹងធ្វើឲ្យ ខូចប្រយោជន៍ដល់សន្តតិជនដទៃទៀតផង និង ពុំអាចធានាបាន នូវការសម្រេចចិត្តបោះបង់មួយដែលពិតប្រាកដផង។

[35]សូមអានមាត្រា១១៩៦ និងមាត្រា១២០០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។ ដូចដែលមាត្រា១២០០ បញ្ជាក់ច្បាស់ការទទួលស្គាល់ណាមួយចំពោះសិទ្ធិអាចទទួលឬបដិសេធចោលនូវអច្ច័យទាន ដោយសន្តតិជននៃអច្ច័យលាភីនាកាលដែលអច្ច័យលាភីនោះបានទទួឡមរណភាពសំដៅតែក្នុងករណីដែលអច្ច័យលាភីរូបនោះរួចរាល់អស់ហើយដូចនេះអាចចាត់ចែងបន្តទៅសន្តតិជននៃអច្ច័យលាភីនោះបាន។ តែផ្ទុយមកវិញបើមរណភាពនៃអច្ច័យលាភីនៅមុនមរណភាពនៃមតកជនវិញគឺពុំអាចទទួលយកបានឡើយពីព្រោះថាការផ្ទេរទ្រព្យពីមតកជនពុំត្រូវបានធ្វើដោយមតកជនពុំទាន់ស្លាប់ហើយអច្ច័យទានទៀតសោតគឺ ត្រូវបានប្រដូចនឹងករណីនៃប្រទានកម្មត្រង់ការគិតដល់គុណភាពបុគ្គលដែលជាអត្ថ គាហកជាសំខាន់។ដូចនេះ រាល់ការដែលអនុញ្ញាតឲ្យសន្តតិជននៃអច្ច័យលាភីទទួលបានសិទ្ធិណាមួយលើអច្ច័យទាន(លើកលែងតែអច្ច័យលាភីនោះជាសន្តតិជន) នឹងនាំឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់សិទ្ធិរបស់សន្តតិជននៃមតកជនផងនិងដល់ឆន្ទៈធ្វើទានរបស់មតកជនផ្ទាល់ផង។

បង្កើតអានុភាពឡើយព្រោះមតកសាសន៍ មានអានុភាព ទៅបានលុះណាមតកជនស្លាប់[36]។ ផ្ទុយទៅវិញ ករណីទីពីរ បញ្ជាក់ថា អច្ច័យទាននោះ ទៅឲ្យសន្តតិជននៃ អច្ច័យលាភីនោះ ប៉ុណ្ណោះ[37]។ ទោះបីជាការកំណត់បែបនេះ ហាក់ដូចជាសមហេតុផលក៏ដោយចុះ ក៏ប៉ុន្តែដោយសារតែ អច្ច័យទាននេះ ត្រូវបានទទួលស្គាល់ថា ដូចគ្នានឹងប្រទានកម្មត្រង់គោលដៅនៃឆន្ទៈក្នុងការធ្វើអំណោយរបស់មតកជន ពោលគឺជាកិច្ច គតិយុត្តមួយដែលផ្តោតសំខាន់ទៅលើគុណភាពនៃបុគ្គល (លើទំនាក់ទំនងផ្ទាល់ខ្លួនរវាង មតកជន និង អច្ច័យលាភីនោះ) ដូចនេះ មរណភាពនៃអច្ច័យលាភី គប្បីត្រូវទុកអច្ច័យទាននោះ ជាមោឃដែរ ហើយផ្ទេរអច្ច័យទាន នោះចូលក្នុងទ្រព្យមតិករបស់មតកជនវិញដើម្បីជា ប្រយោជន៍ដល់សន្តតិជន នៃមតកជននោះ ពីព្រោះថា សន្តតិជននៃ អច្ច័យលាភី ពុំមានគុណភាពតាមឆន្ទៈនៃមតកជនឡើយ។ ហេតុនេះការទទួលស្គាល់សិទ្ធិបន្ត លើអច្ច័យទាន ណាមួយ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧[38] ទៅឲ្យសន្តតិជន នៃអច្ច័យលាភីនោះ ទុកដូចជា ការរំលោភធ្ងន់ធ្ងរមួយ ចំពោះឆន្ទៈនៃ មតកជនដែរ។

---

[36]ក្នុងន័យនេះ កថាខណ្ឌទី១ នៃមាត្រា១២០០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ចែងថា៖ "អច្ច័យទាន ពុំបង្កើតអានុភាពឡើយ បើអច្ច័យលាភីបាន ទទួលមរណភាពនៅមុខ ឬក្នុងពេលដែលម្ចាស់បណ្តាំទទួលមរណភាព។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអច្ច័យ ទានភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ ហើយអច្ច័យលាភីបានទទួល មរណភាពនៅមុនពេលដែលល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញ"។

[37]សូមមើល "សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីភាគ ៦ , គន្ថីទី៨ -ទី៩", រៀបរៀងដោយក្រុម ការងារជប៉ុនដែលទទួល បន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី ឆ្នាំ២០១០ កំណត់ពន្យល់ចំពោះមាត្រា ១២០៣ ទំព័រ៦៥។

[38] មាត្រា១២០៣ នៃក្រម ចែងថា៖ "បើអច្ច័យលាភីបានទទួលមរណភាព ដោយមិនបានទទួលស្គាល់ឬបោះបង់អច្ច័យទានទេ សន្តតិជនរបស់ អច្ច័យលាភីនោះ អាចទទួលស្គាល់ឬបោះបង់អច្ច័យទានបាន ត្រឹមទំហំនៃសិទ្ធិលើសន្តតិកម្មរបស់ខ្លួន" និង សូមអាន "សេចក្តីកំណត់ចំពោះ មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦ , គន្ថីទី៨ -ទី៩ ",រៀបរៀងដោយក្រុមការងារជប៉ុន ដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, ឆ្នាំ២០១០ , កំណត់ពន្យល់ចំពោះមាត្រា១២០៣, ទំព័រ៦៥។

## ផ្នែកទី២
## ល័ក្ខខ័ណ្ឌចាំបាច់ជានម្រង់នៃការបង្កើត

បើទោះជាច្បាប់តម្រូវឲ្យមតកជនសម្តែងនូវឆន្ទៈពិតប្រាកដក៏ដោយ ក៏ពុំមែនមានន័យថា ការណ៍នេះមាន លក្ខណៈគ្រប់គ្រាន់ ដើម្បីអាចធ្វើឲ្យមតកសាសន៍នោះមានសុពលភាពពេញលេញដើម្បី ដោយហេតុថា មតកសាសន៍គឺជាលិខិតឪឡារិក[39] ពោលគឺលិខិតដែលត្រូវតែគោរពតាម ទ្រង់ដែលច្បាប់កំណត់ច្បាស់លាស់ឯការមិនគោរពទម្រង់នេះនឹងនាំឲ្យមានទណ្ឌកម្មដែលជាកម្មវត្ថុនៃ ការប្រកាសមោឃភាព[40]។ ចម្ងល់អាចនឹងត្រូវចោទឡើងថា តើហេតុអ្វី បានជាបាច់ត្រូវគោរពតាមទម្រង់យ៉ាងដូច្នេះ? ចម្លើយ ស្ថិតនៅត្រង់ថា មតកសាសន៍នេះ គឺជាលិខិតដែលនឹងបង្កើត អានុភាព តែនៅបន្ទាប់ពី មរណភាព របស់មតកជនប៉ុណ្ណោះ ហេតុនេះបើពេលនោះមានបញ្ហាចោទឡើង ណាមួយទាក់ទងនឹងភាពពិតប្រាកដ នៃឆន្ទៈរបស់មតកជននោះ គេពិបាកនឹងបង្ហាញភស្តុតាងឲ្យបានច្បាស់អំពីភាពពិតប្រាកដនេះ ណាស់ ព្រោះតែម្ចាស់ដើមនៃឆន្ទៈបានទទួលមរណភាពបាត់ទៅហើយ។ គឺក្នុងក្តីបារម្ភនេះហើយ ដែលជម្រុងឲ្យ អ្នកធ្វើ ច្បាប់តម្រូវឲ្យមានការគោរពតាមជាចាំបាច់ នូវទម្រង់កំណត់ជាក់លាក់ សំដៅធានាឲ្យបានជា អតិបរមា និងជាសត្យានុម័ត នូវឆន្ទពិតប្រាកដរបស់ម្ចាស់បណ្តាំ។ តាមពិតទៅ ការតម្រូវណាមួយក៏ដោយ ចំពោះល័ក្ខខ័ណ្ឌជាទម្រង់នៃលិខិត នេះសុទ្ធតែមានគោលដៅចង់ស្តែងឲ្យ ដឹងច្បាស់លាស់ពី ភាពពិតប្រាកដ

[39]មានវិធានធំៗពីរដែលមានឥទ្ធិពលខ្លាំងមកលើមតកសាសន៍គឺ៖ ឪឡារិកនិយម និង បុគ្គលនិយម។ ឪឡារិក និយមតម្រូវឲ្យមតកសាសន៍ត្រូវ តែជាលិខិតសរសេរ (ផ្ទាល់ដៃ ឬដោយមន្ត្រីសារការី)ចុះថ្ងៃខែឆ្នាំ និងចុះហត្ថលេខា។ល។ រីឯវិធាននៃបុគ្គលនិយមវិញ តម្រូវឲ្យមតកសាសន៍ ត្រូវតែធ្វើឡើងដោយឆន្ទៈនៃបុគ្គលតែម្នាក់គត់ និងប្រើប្រាស់ សម្រាប់ ជាប្រយោជន៍តែបុគ្គលម្នាក់នោះប៉ុណ្ណោះ (មតកជន)។ ហេតុនេះ ទើប មានច្បាប់ប្រទេសខ្លះ បានប្រកាសហាមឃាត់ មតកសាសន៍ដែលធ្វើឡើងដោយសហព័ទ្ធរួមគ្នា។

[40]មាត្រា១១៧០កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ចែងថា៖ "មតកសាសន៍ដែលធ្វើមិន ត្រូវនឹងទម្រង់ ណាមួយក្នុងបញ្ញត្តិនៃក្រមនេះ ត្រូវចាត់ទុកជាមោឃៈ។ ទោះបីជាមានការរឹតបន្តឹងចំពោះទម្រង់នៃមតកសាសន៍នេះយ៉ាងណាក៏ដោយក៏ក្រមថ្មីទុកលទ្ធភាពឲ្យសុពលភាពនៅ តែមានដដែល បើទោះជាមតកសាសន៍នោះធ្វើឡើងពុំគោរពតាមទម្រង់កំណត់ក៏ដោយ គ្រាន់តែសុពលភាពនេះប្រែប្រួលទៅតាមទម្រង់ដែល លិខិតនេះរណប៉ុណ្ណោះ(ឧទាហរណ៍ ម្ចាស់បណ្តាំចង់ធ្វើមតកសាសន៍តាមទម្រង់នៃលិខិតសម្ងាត់ ប៉ុន្តែក្រោមមរណភាពនៃមតកជន គេពិនិត្យ ឃើញថា លិខិតដែលធ្វើនេះ ពុំគោរពតាម ទម្រង់នៃលិខិតសម្ងាត់នោះទេ តែបែរជាត្រឹមត្រូវតាមទម្រង់នៃលិខិតឯកជនទៅវិញ។ ដូចនេះ មតកសាសន៍នេះ នៅតែមានសុពលភាពតាមទ្រង់នៃលិខិតឯកជនដដែល បើទោះជាមតកជនបានបញ្ជាក់ថា ជាលិខិតសម្ងាត់ក៏ដោយ។ នេះបើតាមមាត្រា១១៧១ នៃក្រមថ្មី)។

នៃឆន្ទៈរបស់ម្ចាស់បណ្តាំប៉ុណ្ណោះ[41]។ ក្នុងគោល ដៅនេះហើយ ទើបមតកសសាសន៍ត្រូវបានច្បាប់តម្រូវឲ្យធ្វើឡើង ក្រោមទម្រង់ប្លែកៗគ្នាយ៉ាងច្រើន។ ជាទ្រឹស្តី និង តាមស្មារតីនៃក្រមរដ្ឋប្បវេណីថ្មី ឆ្នាំ ២០០៧ យើងអាចបែងចែកទម្រង់នៃមតកសាសន៍នេះជាពីរប្រភេទ ខុសគ្នាអាស្រ័យទៅតាម ស្ថានភាពជាក់ស្តែង នៃមតកជននាកំឡុងពេលធ្វើលិខិតពោលគឺ ៖ ទម្រង់ធម្មតា **(កថាខណ្ឌទី១)** និង ទម្រង់ ពិសេស **(កថាខណ្ឌទី២)**។

**កថាខណ្ឌទី១៖ ទម្រង់នៃមតកសាសន៍ក្នុងស្ថានភាពធម្មតា**

ស្ថិតក្នុងស្ថានភាពធម្មតាមានន័យថា មតកជនស្ថិតក្នុងស្ថានភាពមួយ ដែលអាចសម្តែងឆន្ទៈ របស់ខ្លួនតាម សម្រួល និងអាចគោរពបានតាមនីតិវិធីចាំបាច់នានាដែលច្បាប់បានតម្រូវ ព្រមទាំងមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការជ្រើសរើសវិធីធ្វើមតកសសាសន៍ តាមដែលខ្លួនពេញចិត្ត។ ក្នុងករណីនៃស្ថានភាពធម្មតានេះមតកសាសន៍អាចត្រូវបាន ធ្វើឡើងក្រោម ទម្រង់ណាមួយនៃទម្រង់ តែបីយ៉ាងគត់[42]៖ ជាលិខិតយថាភូត **(ក)** ឬជាលិខិតឯកជន **(ខ)** ឬក៏ជាលិខិតសម្ងាត់ **(គ)**។ តាមរយៈការទទួល ស្គាល់នូវទម្រង់ទាំងបីរបស់ច្បាប់នេះមានន័យថា មតកជនអាចជ្រើសរើសយក ទម្រង់ណាមួយក៏បាន ក្នុងពេលគាត់តែងមតកសាសន៍របស់ខ្លួន។

**ក..មតកសាសន៍ដោយលិខិតយថាភូត**

លិខិតយថាភូត[43] គឺជាទម្រង់មួយដែលអាចទុកចិត្តបានបំផុតដោយហេតុថា មតកសាសន៍តាមទម្រង់នេះជា លិខិតដែលធ្វើឡើងតាម រូបមន្តច្បាប់ដោយមានវត្តមានមន្ត្រីសាធារណៈ មានវិជ្ជាជីវៈច្បាស់

---

[41]សូមអានសៀវភៅរបស់ Philippe MALAURIE មានចំណងជើងថា៖ << Les successions, Les liberalites>>បោះពុម្ពដោយ Edition Defrenois, ឆ្នាំ២០០៣, ទំព័រ៤៨។

[42]គួរកត់សម្គាល់ដែរថា ក្រមរដ្ឋប្បវេណីសង្គមចាស់ (ឆ្នាំ១៩៦៧ របស់ អេង សុត) ទទួលស្គាល់ត្រង់មាត្រា ៥៥៥ នៃក្រមតែទម្រង់ពីរ ប៉ុណ្ណោះ គឺទម្រង់នៃលិខិតយថាភូត(ក្រមហៅថា "សំបុត្របណ្តាំមានបញ្ជាក់") និងទម្រង់នៃលិខិតឯកជន (សំបុត្រឯកជន)។ ចំណែកឯក្រមថ្មី ឆ្នាំ២០០៧វិញ បានបន្ថែមទម្រង់ថ្មីមួយទៀតគឺ លិខិតសម្ងាត់នេះ។ តែទោះជាយ៉ាងណាក៏ដោយ ទម្រង់ទាំងបីនេះ គេឃើញមាតវត្តមានក្នុង ច្បាប់អឺរ៉ុប ពិសេសច្បាប់បារាំង តាំងពីយូរយាណាស់មកហើយ។ បទពិសោធន៍ប្រទេសបារាំង អាចឲ្យយើងដឹងបានថា ក្នុងចំណោមទម្រង់ ទាំងបីនេះមានតែលិខិតឯកជន មួយទេដែលធ្លាប់បានប្រើប្រាស់ ក្នុងការអនុវត្តន៍ ញឹកញាប់ផុត។ ឯលិខិតយថាភូតគឺកម្រនឹងត្រូវបានគេជ្រើស រើសមកប្រើណាស់។ ធ្ងន់ធ្ងរជាងនេះទៅទៀត លិខិតសម្ងាត់ បែរជាពុំធ្លាប់ត្រូវបានប្រើប្រាស់ទាល់តែសោះ(សូមអានសៀវភៅរបស់ Philippe MALAURIE មានចំណងជើងថា៖ << Les successions, Les liberalites>>, បោះពុម្ពដោយ Edition Defrenois, ឆ្នាំ២០០៣, ទំព័រ២៤៧)។ ដូចនេះ តើការចម្លងតាមច្បាប់បរទេសនូវទម្រង់ទាំងបីនេះមកប្រើប្រាស់ក្នុងសង្គមខ្មែរ អាចមានប្រសិទ្ធិភាពឬទេ?

[43]សូមអានមាត្រា ១១៧៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

លាស់ផង[44] និងសាក្សីចូល រួមបញ្ជាក់ ពីភាពពិតប្រាកដនៃលិខិតផង។ ដូចនេះទម្រង់នេះ ជាទម្រង់នៃភស្តុតាងដ៏ខ្លាំងក្លាបំផុត ដែលនេះហើយ ជាគុណសម្បត្តិតែមួយគត់នៃទម្រង់នេះ។ តើទម្រង់នេះ ត្រូវតាក់តែងយ៉ាងដូចម្តេច?

ក្នុងការធ្វើមតកសាសន៍ដោយលិខិតយថាភូត មតកជនត្រូវប្រាប់ នូវរាល់ខ្លឹមសារនេះ គឺជាការនិយាយប្រាប់ សហការី នូវខ្លឹមសារនៃបណ្តាំដែលមតកជនបានព្រាងទុក ដើម្បីឲ្យសារការីធ្វើការ បញ្ចូលខ្លឹមទាំងនោះ ទៅក្នុងលិខិត ជាទម្រង់យថាភូត ឲ្យមានន័យនិងគុណភាពតាមផ្លូវច្បាប់ ដូចនឹងលិខិតសាធារណៈដែរ។

ចំពោះគុណភាពនៃសាក្សីវិញ ពុំមែនគ្រប់បុគ្គលិកទាំងអស់ សុទ្ធតែអាចចូលរួម ធ្វើជាសាក្សីនៃលិខិតតាមទម្រង់នេះឡើយ។ ច្បាប់តែងកម្រិតលក្ខខ័ណ្ឌ ចំពោះបុគ្គលិកមួយចំនួន មិនបានទទួលគុណភាពជាសាក្សីនេះឡើយ ដោយឈរលើមូលដ្ឋាន នៃការធានានូវគុណភាពនៃសក្ខីកម្ម។ បុគ្គលទាំងនោះរួមមាន ៖ ជនដែលមានទំនាក់ទំនងកំណត់ជាមួយនឹងជន ដែលត្រូវជនដែលសន្មតថាជាសន្តតិជន.អតិជន ឬជាជននៅក្រោមអាណាព្យាបាលធម្មតា, ជនដែលត្រូវសន្មតថាជាសន្តតិជន ឬជាអច្ច័យលាភី ឬជាសហព័ន្ធ ឬមួយជាញាតិលោហិតខ្សែផ្ទាល់របស់ជនទាំងនោះ។ ការហាមឃាត់ជនទាំងនេះ ក៏ព្រោះតែជនទាំងនេះ សុទ្ធសឹងជាអ្នកដែល មានផលប្រយោជន៍ផ្ទាល់ ពាក់ព័ន្ធនឹងមតកសាសន៍ ហើយដែលអាចនាំឲ្យប៉ះពាល់ផងដែរ ដល់សុក្រិត្យភាពក្នុងការធ្វើជាសក្ខីកម្មនានា។ដូចគ្នាដែរ ក្នុងករណីដែលសារការីជាជនពាក់ព័ន្ធផ្ទាល់ក្នុងការធ្វើមតកសាសន៍ នោះសហព័ន្ធ ឬញាតិលោហិតផ្ទាល់ ឬក្រឡាបញ្ជី ឬក៏និយោជិតរបស់សាការីរូបនោះត្រូវបានចាត់ទុកថាជាជនដែលខ្វះលក្ខណៈសម្បត្តិជាសាក្សីផងដែរ[45]។

បន្ទាប់ពីបានកត់ត្រានៃក្លឹមសារនៃមតកសាសន៍រួចរាល់ហើយ សាក្សីត្រូវតែសូត្រឲ្យខ្លាំងៗ ឲ្យដល់ម្ចាស់បណ្តាំ និងសាក្សីស្តាប់។ ម្ចាស់បណ្តាំ និងសាក្សីត្រូវធ្វើការទទួលស្គាល់ ឬបដិសេធនូវភាព ត្រឹមត្រូវចំពោះអត្ថន័យនៃមតកសាសន៍ ដែលសរសេរសាការី រួចត្រូវសរសេរឈ្មោះ អាយុ លំនៅស្ថាន និងចុះហត្ថលេខារៀងៗខ្លួន លើលិខិតយថាភូតនោះ[46]។ បន្ទាប់មក សារការីត្រូវសរសេរឈ្មោះ អាយុលំនៅស្ថាន និងចុះហត្ថលេខារបស់ខ្លួនលើលិខិតនោះ ទុកជាការស្រេច ចំពោះទម្រង់នៃយថាភូតនេះ ។

---

[44]មន្ត្រីសាធារណៈមានវិជ្ជៈ ក្នុងន័យនេះសំដៅដល់មន្ត្រីសាការីនេះឯក។ ពាក្យ " សារការី" នេះមានន័យថាជាមន្ត្រីសាធារណៈដែលមានមុខ ងារធ្វើលិខិតយថាភូតបញ្ជាក់អំពីលក្ខណៈពិតប្រាកដត្រឹមត្រូវ ធានារ៉ាប់រងអំពីកាលបរិច្ឆេទ រក្សាទុក និងចេញសេចក្តីចម្លងយថាភូតនៃលិខិត ទាំងឡាយដែលត្រូវតែឲ្យមានការបញ្ជាក់(យោងតាមសទ្ទានុក្រម ផ្នែករដ្ឋប្បវេណីឆ្នាំ២០០៧)។

[45]សូមមើលមាត្រា ១១៧២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

[46]ប្រសិនបើម្ចាស់បណ្តាំមិនអាចសរសេរ ឬចុះហត្ថលេខាបានទេ សាការីអាចជំនួសការសរសេរ និងហត្ថលេខា ដោយសរសេរ

យ៉ាងណាមិញ ទម្រង់យថាភូតនេះ ក៏អាចមានគុណវិបត្ត ចំពោះមតកសាសន៍ផងដែរ ។កាលបើសម្រេចជ្រើសរើសទម្រង់នេះហើយ មតកជនត្រូវចំណាយសោហ៊ុយច្រើន ឲ្យដល់មន្ត្រីសាការី ដែលប្រហាក់ប្រហែលទៅនិងការជួលមេធាវីដែរ។ ម្យ៉ាងទៀត ការដែលតម្រូវឲ្យមានវត្តមានតតិជន ដូចជាសាការី និងពិសេសគឺសាក្សី នឹងនាំឲ្យភាពអាចទុកជាសម្ងាត់បាននៃមតកសាសន៍ ត្រូវកាត់បន្ថយ ទម្រាំដល់ ពេលស្លាប់នៃមតកជននោះ។ ដើម្បីជៀសផុតពីគុណវិបត្តិនេះហើយ ទើបទម្រង់នៃលិខិតឯកជនតែងជាជម្រើសញឹកញាប់បំផុត ។

**ខ. មតកសាសន៍ដោយលិខិតឯកជន**

មតកសាសន៍ដោយលិខិតឯកជន[47] ជាទម្រង់ដែលប្រើជាញឹកញាប់បំផុត ព្រោះជាតម្រង់ដែល ដ៏សាមញ្ញ និង ងាយស្រួលោបំផុត។ តាមទម្រង់នេះ ម្ចាស់បណ្ដាំត្រូវសរសេរនូវ រាល់អត្ថន័យទាំងអស់ ដែលខ្លួនប្រាថ្នាសំដែងឆន្ទះ រួចត្រូវចុះថ្ងៃ ខែ ឆ្នាំ និងត្រូវចុះហត្ថលេខាដោយ មេដៃឯងផ្ទាល់[48] រាល់ល័ក្ខខ័ណ្ឌតម្រូវទាំងឡាយនៃលិខិតប្រភេទនេះ សុទ្ធតែពុំមានភាពស្មុកស្មាញសស៊ាំញុំាឡើយ ហើយអាចជួយ ដល់មតកជន ក្នុងការរក្សាភាពសម្ងាត់នៃខ្លឹមសាររបស់មតកសាសន៍បានយ៉ាងល្អទៀតផង ។ ក៏ប៉ុន្តែរាល់ការមិនបំពេញនូវល័ក្ខខ័ណ្ឌណាមួយដូចបានកំណត់ខាងដើម សុទ្ធតែអាចជាមូលហេតុ នៃមោឃភាពដល់មតកសាសន៍ទាំងអស់[49]។ ជាក់ស្តែងបើមតកសាសន៍ ត្រូវបានសរសេរដោយអ្នក ដ៏ទៃ ដែលពុំមានមតកជន ឬដោយម៉ាស៊ីនណាមួយ ពោលគឺដោយមិនផ្ទាល់ដៃរបស់ មតកជនមតកសាសន៍ នោះ នឹងត្រូវចាត់ទុកជាមោឃៈ[50]ពីព្រោះថានៅពេលក្រោយមរណភាព នៃមតកជនបើមានបញ្ហាទាក់ទង នឹងសូក្រិតភាព នៃមតកសាសន៍កើតឡើង នោះគេពិបាកនឹងបញ្ជាក់ ឲ្យបានច្បាស់ថា តើ មតកសាសន៍ នោះពិត

ឈ្មោះ អាយុ និងទិលំនោឋានរបស់ជននោះ ហើយត្រូវសរសេរបន្ថែមនូវហេតុនោះផង។

[47]សូមអានមាត្រា១១៧៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ។

[48]សម្រាប់មតកសាសន៍ដោយទម្រង់នៃលិខិតឯកជននេះ ចាំបាច់ត្រូវតែគោរពតាម ដោយមិនអាចខ្វះបាននូវល័ក្ខខ័ណ្ឌតម្រូវទាំងបីនេះគឺការសរសេរដោយផ្ទាល់ដៃនៃមតកជន ការចុះថ្ងៃ ខែ ឆ្នាំ និងចុះហត្ថលេខា។ លិខិតណាមួយដែលមិនដែលមិនគោរពនូវល័ក្ខខ័ណ្ឌមួយចំណោមល័ក្ខខ័ណ្ឌទាំងបីនេះទេ នឹងត្រូវទុកជាមោឃៈ។ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ពុំបានបញ្ជាក់ឲ្យច្បាស់ពីចំនុចនេះឡើយ ប៉ន្តែមោឃៈភាពនេះ ត្រូវបានទទួលស្គាល់រួចដោយយុត្តិសាស្ត្រនៃតុលាការបារាំង(សូមអានសៀវភៅរបស់ Philippe MALAURIE មានចំណងជើងថា៖ *"Les successions, Les lberalites"* បោះពុម្ពដោយ Edition Defrenois, ឆ្នាំ ២០០៧. ទំព័រ២៥១ ដល់ ២៥០ ) ។ ដូចនេះហើយ ទើបអ្នកច្បាប់មួយចំនួនបានចាត់ទុកជាមតកសាសន៍តាមទម្រង់នេះ ថាមិនមែនជាលិខិតឯកជនធម្មតានោះឡើយ (លិខិតឯកជនឌីឡូរិក?) ។

[49]សូមអានសៀវភៅរបស់ Philippe MALAURIE មានចំណងជើងថា៖ *"Les successions, Les lberalites"* បោះពុម្ពដោយ Edition Defrenois, ឆ្នាំ២០០៣, ទំព័ទី ២៥២ ។

[50]យុត្តិសាស្ត្របារាំងធ្លាប់បានប្រកាសមោឃៈភាពដោយមូលហេតុនេះរួចហើយ (Cass. civ ,. 18 mai 1936 ) ។

ជាធ្វើឡើងដោយម្ចាស់បណ្តាំប្រកដមែន ឬយ៉ាងណានោះទេ ។ ដូចគ្នាដែរ ករណីដែលតម្រូវឲ្យ សរសេរឡើងដោយដៃផ្ទាល់របស់មតកជន ក៏គង់មានគោលដៅផ្ទៀងផ្ទាត់ មើលអក្សរ តាមរយៈ ការប្រៀបធៀបមតកសាសន៍ នឹងអក្សររបស់មតកជន រូបនោះ ដែលបានសរសេរលើលិខិតផ្សេងៗ កាលពីនៅរស់។ ដូចគ្នានេះដែរដោយហេតុថាអាចមានករណីនៃការផ្លាស់ប្តូរខ្លឹមសារណាមួយជាយហេតុ ក្នុងមតកសាសន៍ ដូចការសរសេរបន្ថែម ឬ លុបចោលនៅពាក្យពេចន៍ខ្លះៗជាដើម ទើបច្បាប់តម្រូវឲ្យមាន ការសរសេរបញ្ជាក់ជាចាំបាច់ ចំពោះការផ្លាស់ទាំងនេះ ហើយចាំបាចផងដែរ ត្រូវតែចុះហត្ថលេខា ដើម្បី បញ្ជាក់មើលដោយប្រៀបធៀបនឹងលិខិតផ្សេងៗ ថាការផ្លាស់ប្តូរនេះ ពិតជាត្រូវបានធ្វើឡើងដោយសាមីខ្លួន មែនឬទេ[51]។

បើទោះបីជាទម្រង់នេះ មានភាពងាយស្រួលមិនស៊ាំញុំ ហើយអនុញ្ញាតឲ្យម្ចាស់បណ្តាំចំណាយសោហ៊ុយថោក ក្នុងការតាក់តែងលិខិត និងអាចរក្សាខ្លឹមសារជាសម្ងាត់នៃលិខិតបាន (ដែលនេះផ្ទុយស្រឡះ ពីការរត់ទៅរកមន្ត្រីសារការីសម្រាប់ទម្រង់យថាភូត) ក៏ពិតមែន ក៏ប៉ុន្តែទម្រង់នេះសោត ក៏មានហានិភ័យខ្ពស់ផងដែរ ដូចជា៖ អាចប្រឈមនិងមោឃភាពលើទម្រង់ខ្ពស់ អាចប្រឈមនឹងភាព មិនច្បាស់លាស់នៃខ្លឹមសារខ្ពស់ព្រមទាំង នាក្រោយមរណភាពរបស់មតកជននោះ អាចប្រឈមនឹងការវិនាស បាត់បង់ទៅនៃលិខិតផងដែរ។ ដូច្នេះហើយ ទើបអ្នកនីតិបញ្ញត្តិ បានបង្កើតឲ្យមានឡើង នូវទម្រង់ទីបី នៃមតកសាសន៍ ដែលជាលិខិតចម្រុះគ្នារវាងលិខិតយថាភូត និងលិខិតឯកជន ក្នុងបំណង់កាត់បន្ថយឲ្យ បានជាអតិបរមា នូវហានិភ័យទាំងឡាយ ដែលកើតពីលិខិតទាំងពីរនេះ ។ ទម្រង់ទីបីនេះហៅលិខិតសម្ងាត់។

**គ. មតកសាសន៍ដោយលិខិតសម្ងាត់**

មតកសាសន៍ដោយលិខិតសម្ងាត់ គឺជាទម្រង់មួយ ដែលអនុញ្ញាតឲ្យអ្នកចេះសរសេរអក្សរ អាចធ្វើមតកសាសន៍របស់ខ្លួនដោយរក្សាខ្លឹមសារនោះជាសម្ងាត់ទាំងស្រុង។ ដូចនេះ គេអាចការពារ កុំឲ្យមានការលុបចោល ឬលួចកែប្រែ ដោយអតិជនបាន ។

មតកសាសន៍តាមលិខិតសម្ងាត់នេះ[52] អាចត្រូវបានសរសេរដោយជនដទៃ ឬដោយម៉ាស៊ីន ក៏បាន។ ចំនុចសំខាន់ គឺត្រង់ថា ម្ចាស់បណ្តាំត្រូវចុះហត្ថលេខាលើលិខិតនោះ ជាដាច់ខាត។ ម្ចាស់បណ្តាំត្រូវដាក់លិខិតនោះក្នុងស្រោមបិទជិត ហើយត្រូវចុះហត្ថលេខា ឬសរសេរសញ្ញាសម្គាល់ ឬមធ្យោបាយផ្សេងៗទៀតដែលអាចវិនិច្ឆ័យបាន អំពីការបានបើក ឬមិនបានបើកស្រោមលិខិតនេះ នៅមាត់ស្រោម

[51]សូមមើលកថាខណ្ឌទី០២ នៃមាត្រា១១៧៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ។

[52]សូមអានមាត្រា១១៧៥នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

លិខិតនោះ។ ម្ចាស់បណ្តាំ ត្រូវដាក់លិខិតដែលបានបិទជិតនោះ នៅចំពោះមុខមន្ត្រីសារការីម្នាក់ និងសាក្សីពីរអ្នក ព្រមទាំងធ្វើសេចក្តីថ្លែងការណ៍ថាលិខិតនេះ ជាលិខិតមតកសាសន៍របស់ខ្លួន ហើយបើមានជនក្រៅពីសម័យខ្លួនបានសរសេរត្រូវសេចក្តី ថ្លែងការណ៍អំពីឈ្មោះ និងស្ថានភាពរបស់ជនដែលបានសរសេរនោះ ។សារការីត្រូវចុះថ្ងៃ ខែ ឆ្នាំដែលសាមីខ្លួនបានដាក់លិខិតនោះ ជាមួយគ្នានឹងសាក្សី ព្រមទាំងម្ចាស់បណ្តាំផងដែរ ។

ក្នុងការណីដោយឡែកមួយទៀត ដោយគិតដល់ស្ថានភាពនៃលទ្ធភាពរបស់ម្ចាស់បណ្តាំផ្ទាល់ ក្នុងការតាក់តែងលិខិតបណ្តាំនេះផង និងការកែតម្រូវឲ្យគាត់ត្រូវតែគោរពតាមល័ក្ខខ័ណ្ឌបន្ថែមផង ទើបច្បាប់បានបង្កើតឲ្យមានទម្រង់ជាពិសេសដោយឡែកសម្រាប់មតកជនប្រភេទនេះ ។ ប៉ុបន្តែការណ៍នេះពុំមានន័យថា ៖ មតកជនក្នុងស្ថានភាពនេះ មានបញ្ហាស្មាតីដែលអាចប៉ះពាល់ដល់គុណនៃឆន្ទះ ដូចក្នុងករណីនៃជននៅក្រោមអណាព្យាបាលនោះឡើយ[53] ។

## កថាខ័ណ្ឌទី២ ទម្រង់នៃមតកសាសន៍ក្នុងស្ថានភាពពិសេស

នៅក្នុងទម្រង់ធម្មតា ម្ចាស់បណ្តាំចូលរួមក្នុងការចូលរួមក្នុងរៀបចំ មតកសាសន៍ដោយផ្ទាល់ខ្លួនតាមទម្រង់ណាមួយដែលជ្រើសរើស ដូចជាការសរសេរដោយផ្ទាល់ដៃខ្លួនឯង និងចុះហត្ថលេខាលើលិខិតនោះ ឬក៏ប្រាប់ដោយផ្ទាល់មាត់នៅខ្លឹមសារនៃមតកសាសន៍ដល់សារការិជាដើម[54]។ ផ្ទុយទៅវិញ ទម្រង់ពិសេសដែលត្រូវបានប្រើនៅពេលដែលម្ចាស់ បណ្តាំមិនអាចសរសេរ ឬធ្វើមតកសាសន៍តាមទម្រង ធម្មតាបាន ពោលគឺត្រូវមានល័ក្ខខ័ណ្ឌពិសេសមួយក្នុងការធានា នៅគុណភាពនៃលិខិត ដើម្បីសម្រេចឲ្យស្របទៅតាមស្ថានភាពពិសេសនោះដែរ។ ជាការកត់សម្គាល់មតកសាសន៍ក្នុងស្ថានភាព ពិសេសនេះ មានទម្រង់ប្របាក់ប្រហែលនឹងលិខិតយថាភូត ពីព្រោះថាក្រោមគំនៀបនៃស្ថានភាពនេះ មតកជនពុំអាចធ្វើលិខិតដោយផ្ទាល់ខ្លួនឯង និងសម្ងាត់បានទៀតឡើយ។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ កិច្ចតាមទម្រង់ក្នុងស្ថានភាពពិសេសនេះ នឹងអាចបង្កើតអនុភាពតាមផ្លូវច្បាប់ ដូចមតកសាសន៍ក្នុងស្ថានភាពធម្មតាបានតែក្នុងល័ក្ខខ័ណ្ឌ ដែលនៅក្រោយការបញ្ចប់ទៅនៃស្ថានភាពធម្មតា( បើម្ចាស់បណ្តាំនៅរស់) ឬយកទៅធើការបញ្ជាក់ទទួលស្គាល់ពីតុលាការប៉ុណ្ណោះ(បើម្ចាស់បណ្តាំបានស្លាប់)។ ដូចនេះ អាចនិយាយបានថាគ្មានទម្រង់ពិសេសនៃមតកសាសន៦ ក្រៅពីទម្រង់នៃលិខិតឯកជន និងលិខិតសម្ងាត់។

---

[53]ត្រង់ចំនុចនេះ សូមអានទៅចំណុចខាងក្រោម ស្តីពី ៖ "*សមត្ថភាពគ្រប់គ្រាន់នៃមតកជន*" ។

[54]ត្រង់ចំណុចនេះ សូមអានទៅចំណុចខាងក្រោយ ស្តីពី៖ ទម្រង់នៃមតកសាសន៍ក្នុងស្ថានភាពធម្មតា

**ក. មតកសាសន៍នៃជនដែលកំពុងជួយគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត**

ទោះបីជាកំពុងស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិតក៏ដោយប្រសិនបើមតកជនមានសមត្ថភាពធ្វើមតកសាសន៍ ដោយលិខិតឯកជន មតកជនអាចធ្វើបាន។ ម្យ៉ាងទៀតបាន ប្រសិនបើមតកជន ហៅសារការីបាន ក៏អាចធ្វើមតកសាសន៍នោះ ដោយលិខិតយថាភូតផងដែរ ។ ក៏ប៉ុន្តែអាចមានករណីដែលគ្មានលទ្ធភាព ឬពុំមានពេលវេលាគ្រប់គ្រាន់(បន្ទាន់) នោះម្ចាស់បណ្តាំក៏អាចធ្វើមតកដោយផ្ទាល់មាត់នៅចំពោះមុខសាក្សីផងដែរ[55] ។ យ៉ាងណាមិញ ក្រមរដ្ឋប្បវេណីថ្មីពុំបានកំណត់អត្តសញ្ញាណនៃគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិតនេះ ថាយ៉ាងដូចម្តេចឡើយ ដោយគ្រាន់តែបញ្ជាក់ថាវាអាចមានមូលហេតុមកពីជម្ងឺ ឬហេតុផ្សេងៗទៀតប៉ុណ្ណោះ។ ហេតុនេះ សញ្ញាណនេះហាក់ពុំច្បាស់លាស់ដ៏ដែល។

ក្នុងករណីនេះ ម្ចាស់បណ្តាំត្រូវប្រកាសខ្លឹមសារនៃមតកសាសន៍ដោយផ្ទាល់មាត់ ចំពោះមុខសាក្សីម្នាក់ក្នុងចំណោមសាក្សីយ៉ាងតិចបីនាក់ ដែលត្រូវមានវត្តមាននាពេលនោះ។ សាក្សីដែលទទួលបានការប្រកាសដោយផ្ទាល់មាត់នេះ ត្រូវសរសេរជាលាយលាយលក្ខណ៍អក្សរនូវខ្លឹមសារ នៃមតកសាសន៍នោះ និងបង្ហាវាឲ្យសាក្សីដ៏ទៃទៀតមើល។ បន្ទាប់មកសាក្សីនីមួយៗត្រូវបញ្ជាក់ពីភាពត្រឹមត្រូវ និង ចុះហត្ថលេខាលើមតកសាសន៍ជាការស្រេច។

មតកសាសន៍ទម្រង់នេះ តម្រូវឲ្យមានការដាក់ពាក្យសុំទៅតុលាការ ដើម្បីបញ្ជាក់ភាពពិតប្រាកដរបស់ម្ចាស់បណ្តាំដោយសាក្សីណាម្នាក់ ឬបុគ្គលដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ក្នុងរយៈពេលមួយខែគិតចាប់ពីថ្ងៃដែលបានធ្វើមតកសាសន៍នោះ បើពុំដូច្នោះទេវានឹងពុំមានអានុភាព តាមច្បាស់ឡើយ ។

**ខ. មតកសាសន៍នៃជនដែលត្រូវជាប់ឃុំឃាំង ឬដែលនៅក្នុងនាវា ឬយន្តហោះ**

ក្រមរដ្ឋប្បវេណីថ្មី អនុញ្ញាតឲ្យជនដែលត្រូវជាប់ឃុំឃាំង នឹងនៅក្នុងនាវា ឬ យន្តហោះ អាចធ្វើមតកសាសន៍ដោយវិធី ដោយឡែក[56] ។ នៅក្នុងមន្ទីរឃុំឃាំងជនដែលជាប់ ឃុំឃាំងអាចធ្វើលិខិតមតកសាសន៍ បានដោយមានវត្តមានរបស់នគរបាលឬមន្ត្រី នៃមន្ទីរឃុំឃាំងម្នាក់ និង សាក្សីយ៉ាងតិចពីរនាក់

---

[55]សូមអានមាត្រា១១៧៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ។

[56]សូមអានមាត្រា ១១៧៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។ សូមបញ្ជាក់ដែរថាពិតមែនក្រមព្ទរដ្ឋប្បវេណីថ្មីពុំបានចែងពីករណីនេះ ប៉ុន្តែប្រសិនបើស្ថិតក្នុងស្ថានភាពធម្មតាមតកជនបានធ្វើមតកសាសន៍ដោយពុំសរសេរជាលាយល័ក្ខអក្សរ (ផ្ទាល់មាត់) ទេ មតកសាសន៍ នោះពិតជាក្លាយជាកម្មវត្ថុនៃការបដិសេធចោលនូវអនុភាពរបស់វានៅក្រោយមរណៈភាព នៃមតកជន មិនខានពីព្រោះតែភាព មិនច្បាស់ លាស់នៃឆន្ទៈបង្ហាញមកនេះឯង។ ក្នុងន័យនេះហើយទើបច្បាប់បាវាំង ចាត់ជាមោឃៈនូវរាល់មតកសាសន៍ដែលធ្វើឡើង ដោយផ្ទាល់ម៉ាតឬ ដោយថតសម្លេង(សូមអានសៀវភៅរបស់ Philippe MALAURIE មានចំណងជើងថា៖ *"Les successions, Les lberalites"* បោះពុម្ពដោយ Edition Defrenois, ឆ្នាំ ២០០៣. ទំព័រ២៤៨ )។

ទៀត[57]។ ចំណែកុំឯបុគ្គលដែលកំពុងស្ថិតក្នុងនាវា ឬ យន្តហោះវិញចាំបាច់ត្រូវមាន វត្តមានមេបញ្ជាការបរិបាលនាវា ឬ យន្តហោះ និង សាក្សីយ៉ាងតិចពីរនាក់ដែរ។ មតកជនប្រភេទនេះ អាចធ្វើបណ្តាំ អាចធ្វើបណ្តាំដោយផ្ទាល់មាត់ នៅចំពោះមុខជនដែលបានរៀបរាប់ខាងលើនេះបាន។

មតកសាសន៍របស់ជនទាំងនេះ ជាគោលការណ៍ ត្រូវធ្វើឡើងតាមនីតិវិធីដូចគ្នានិងការធ្វើមតកសាន៍ដោយលិខិតយថាភូតដែរ[58]គ្រាន់តែក្នុងករណីនេះនគរបាល ឬមន្រ្តីនៃមន្ទីរឃុំឃាំង មេបញ្ជាការបរិបាលនាវា ឬ យន្តហោះ នឹងត្រូវដើរតួរជំនួសសាការីប៉ុណ្ណោះ[59]។ តែទោះជាយ៉ាងណា ជនទាំងនេះពុំមែនជាសាការីនោះទេ។ ដូចនេះមតកសាសន៍ដែលធ្វើឡើង ក្នុងករណីទាំងនេះ ក៏មិនមែនជាលិខិតយថាភូតដែរ[60] ។ យោងទៅតាមគោលគំនិតនៃក្រមនេះ មតកសាសន៍ដែលធ្វើឡើងតាមវិធីនេះ ហាក់គ្រាន់តែ ជាលិខិតបណ្តោះអាសន្ន តែប៉ុណ្ណោះ។ វានឹងពុំមានអានុភាពឡើយ ប្រសិនម្ចាស់បណ្តាំបន្តនៅរស់ ក្នុងកំឡុងពេល៦ខែ (គិតចាប់ពីពេល ដែលម្ចាស់បណ្តាំនោះ ត្រូវបានដោះលែង ឬចុះពីនាវា ឬ យន្តហោះ) ហើយអាចធ្វើមតកសាសន៍តាមទម្រង់ណាមួយស្ថិតក្នុងទម្រង់នៃលិខិតយថាភូត ឬលិខិតឯកជនឬលិខិតសម្ងាត់។

**គ..មតកសាសន៍នៃជនដែលមិនអាចនិយាយបាន**

ក្នុងករណីនេះ[61] ម្ចាស់បណ្តាំអាចប្រាប់អំពីខ្លឹមសារនៃមតកសាសន៍ដល់សាការីដោយធ្វើ សេចក្តីថ្លែងការណ៍ ដល់អ្នកបកប្រែភាសាសញ្ញា ឬ សរសេរដោយដៃខ្លួនផ្ទាល់ដើម្បីជំនួសឲ្យការប្រាប់ សេចក្តីថ្លែងការណ៍។ សារការី ក្រោយពីបានសរសេរជាលាយលក្ខណ៍អក្សរនូវខ្លឹមសារនៃមតកសាសន៍រួចរាល់ អាចប្រាប់អំពីខ្លឹមសារដែលបានសរសេរនោះ តាមរយៈការបកប្រែរបស់អ្នកបកប្រែ ទៅម្ចាស់បណ្តាំបានដើម្បីជំនួសការអានឲ្យស្តាប់។

**ឃ.មតកសាសន៍នៃជនជាតិខ្មែរដែលរស់នៅបរទេស**

ជនជាតិខ្មែរដែលរស់នៅបរទេស អាចធ្វើមតកសាសន៍ ដោយអនុលោមតាមទម្រង់ដែលអនុម័តដោយប្រទេសដែលខ្លួនកំពុងរស់នៅបាន។ ទោះបីជាយ៉ាងណាក៏ដោយ កាលបើមតកសាសន៍ ត្រូវបានធ្វើនៅចំពោះមុខសាការីបរទេសវានឹងមានឧបសគ្គខាផ្នែកភាសា។ ដូច្នេះហើយប្រសិនបើ ស្ថានកុងស៊ុល

---

[57] ក្នុងករណ៍នេះអាចចោទសួរថាតើសាក្សីយ៉ាងតិចពីររូបនោះត្រូវមានកុណភាពយ៉ាងដូចម្តេច ? ចំណុចនេះក៏ពុំត្រូវបាន បញ្ជាក់ឲ្យច្បាស់នៅក្នុងក្រមថ្មីនេះឡើយ។

[58] ត្រង់ចំណុចនេះសូមអានទៅចំណុចខាងក្រោយ ស្តីពី ៖ "*មតកសាសន៍ដោយលិខិតយថាភូត*"

[59] សូមមើលកថាខណ្ឌទី៤ នៃមាត្រា ១១៧៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧។

[60] ហេតុនេះករណីនេះអាចនឹងចោទឡើងនូវបញ្ហានៃប្រភេទរបស់ទម្រង់នៃលិខិតមតកសាសន៍នេះ។

[61] សូមអានមាត្រា ១១៧៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

កម្ពុជាមានទីតាំង នៅ កន្លែងដែលជនជាតិខ្មែរស្ថិតនៅ កុងស៊ុលនោះត្រូវដើរតួជាសារការី ដើម្បីឲ្យ ជនជាតិខ្មែរអាចធ្វើ មតកសាសន៍ដោយលិខិតយថាភូត ឬលិខិតសម្ងាត់ តាមទម្រង់ច្បាប់កំនត់បាន[62]។

ក្រោយពីបានស្គាល់អំពីបណ្តាំល័ក្ខខ័ណ្ឌទាំងឡាយ ក្នុងការបង្កើតមតកសាសន៍រួចហើយ យើងនិងសិក្សាជាបន្ទាប់នូវរាល់ខ្លឹមសារទាំងឡាយដែលលលខិតគតិយុត្តបែបមតជន ហើយក៏ជាភស្តុតាងតែ មួយគត់នៃការបង្ហាញពីឆន្ទៈរបស់ខ្មោចនេះ។ ដូចនេះការអនុវត្តមតកសាសន៍ ក៏ត្រូវអនុលោមផងដែរនូវខ្លឹមសារទាំងនេះ ក្រោយពេលមរណៈភាពនៃមតកជន។

[62] សូមអានមាត្រា ១១៨១នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

# ជំពូកទី២
# ខ្លឹមសារសំខាន់នៃមតកសាសន៍

# ជំពូកទី២

## ខ្លឹមសារសំខាន់នៃមតកសាសន៍

តាមពីតទៅ ខ្លឹមសារនៃមតសាសន៍នេះ សំដៅដល់អត្ថន័យនៃលិខិតឬកិច្ចដែលជាការសំដែង នូវឆន្ទៈចុងក្រោយរបស់តមកជន ពោលគឺនូវអ្វីដែលមតកជនជាម្ចាស់បណ្តាំតែម្នាក់ឯង ប្រាថ្នាចង់ឲ្យ កើតមានឡើង នៅក្រោយពេលស្លាប់របស់គាត់ប៉ុណ្ណោះ។ ក្នុងន័យនេះ ខ្លឹមសារនៃមតកសាសន៍ អាចទាក់ទងផ្ទាល់នឹងបេតិកភណ្ឌផង និងអ្វីដែលកំពុងពាក់ព័ន្ធជាមួយ បេតិកភណ្ឌផង[63]។ ប៉ុន្តែដោយសារតែជាការសំដែងឆន្ទៈឯតោភាគីនៃមតកជន ខ្លឹមសារនេះអាចនឹងបង្កើតអនុភាពគតិយុត្តមួយ ប្រកបដោយប្រសិទ្ធភាព តាមផ្លូវច្បាប់បាន តែកាលណាបើខ្លឹសារនេះ មានអត្ថន័យជាការផ្ទេរនូវផលប្រយោជន៍ស្របច្បាប់ណាមួយរបស់ម្ចាស់ឆន្ទៈ មកដល់អ្នកដែលម្ចាស់ឆន្ទៈនោះ ចង់ឲ្យទទួលនូវអនុភាពប៉ុណ្ណោះ។ ស្របទៅនិងហេតុផលនេះ ទើបផលប្រយោជន៍ដែលកើតពីឆន្ទៈនេះ ជាទូទៅ គឺទ្រព្យដែលសេសសល់ចុងក្រោយរបស់ម្ចាស់ឆន្ទៈ។ ចំណែកឯ ការផ្ទេរនូវបន្ទុកជាយថាហេតុណាមួយនោះ អាចនឹងមានប្រសិទ្ធភាពតាបច្បាប់ទៅបាន លុះណាតែវាដើរតួលក្ខខ័ណ្ឌដែលម្ចាស់ឆន្ទៈប្រាថ្នាឲ្យកើតមាន ជាថ្នូរនឹងការទទួលបានទ្រព្យដែលនៅសេសសល់របស់គាត់នោះដែរ[64]។ ដូចនេះ យើងអាចសង្រួមខ្លឹមសារសំខាន់ នៃមតកសាសន៍ មកត្រឹមតែជា ការចាត់ចែងទ្រព្យសម្បត្តិដែលនៅសេសសល់(ហៅមតិក) ក្រោយពេលស្លាប់នៃមតកជនជាម្ចាស់បណ្តាំនោះបានហើយ[65]។ ការចាត់នេះសោត អាចជាការកណាត់នូវចំនែកមតិក ឬក៏ជាការកំណត់នូវអ្នកដែលត្រូវទទួលបន្ទុកចាក់ចែងទ្រព្យមតិកនេះឯង។

លើសពីនេះទៀត បើមតកសាសន៍ជាឆន្ទៈរបស់ម្ចាស់បណ្តាំតែម្នាក់ ហើយនឹងចាប់ផ្តើមអនុវត្តតែនៅក្រោយពេលដែលម្ចាស់ឆន្ទៈនេះ បានបាត់បង់ពីលើលោកនេះទៅហើយនោះ ហេតុនេះវាពិតណាស់ដែលថា ភាពមិនច្បាស់លាស់មួយចំពោះខ្លឹមសារនៃមតកសាសន៍នេះ ប្រាកដជាអាចនឹងកើតមានជាយថាហេតុមិនខានដែលទាមទារនូការបកស្រាយមួយ។ តើអ្នកណាមានសិទ្ធិបកស្រាយនេះ ? សន្តតិជន

---

[63]សូមអានមាត្រា ១១៨៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ។
ផងដែរនឹងចាត់ទុកជាខ្លឹមសារមិនពាក់ព័ន្ធនិងទ្រព្យក្នុងន័យនៃមាត្រានេះចំពោះឆន្ទៈនៃមតកសាសន៍
ក្នុងការតែងតាំងអាណាព្យាបាលឲ្យកូនអនីតជនក្រោយពេលស្លាប់របស់ខ្លួនការទទួលស្គាល់កូនឥតខាន់ស្លាការចាត់ចែង
របៀបនៃបុណ្យសពរបស់ខ្លួន ។ល។

[64]ក្នុងន័យនេះ សូមអានមាត្រា១១៩៦ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ទាក់ទងនឹងអនុភាពនៃមតកសាសន៍ដែលភ្ជាប់ជាមួយនឹងលក្ខខ័ណ្ឌបង្អង់ ។

[65]សូមអានមាត្រា១១៨២ ស្តីពី៖ "*ការកំណត់ចំណែកមតិក* " និងមាត្រា១១៨៣ស្តីពី៖ *ការកំណត់នូវវិធីបែងចែកដោយមតកសាសន៍* "នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

នៃមតកជន ? អច្ច័យលាភី ? អ្នកទទួលបន្ទុកប្រតិបត្តិមតកសាសន៍? ឬតុលាការ ? ចំនុចនេះ ? ពុំត្រូវបញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧នោះឡើយ។ ប៉ុន្តែ ដូចក្នុងករណីនៃកិច្ចគតិយុត្តឯទៀតៗ ដែរការបកស្រាយខ្លឹមសារនៃមតកសាសន៍នេះ គួតែអាចធ្វើឡើងដោយ គ្រប់បុគ្គល ដែលពាក់ព័ន្ធ ណាមួយក៏បាន បើការបកស្រាយនោះអាចបញ្ចប់ជម្លោះរវាងណាមួយអំពីខ្លឹមសារនេះ។ ប៉ុន្តែនៅទីនេះការសិក្សាណា មួយអំពីបកស្រាយនេះ ហាក់ពុំសូវមានសារៈសំខាន់ប៉ុន្មាននោះឡើយ។

ដូចនេះ នៅក្នុងជំពូកនេះ យើងសូមមិនលើកយកមកធ្វើការសិក្សាបង្ហាញ នូវខ្លឹសារណាមួយនៃមតកសាន៍ដែលពុំទាក់ទងនឹងទ្រព្យ និងនូវបកស្រាយណាមួយ លើខ្លឹមសារ ស្រិពចស្រពិលមិនច្បាស់នៃមតកសាសន៍ ពីព្រោះថាសារៈសំខាន់របស់ចំនុចទាំងទ្វេរនេះ ត្រូវបានកាត់បន្ថយដូចដែលយើងបានបកស្រាយខាងលើរួចហើយ។ ការសិក្សាក្នុងជំពូកនេះថានឹងផ្ដោតតែទៅលើខ្លឹមសារដែល ពាក់ព័ន្ធសារសំខាន់នៃមតកសាសន៍។ ខ្លឹមសារសំខាន់នេះអាចត្រូវបានបែងចែកជាពីរផ្នុយគ្នាគឺ៖ ខ្លឹមសារវិជ្ជមាន **(ផ្នែកទី១)** និងខ្លឹមសារអវិជ្ជមាន**(ផ្នែកទី២)** នៃមតកសាសន៍ ។ភាពជាវិជ្ជមាន ឬជាអវិជ្ជមាននៃខ្លឹមសារក្នុងន័យនេះ សំដៅទៅការបែងចែកខ្លឹមសារនៃឆន្ទៈថាតើវាបង្កើតសិទ្ធិណាមួយពីបុគ្គលណាម្នាក់តាមរយៈមតកសាសន៍នេះប៉ុណ្ណោះ។

# ផ្នែកទី១
# ខ្លឹមសារជាវិជ្ជមាននៃមតកសាសន៍

ជាទូទៅ មតកសាសន៍ដែលជាឆន្ទៈចុងក្រោយរបស់មតកជន តែងបញ្ញត្តអំពីខ្លឹមសារជាវិជ្ជមានតែមួយគត់ គឺការផ្ទេរសិទ្ធិលើមត៌ករបស់ខ្លួន ឲ្យដល់សាច់ញាតិ បងប្អូន ឬតតិជនណាម្នាក់ដែលខ្លួនប្រាថ្នាចង់ផ្ទេរទ្រព្យរបស់ទាំងនោះទៅឲ្យ ក្រោយខ្លួនទទួលមរណភាព (**កថាខណ្ឌទី១**) ។ ក៏ប៉ុន្តែ ដោយហេតុការអនុវត្តឆន្ទៈចុងក្រោយនេះ រមែងធ្វើនៅក្រោយពេលដែលអ្នកផ្តាំថែកហានៈទៅ ទើបក្តីបារម្ភអំពី ការមិនអនុវត្តឲ្យស្របតាមឆន្ទៈរបស់ម្ចាស់បណ្តាំ ក៏រមែងកើតមានផងដែរ។ ដូចនេះហើយ ភាពចាំបាច់ នៃការបង្កើតសិទ្ធិឲ្យដល់បុគ្គលលៃណា ម្នាក់ដែលអាចទុកចិត្តបាន ឲ្យទទួលរ៉ាប់រងចាត់ចែង ការប្រតិបត្តិមតកសាសន៍នេះ តែត្រូវបានយល់ថាមានអត្ថប្រយោជន៍ចំពោះមតកជន និងក៏ជាមូលហេតុដែលនាំឲ្យមតកជនតែងបង្ហាញឆន្ទៈ បង្កើតដោយជាក់លាក់តាមរយៈ មតកសាសន៍ខ្លួនតែម្តង ឬ មួយក៏ច្បាប់តែងតម្រូវឲ្យ បង្កើតដោយសន្មតទុកជាឆន្ទៈរបស់មតកជន ក្នុងករណីមតកសាសន៍ ពុំបានបញ្ញត្តិ ក៏មាន (**កថាខណ្ឌទី២**)។

## កថាខណ្ឌទី១ ការបង្កើតសិទ្ធិលើមត៌កដល់អត្តគាហក

តាមរយៈអានេះភាពនៃមតកសាសន៍ ម្ចាស់បណ្តាំអាចចាត់ចែងទ្រព្យជា មត៌កដែលនៅសេសសល់របស់ខ្លួន ឲ្យដល់អត្តគាហក[66] ដែលអាចជាសន្តតិជនរបស់ខ្លួន ឬអាចជាតតិជនយជន។ ការចាត់ចែងនេះ គឺជាការបង្កើតនូវសិទ្ធិលើមត៌កឲ្យដល់អត្តគាហកនោះ តាមរយៈយន្តការនៃអនុប្បទាន ទ្រព្យសម្បត្តិពីមតកជនទៅអត្តគាហកទាំងនោះ តាមរយៈយន្តការ នៃអនុប្បទានទ្រព្យ សម្បត្តិពីមតកជនទៅអត្តគាហកទាំងនោះ[67]នាថ្ងៃមរណភាពនៃមតកជននោះ។ យើងអាចបែងចែកការផ្ទេរសិទ្ធិនេះ តាមរូបភាពពីរយ៉ាងដាច់ដោយឡែកពីគ្នា ពោលគឺអាចតាមរបបសន្តតិកម្មផង (**ក**)និងអាចតាមរយៈ អច្ច័យទានផង(**ខ**)។ពិតមែនតែទាំងរបបសន្តតិកម្ម និងរបបអច្ច័យទាន សុទ្ធសឹងតែជាកិច្ចគតិយុត្តឯកតោភាគីដូចគ្នាក៏ដោយ[68] ក៏ប៉ុន្តែយន្តការនៃការផ្ទេរសិទ្ធិនៃរបបទាំងពីរនេះ មានអត្ថន័យមិនដូចនោះឡើយ។

[66]បើក្នុងករណីអត្តគាហកៈនៃមតកសាសន៍នេះជាជនបរទេសនិងពុំមានសញ្ជាតិជាខ្មែរទេនោះ អត្តគាហកៈរូបនោះនឹងពុំអាចទទួលបាននូវសិទ្ធិជាកម្មសិទ្ធិករនៃទ្រព្យជាដីធ្លីនៅកម្ពុជា ដែលបន្សល់ទុកដោយមតកជនបានឡើយ។ ករណីនេះមានចែងច្បាស់នៅក្នុងរដ្ឋធម្មនុញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ត្រង់មាត្រា៤៤ និងនៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ត្រង់មាត្រា១១៥៥។

[67]សូមអានមាត្រា ១១៨៤ និង ១១៨៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

[68]ត្រង់ចំណុចនេះសូមមើលទៅក្រោយស្តីពីៈ*" សេចក្តីផ្តើម "* ។

**ក..តាមរបបសន្តតិកម្ម**

ជាគោលការណ៍ របបសន្តតិកម្មសំដៅដល់របបនៃការផ្ទេរ(អនុប្បទាន) នូវទ្រព្យសម្បត្តិជាមត៌ក របស់មតកជន ទៅឲ្យបុគ្គលជាសន្តតិកម្មជននៃមតកជននោះ[69]។ តាមន័យនេះ របបសន្តតិកម្ម ត្រូវបាន កំណត់ដោយល័ក្ខខ័ណ្ឌ ពីរយ៉ាងជាសំខាន់ ៖ ម្យ៉ាងគឺសារជាតិនៃទ្រព្យ ដែលត្រូវធ្វើអនុប្បទាន នោះត្រូវតែ ជាចំណែកមត៌ក និងមិនមែនជាធច្ចិយទាន [70] និងម្យ៉ាងទៀតគឺអត្តគាហកដែលត្រូវទទួលមត៌កនោះ ក៏ ត្រូវ មានគុណភាពជាសន្តតិកម្មនៃមតកជននោះផងដែរ។

ជាទ្រព្យមត៌កមានន័យថា ជាទ្រព្យដែលនៅសេសសល់ពីខ្មោច ហើយដែលមតកជន ពុំបាន សំដែងនូវឆន្ទៈធ្វើជាប្រទានកម្មមកឲ្យសន្តតិជន នាពេលធ្វើមតកសាសន៍នោះទេ។ ចំណែកឯសន្តតិជន នៃខ្មោចសំដៅរាល់ជនដែលត្រូវទទួលបន្តនូវសិទ្ធិ និងករណីកិច្ចទាំងអស់ដែលជាមត៌ករបស់ជន ចាប់ពី ពេលដែលចាប់ផ្តើមសន្តតិកម្ម[71] ព្រមទាំងគុណសម្បត្តិគ្រប់គ្រាន់ ដូចបញ្ញត្តិនៃមាត្រា១១៤៩ [72] នៃក្រមរដ្ឋ ប្បវេណីឆ្នាំ២០០៧ បានកំណត់។ ក្នុងន័យនេះ សន្តតិគឺជាប្រធាននៃមត៌ក ពោលគឺជាម្ចាស់នៃ មត៌ក ជា ស្វ័យប្រវត្តិនៅក្រោយពេលស្លាប់នៃមតកជនលើកលែងតែមតកជននោះបានបង្ហាញឆន្ទៈផ្សេងពីនេះ [73]។

លើកលែងសហព័ន្ធនៃមតកជនដែលដែលច្បាប់ទទួលស្គាល់ថា ជាសន្តតិជនជានិច្ច[74] សន្តតិជន ទាំងអស់ហាក់សុទ្ធសឹងជាបុគ្គលដែលជាប់ចំណងសារលោហិតនឹងមត៌កជននោះ។ ដូចនេះហើយ ទើបជា គោលការណ៍ បើទោះជាគ្មានវត្តមាននៃមតកសាសន៍ទេ ក៏សន្តតិជននៃមតកជន ត្រូវច្បាប់កំណត់ឲ្យមាន សិទ្ធិទទួលស្នងទ្រព្យមត៌ក របស់មតកជននោះ[75] ។ ហើយបើទោះបីជា មានមតកសាសន៍ ដែលបាន កំណត់ យ៉ាងច្បាស់អមពីការបែងចែកចំណែកមត៌កតាមឆន្ទៈនៃមតកជនក៏ដោយ ក៏កម្រិតអប្បរមា មួយ

[69]បើមតកជនពុំបានបញ្ចេញឆន្ទៈចុងក្រោយរបស់ខ្លួនទេច្បាប់នឹងដើរតួនាទីជាអ្នកកំណត់ជំនួសឲ្យដែលគេឲ្យឈ្មោះថាជា " *សន្តតិកម្មតាមច្បាប់* " ។ឯការបញ្ចេញឆន្ទៈនេះវិញត្រូវបានកំណត់ឈ្មោះថាជាស្តីពី៖ " *សន្តតិកម្មតាមមតកសាសន៍* " ។

[70]ត្រង់ចំណុចនេះសូមអានទៅចំណុចខាងក្រោយស្តីពី៖ " *របបអច្ចិយទាន* "។

[71]សូមអានមាត្រា១១៤៧ កថាខណ្ឌ ទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ។

[72]មាត្រា១១៤៩ ចែងថា ៖ ១- មានតែជនដែលមានជីវិតរស់នៅ នាពេលចាប់ផ្តើមសន្តតិកម្ម ក្រៅពីបុគ្គលដែលបញ្ញតិចាប់ពីមាត្រា១១៥០ (អភ័យបុគ្គលនៃសន្តតិកម្ម ជាអាទិ៍ )រហូតដល់មាត្រា១១៥២ (ការផ្តាច់មត៌កពីសន្តតិជន ដោយមតកសាសន៍០ ខាងក្រោមនេះទេ ទើបអាចទទួលសន្តតិកម្មបាន។ ២- ទោះមានបញ្ញតិដូចកថាខណ្ឌទី១ ខាងលើនេះក៏ដោយ បញ្ញត្តិនៃកថាខណ្ឌទី២ និងទី៣ នៃមាត្រា ៩ (ទារកនៅក្នុងគត៌) នៃក្រមនេះ ត្រូវយកមកអនុវត្ត ចំពោះទារកដែលនៅក្នុងគត៌ " ។

[73]ត្រង់ចំណុចនេះសូមមើលទៅចំណុចខាងក្រោយស្តីពី៖ " *ការលុបសិទ្ធិលើមត៌កពីសន្តតិជនដែលច្បាប់ទទួលស្គាល់* " ។

[74]សូមអានមាត្រា១១៦១ កថាខ័ណ្ឌ ទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

[75]នេះជារបបនៃសន្តតិកម្មតាមច្បាប់។ សូមអានទៅជំពូកទី២ នៃគន្ថីទី៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

នៃចំណែកមតិករបស់មតកជននោះ ត្រូវបានធានាដោយច្បាប់ជាដរាប ចំពោះអត្តគាហក ប្រភេទនេះ[76] ពីព្រោះថាឆន្ទៈរបស់មតកជម ត្រូវគោរពជាចាំបាច់នូវកោលការណ៍ នៃសាមគ្គីភាពគ្រួសារដែលជាដាច់ខាត់ផងដែរ[77] ។

តាមច្បាប់ សន្តតិជនទាំងនេះសោត ត្រូវចែកបានជាបីលំដាប់ផ្សេងៗគ្នា រួមទាំងអាចមាន ប្រភេទនៃសន្តតិជនជំនួស ក្នុងករណីមរណភាពនៃសន្តតិជនផ្ទាល់នោះផងដែរ[78]។

**ខ. របបអច្ច័យទាន**

ផ្ទុយអមពីរបបសន្តតិកម្ម[79]អច្ច័យទានមានន័យថាតាមរយៈមតកសាសន៍ មតកជនវបានបញ្ចេញឆន្ទៈរបស់ខ្លួនសំដៅដល់ហូតភាគណាមួយនៃមតិកដែល នៅសេសសល់ ចុងក្រោយរបស់គាត់[80] ប្រគល់ទៅឲ្យបុគ្គលម្នាក់ ឬច្រើននាក់ដែលហៅថាអច្ច័យលាភី។ តាមនិយមន័យ ដែលបានផ្តល់ឲ្យ ដោយក្រមរដ្ឋប្បវេណីឆ្នាំ២០០៧[81]អច្ច័យទាន[82] សំដៅដល់" ប្រទានកម្ម " [83] ដែលម្ចាស់បណ្តាំធ្វើទោឲ្យបុគ្គលម្នាក់ ឬ

---

[76]ត្រង់ចំណុចនេះសូមអានទៅចំណុចខាងមុខស្តីពី៖ *" ដែនកម្រិតនៃការលុបសិទ្ធិលើមតិកពីសន្តតិជន "*។

[77]គុណវុឌ្ឍជាសន្តតិជននេះពុំអាចបាត់បង់ទៅតាមរយៈឆន្ទៈរបស់មតកចនឡើយ (សូមអានត្រង់ចំណុចស្តីពី៖ " *ការលុបសិទ្ធិមតិកជនដែលច្បាប់ទទួលស្គាល់)* ។

[78]សូមអានពីមាត្រា១១៥៦ ដល់មាត្រា១១៦០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

[79]ជាតទ្រឹស្តីងអាចកំណត់ពីភាពខុសនៃរបបទាំងពីនេះត្រង់ចំណុចដែលថអច្ច័យទានគឺដូច
គ្នានឹងប្រទាបកម្មត្រង់ជាកិច្ចមុធា(ដោយមិនយកថ្លៃ) ដែលយកគុណភាពនៃបុគ្គលជាធំ(អត្តគាហក) ពោលគឺកិច្ចនេះមានអានុភាពតែទៅលើបុគ្គលដែលឆន្ទៈនៃមតកជនសំដៅដល់ប៉ុណ្ណោះ(ដូចនេះបើគ្មានមតកសាសន៍ទេក៏គ្មានអច្ច័យទានដែរ) ។ រីឯសន្តតិកម្មគឺធ្វើឡើងដោយស្វ័យប្រវត្តិនៅក្រោយមរណភាពនៃមតកជន(ដុចនេះ លើកលែងតែគ្មានសន្តតិជនទើជាគ្មានមតកសាសន៍ក៏មានសន្តតិកម្មដែរឯវត្តមាននៃមតកសាសន៍គឺគ្រាន់តែជាការចាត់ចែងរបៀបនៃសន្តតិកម្មប៉ុណ្ណោះ )។

[80]យោងតាមមាត្រា១២០៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ អច្ច័យទានពុំមានអនុភាពឡើយបើសិទ្ធិដែលជា កម្មវត្ថុនៃអច្ច័យទាននោះពុំស្ថិតនៅក្នុងមតិកនាពេលដែលម្ចាស់បណ្តាំបានទទួលមរណភាពទេនោះ ។

[81]សូមអាន " សទ្ទានុក្រមផ្នែករដ្ឋប្បវេណី *" នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ " ។*

[82]បើយោងតាមក្រមរដ្ឋប្បវេណីសង្គមចាស់(អេងសុត ឆ្នាំ១៩៦៧)វិញអច្ច័យទានគឺជាសំបុត្របណ្តាំដែលផ្តាំឲ្យចែកទ្រព្យមតិកណាមួយទៅជនណាម្នាក់ ឬច្រើននាក់។

[83]យោងតាមពាក្យ " ប្រទានកម្ម " ដែលបានប្រើដោយក្រមឆ្នាំ២០០៧ បានបង្កើតឲ្យមានការភាន់ច្រឡំមួយដ៏ធ្ងន់ចំពោះសញ្ញាណនៃ " អច្ច័យទាន " ដោយហេតុថាក្រមនេះបានកំណត់ច្បាស់រយចហើយនូវសញ្ញាណនៃ " ប្រធានកម្ម " នេះក្នុងមាត្រា៥៦៨ថា៖ *" សំដៅដល់កិច្ចសន្យាមួយដែលមានអនុភាពដោយភាគីម្ខាងបង្ហាញឆន្ទៈ ផ្តល់ឲ្យភាគីម្ខាងទៀត នូវទ្រព្យសម្បត្តិដោយមិនយកថ្លៃហើយភាគិម្ខាងទៀតយល់ព្រមទទួល"* ។
ប៉ុន្តែធាតុពិតនៃអច្ច័យទានគឺជាកិច្ចឯកតោភាគីពុំមែនជាកិច្ចសន្យាឡើយ។ តើក្រមថ្មីនេះចង់បង្កើតសញ្ញាណថ្មីនៃប្រទានកម្មដោយកិច្ចឯកតោភាគីបន្ថែមលើប្រទានកម្មជាកិច្ចសន្យា? ឬមួយចង់ចាត់ទុកអច្ច័យទាននេះជាកិច្ចសន្យា ដូចមានចែងក្នុងមាត្រា៥៦៨នៃក្រមនេះ។ ឬមួយក៏ចង់គ្រាន់តែជាការភាន់ស្រឡំក្នុងបម្រើបម្រាស់ពាក្យ ? តែទោះបីជាយ៉ាងណា យើងអាចយល់បានថាការប្រើប្រាស់ពាក្យនេះគ្រាន់ជាតែមានបំណងចង់ប្រដូចសញ្ញាណនៃអច្ច័យទាននេះទៅនឹងសញ្ញាណនៃកិច្ចសន្យាប្រទានកម្ម
ត្រង់លក្ខណៈនៃការបង្ហាញ" *ឆន្ទះផ្តលទៅឲ្យភាគីម្ខាងទៀតនូវទ្រព្យសម្បត្តិដោយមិនយកថ្លៃ " ប៉ុន្តែ* ពុំមានន័យថា

ច្រើននាក់នូវទ្រព្យសម្បត្តិរបស់ខ្លួនតាមរយៈមតកសាសន៍ " ។ ដោយមូលហេតុកិច្ចឯកតោភាគី អច្ច័យទាននេះនឹងត្រូវតែបង្កើតអានុភាពបានភ្លាម នៅពេលដែលមតកជនបានទទួលមរណភាប ដោយពុំចាំបាច់មានការយល់ព្រមណាមួយ អំពិអត្ថគាហក (អច្ច័យលាភី) នោះទេ។ ក្នុងន័យនោះទ្រព្យនឹងត្រូវបានផ្ទេរចូលទៅក្នុងបេតិកភណ្ឌ នៃអច្ច័យលាភីដោយ ស្វ័យប្រវត្តិ។ឯការបដិសេធជាយថាហេតុណាមួយរបស់អច្ច័យលាភី[84] គឺគ្រាន់តែជាការបោះបង់ ទ្រព្យសម្បត្តិពី បេតិកភណ្ឌរបស់ខ្លួនមកវិញប៉ុណ្ណោះ។អច្ច័យលាភីនេះ អាចជាសន្តិជន ឬតតិជនដែល ពុំមាន ជាប់សាច់ឈាមអ្វីទាំងអស់ជាមួយម្ចាស់បណ្តាំក៏បាន។

យោងតាមបញ្ញត្តិនៃមាត្រា១១៩៩ នៃក្រមឆ្នាំ២០០៧ អច្ច័យទានត្រូវបានបែងចែកជាពីរ ប្រភេទអាស្រ័យទៅតាមរបៀបនៃ ការទទួលបានមតិកតាមមតកសាសន៍។ អាចជាអច្ច័យទានសកល ឬអច្ច័យទានមានកំណត់[85]។ ជាអច្ច័យទានសកល កាលណាបើប្រទានកម្មនោះ ធ្វើទៅលើទ្រព្យសម្បត្តិទាំងអស់ ឬជាអច្ច័យទានដែលមានកំណត់ ទៅតាមភាគរបស់មតកជន ។ ជាស្តែងបើបើម្ចាស់ បណ្តាំបានធ្វើប្រទានកម្មតាមរយៈមតកសាសន៍នូវទ្រព្យសម្បត្តិទាំងអស់របស់ខ្លួន ឬ មួយផ្នែកដែល កំណត់តាមមាត្រា (ដូចជា១ ភាគ ២ ឬ២ភាគ ៣ ជាអាទិ៍)ទៅឲ្យបុគ្គលជាក់លាក់ណាមួយ ឬច្រើន។ អច្ច័យលាភីសកលត្រូវបានប្រដូចទៅនិងសន្តតិកជន ដោយត្រូវរ៉ាប់រងនូវសិទ្ធិ និងកាតព្វកិច្ចលើមតិកដែលមតកជនផ្តល់ឲ្យ ដូចគ្នានឹងសន្តតិកម្មដែរ[86]។ រីឯអច្ច័យទានមានកំណត់ គឺជាប្រទាននូវទ្រព្យសម្បត្តិជាក់លាក់ ណាមួយដែលកំណត់ច្បាស់នៅក្នុងមតកសាសន៍(ដូចជាប្រទានកម្មនូវដីធ្លីណាមួយឲ្យទៅលោក " ក "

---

ជាកិច្ចសន្យានោះឡើយ ។ ការកំណត់ឲ្យដុចគ្នាណាមួយនៃសញ្ញាណទាំងពីរដោយអ្នកតាក់តែងក្រមថ្មីនេះ ប្រហែលមកពីមូលហេតុនៃបំណុលោយករបេបប្រទានកម្មមកអនុវត្តចំពោះអច្ច័យទាន ពិសេសទាក់ទងនិងយន្តការបង់ពន្ធលើប្រតិបត្តិការណ៍នៃការផ្ទេរទ្រព្យទាំងនោះ ពោលគឺជាធម្មតា ប្រទានកម្មត្រូវបង់ពន្ធខ្ពស់ជាងសន្តតិកម្ម។

[84]ត្រង់ចំណុចនេវសុមអានទៅចំណុចខាងក្រោយស្តីពី៖ *" ការដិសេធរបស់អត្ថគាហកៈ "*។

[85]តាមច្បាប់បារាំងអច្ច័យទាននេះត្រូបានបែងចែកជាបីប្រភេទ៖ អច្ច័យទានសកល (Legs Universel គឺក្នុងករណីដែល ទទួលបន្តទាំងអស់នូវមតិករបស់មតកជន) ឬជាអច្ច័យទានជាសកល(Legs a titreUniversel គឺទទួលបន្តទាំងអស់ នូវចំណែកណាមួយដែលមតកសាសន៍បានកំណត់បានកំណត់ច្បាស់) ឬក៏ជាអច្ច័យទានមានកំណត់(Legs particulier ) គឺទទួលបន្តតែ ទ្រព្យសម្បត្តិដែលមតកសាសន៍កំណត់ច្បាស់ដូចជាផ្ទះ រថយន្ត ប្រាក់១០០០$ -ល- ។ ចំពោះអច្ច័យទានសកល និងជាសកលនេះត្រូវបានច្បាប់បារាំងប្រដូចទៅនឹងទាយាទនៃមតកជនដែរ ពោលគឺត្រូវទទួលបន្តពីខ្មោចទាំងសិទ្ធិករណីកិច្ច។ រីឯអច្ច័យទានមានកំណត់វិញគ្រាន់តែជាអ្នកទទួលបន្តធម្មតាពីខ្មោចតាមឆន្ទៈរបស់ខ្មោចប៉ុណ្ណោះ ដូចនេះ ទទួលតែសិទ្ធិពុំទទួលយកបំណុលនោះ ទេ(សូមអានសៀវភៅ J Maury មានចំណាង់ជើងថា៖ Successions , Liberalites បោះពុម្ពលើទី ៤ ដោយ Edition Litect,ឆ្នាំ២០០៣ទំព័រទី ១៧១ ដល់១៧៣ ។ ដូចនេះ ច្បាប់ខ្មែរហាក់បានបញ្ចូលសញ្ញាណនៃអច្ច័យទានសកល និងជាសកលតែមួយ(យោងតាមមាត្រា១១៩៩នៃក្រមថ្មី ។

[86]សូមអានមាត្រា១២១២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ។លើសពីនេះទៀត មាត្រានេះបានទទួលស្គាល់ថាបើមតកជនសម្រេចធ្វើប្រទានកម្មនូវមតិកទាំងអស់របស់ខ្លួនឲ្យដល់អច្ច័យលាភីសកលដែលមិនមានជាសន្តតិជរបស់ខ្លួន នោះ នឹងត្រូវចាត់ទុកថាមិនបានទទួលសន្តតិកម្ម លើកលែងតែសិទ្ធិលើភាគបម្រុង។

ហើយដីធ្លីនៅសល់ឲ្យទៅលោក " ខ "ចំណែកឯរថយន្តឲ្យទៅលោក " គ " ជាអាទិ៍)។ ខុសពីអច្ច័យទានសកលអច្ច័យទានមានកំណត់នេះ អនុញ្ញាតឲ្យអច្ច័យលាភីទទួលតែសិទ្ធិមានលើទ្រព្យ ដែលបានផ្ទេរមកនោះប៉ុណ្ណោះ ពុំទទួលរ៉ាប់រងនូវបំណុលដែលមាននោះទេ ។

ជាចុងក្រោយ ដោយសារតែអច្ច័យលាភីពុំមានគុណភាពដូចសន្តតិជន ជាប្រធាននៃមតិក ចាប់តាំងពីពេលដែរមតកជនបានទទួលមរណភាពទៅទេនោះ ដូច្នេះហើយ លើកលែងតែមានបញ្ញត្តិផ្សេងក្នុងមតកសាសន៍ ដើម្បីអាចទទួលបានផលអំពីអច្ច័យទានដែលមតកជនបានប្រគល់មកខ្លួន អច្ច័យលាភីត្រូវធ្វើការទាមទារឲ្យអនុវត្តអច្ច័យទាន[87] ពោលគឺស្នើសុំទៅសន្តតិជន ឬអ្នកប្រតបត្តិមតកសាសន៍ ដែលបានជ្រើសតាំងរួចមកហើយនោះ ។

## កថាខណ្ឌទី២ ៖ការបង្កើតសិទ្ធិចាត់ចែងមត៌កដល់អ្នកប្រតិបត្តិមតកសាសន៍

ដោយមូលហេតុណាមួយក៏ដោយ ការបង្កើតឲ្យមុខងារនៃអ្នកប្រតិបត្តិមតកសាសន៏នេះ[88] តែងតែផ្សារភ្ជាប់ជាមួយនឹងកង្វល់ ក្នុងការអនុវត្តមតកសាសន៍ ដែលជាឆន្ទៈចុងក្រោយ នៃមតកជន(បណ្តាំនៃខ្មោច)ជាដរាប។ ដោយយោងតាមស្មារតីនៃក្រមរដ្ឋប្បវេណី ខ្មែរ ឆ្នាំ២០០៧[89] អ្នកប្រតិបត្តិមតកសាសន៍សំដៅដល់បុគ្គលមួយរូប ឬច្រើនរូប (សហអ្នកប្រតិបត្តិមតកសាសន៍) ដែលត្រូវបានជ្រើសតាំងឡើង

---

[87]សូមអានមាត្រា១២០៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

[88]មុខងារនេះអាចរ៉ាប់រងបានថាសញ្ញាណថ្មីសម្រាប់ច្បាប់ខ្មែរពីព្រោះថាប្រពៃណីខ្មែរអនុញ្ញាតឲ្យតែក្រុមគ្រួសារសាច់ញាតិនៃមតកជនជាអ្នកប្រតិបត្តិបណ្តាំ ជាការគ្រប់គ្រាន់ហើយ។ ប៉ុន្តែចំពោះច្បាប់បរទេស ពិសេសអឺរ៉ុប បានចាត់តួនាទីនេះមានសារៈសំខាន់រហូតបញ្ចូលសញ្ញាណនេះពីការអនុវត្តធម្មតា មកជាច្បាប់ ក្នុងគោលដៅធានាការអនុវត្តឆន្ទៈ របស់ខ្មោច ឲ្យត្រឹមត្រូវនិងមានប្រសិទ្ធិភាព ពិសេសក្នុងករណីនៃអច្ច័យទាន(សូមអានសៀវភៅរបសលោក Philippe MALAURIE មានចំណងជើងថា៖ *" Les successions, Les lberalites"* បោះពុម្ពដោយ Edition Defrenois, ឆ្នាំ ២០០៧ , ទំព័រ២៦៩ និងបន្តបន្ទាប់ )។

[89]ពិតមែនតែក្រមនេះបានឧទ្ទិសផ្នែកទី៧ ជំពូកទី៣ នៃគន្លឹះទី៨ របស់ខ្លួនសម្រាប់សញ្ញាណនេះក៏ដោយក៏ក្រមនេះពុំបានកំណត់ឲ្យច្បាប់ពីនិយមន័យនៃសញ្ញាណនេះឡើយ។ ប៉ុន្តែយើងអាចយល់សញ្ញាណនេះបានតាមតួនាទីភារកិច្ចនិងសិទ្ធិអំណាច ដែលកំណត់នៅក្នុងផ្នែកទី ៧ នៃក្រមនេះ ។ ក្រមនេះបានប្រដូចតួនាទីនេះទៅនឹងអាណត្តិ( សូមអានមាត្រា១២២៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧) ។ បញ្ហាចោតត្រង់ថាបើអាណត្តិកិច្ចមែនតើគាត់តំណាងឲ្យអ្នកណា? ឲ្យមកជនដែលស្លាប់បាត់ហើយនោះ ? ឬក៏សន្តតិជននៃមតកជនដែលនឹងស្នងមតិកបន្ត ? អ្វីដែលចំឡែកគឺត្រង់នៅមាត្រា១២២៣ នៃក្រមនេះដែលចែងថា អ្នកប្រតិបត្តិមតកសាសន៍ត្រូវធ្វើសកម្មភាពក្នុងនាមខ្លួនឯងផ្ទាល់(ដូចនេះ មិនមែនជាអ្នកតំណាងអាណត្តិកិច្ចទេ) ប៉ុន្តែសកម្មភាព ដែលគាត់បានធ្វើនឹងមានគុណភាពដល់សន្តតិជនដែលជាម្ចាស់សិទ្ធិលើមតិក(ដូចនេះ វាស្រដៀងនឹងអាណត្តិកិច្ចវិញត្រង់ថាសកម្មភាពរបស់អ្នកតំណាងមានអានុភាពដល់ម្ចាស់សិទ្ធិដែរ )។ គួរបញ្ជាក់ដែរថាបើទោះបីជាក្រមនេះបានបញ្ញត្តិក៏ដោយ ក៏មុខងារជាអ្នកប្រតិបត្តិមតកសាសន៍នេះគ្រាន់តែជម្រើសមួយពុំមែនជាកាតព្វកិច្ចអ្វើឡើយ បានសេចក្តីថាបើមតកសាសន៍អាចនឹងត្រូវអនុវត្តតាមយ៉ាងល្អនោះទាំងម្ចាស់បណ្តាំទាំងតុលាការណពុំចាំបាច់បង្កើតឲ្យមានយន្តការនេះឡើយ។

ដើម្បីទទួលភារកិច្ចអនុវត្តមតកសាសន៍ឲ្យបានត្រឹមត្រូវ និងមានប្រសិទ្ធិភាព។ ដើម្បីអាចធានាបាននូវសុក្រឹតភាពនៃការងារការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍នេះត្រូវតែផ្អែកតាមបែបបទមួយច្បាស់លាស់(ក) ទើបសិទ្ធិអំណាចរបស់គាត់ត្រូវបានទទួលស្គាល់ដោយច្បាប់(ខ)។

**ក. ការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍**

អ្នកប្រតិបត្តិមតកសាសន៍អាចត្រូវបានជ្រើសតាំងឡើងតាមពីរប្រភេទ៖ ដោយមតកជនផ្ទាល់ ឬដោយតុលាការ[90] ដោយមតកជន ពើលគឺតាមរយៈមតកសាសន៍ដែលតាមនោះ ម្ចាស់បណ្តាំ បានសំដែងឆន្ទៈបង្កើតអ្នកប្រតិបត្តិមតកសាសន៍នេះឯង។ក្នុងករណីនេះ មតកសាសន៍អាចបញ្ជាក់នូវអត្តសញ្ញាណ នៃបុគ្គលដែលត្រូវបានមតកជនសម្រេចឲ្យធ្វើជាអ្នក ប្រតិបត្តិមតកសាសន៍តែម្តង[91] ឬមួយគ្រាន់តែជាការផ្តល់អាណត្តិដល់ជនម្នាក់ ឲ្យមានសិទ្ធិកំណត់បុគ្គលម្នាក់ ឬច្រើននាក់ផ្សេងៗទៀត ធ្វើជាអ្នកប្រតិបត្តិមតកសាសន៍ក៏បាន[92]។ តើបុគ្គលប្រភេទណា ទើបអាចក្លាយជាអ្នកប្រតិបត្តិមតកសាសន៍នេះ ?

ជាទូទៅ ការបង្ហាញឆន្ទៈណាមួយរបស់ម្ចាស់បណ្តាំ ក្នុងការបង្កើតតួនាទីនេះ សរឲ្យឃើញ ពីការមិនទុកចិត្តរបស់ខ្លួន ចំពើការអនុវត្តមតកសាសន៍ ដោយសន្តតិជនរបស់គាត់ដែលនឹងត្រូវក្លាយជា ប្រធាននៃសិទ្ធិលើមតិករបស់គាត់ នៅក្រោយមរណភាព របស់គាត់តែម្តង។ ហេតុនេះអ្នកប្រតិបត្តិ មតកសាសន៍នេះ ត្រូវចាត់ទុកជាបុគ្គលដែលទទួលបាននូវការទុកចិត្តពីម្ចាស់បណ្តាំ។ ដូច្នេះហើយ ដូចកិច្ច ដែលផ្តោតលើគុណភាពបុគ្គលជាសំខាន់ដែរមុខងារជាអ្នកប្រតិបត្តិមមតកសាសន៍នេះ ពុំអាចផ្ទេរ ទៅបុគ្គលផ្សេងទៀតឲ្យខុស ពីអ្នកដែលត្រូវបានជ្រើសតាំង ដោយមតកសាសន៍ឡើយ សូម្បីទៅឲ្យ សន្តតិជន នៃអ្នកប្រតិបត្តិមតកសាសន៍នោះ ក្រោយមរណភាពរបស់គាត់ក៏ដោយ។ ក្នុងករណីនេះ ចាំបាច់ ត្រូវតែជ្រើសតាំងជាថ្មី នៅពេលដែលអ្នកប្រតិបត្តិមតកសាសន៍មុនបានលាឈប់ ឬបានស្លាប់[93] ។

---

[90]សូមបញ្ជាក់ថាតុលាការមានអំណាចបង្កើតអ្នកប្រតិបត្តិមតកសាសន៍បាន តែក្នុងករណ៍ដែលមានការស្នើសុំ ពីអ្នកពាក់ព័ន្ធផលប្រយោជន៍នឹងមតកសាសន៍ប៉ុណ្ណោះ ពុំមានឆន្ទានុសិទ្ធិដោយឯកឯងឡើយ(សូមអានមាត្រា១២១៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧) ។

[91]សូមអានមាត្រា ១១៨៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

[92]សូមអានមាត្រា ១២១៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ។ ក្នុងករណីនេះ អ្នកទទួលអាណត្តិអាចកំណត់ខ្លួនឯងអធ្វើជាអ្នកប្រតិបត្តិមតកសាសន៍បាន បើមតកសាសន៍ពុំបានហាមឃាត់ទេនោះ (សូមមើល" *សេចក្តីកំណត់ចំពោះមាត្រានិមួយៗ នៃក្រមរដ្ឋប្បវេណីភាគណ៦ . គន្លឹះទី ៨ - ទី៩* រៀបរៀងដោយការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី នឹងគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណីឆ្នាំ, ឆ្នាំ២០១០. កំណត់ពន្យល់មាត្រា១២១៤ .ទំព័រ៧៦)។

[93]លើកលែងតែក្នុងករណីដែលម្ចាស់បណ្តាំបានបង្ហាញឆន្ទៈថាអនុញ្ញាតឲ្យផ្ទេរទៅឲ្យអ្នកផ្សេងបាន ឬករណីដែលមានមូលហេតុនៃការផ្ទេរដោយពុំអាចជៀសវាងបាន(សូមមើលមាត្រា១២២៥នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧)។

ទោះបីជាការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍នេះត្រូវផ្អែក ជាធំលើទំនុកចិត្តក៏ដោយ ក៏ច្បាប់នៅតែបានហាមឃាត់ចំពោះបុគ្គលមួយចំនួន ដោយមូលហេតុនៃសមត្ថភាព ក្នុងការក្លាយខ្លួនជា អ្នកប្រតិបត្តិមតកសាសន៍នេះផងដែរ។ ពោលគឺឈរលើហេតុផលដែលថា នៅពេលប្រតិបត្តិមតកសាសន៍ អ្នកប្រតិបត្តិមតកសាសន៍នេះក៏ជាអ្នកធ្វើសកម្មភាពគតិយុត្តមួយផងដែរ ដូច្នេះហើយ ជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពគតិយុត្ត ដូចជាជននៅក្រោមអាណាព្យាបាលទូទៅ ឬនៅក្រោមរបបហិតូម្ភ នីតិជននិងជនធនក្ស័យដែលធ្លាប់មានបញ្ហាខាងហិរញ្ញវត្ថុ ពុំអាចធ្វើជាអ្នកប្រតិបត្តិ មតកសាសន៍នេះបានទេ[94]។

ជាចុងក្រោយ ការជ្រើសតាំងបុគ្គលណាមួយជាអ្នកប្រតិបត្តិមតកសាសន៍នេះ ពុំមានន័យជាការបង្កើតកាតព្វកិច្ចឲ្យដល់បុគ្គលនេះឡើយ តែត្រូវឈរលើការយល់ព្រមទទួលមុខងារនេះ ឬអត់ពីបុគ្គលនោះប៉ុណ្ណោះ។ រាល់ការយឺតយ៉ាវណាមួយក្នុងការកាន់ ឬអនុវត្តមុខងារនេះ អាចក្លាយជាកម្មវត្ថុនៃការដាស់តឿន និងសួរបញ្ជាក់ថាព្រមទទួល ឬលះបង់ដោយទុករយៈពេលកំណត់ឲ្យមួយ ពីសំណាក់សន្តតិជន ឬពីជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ផ្សេងទៀត។ ភាពស្ងៀមស្ងាត់មិនឆ្លើយតប នឹងត្រូវចាត់ទុកជាការលាឈប់ពីមុខងារនេះ។ លក្ខខ័ណ្ឌនេះ ត្រូវអនុវត្តចំពោះបុគ្គល ដែលមតកសាសន៍ផ្តល់សិទ្ធិក្នុងការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍នេះផងដែរ។ បើអ្នកប្រតិបត្តិនេះ បានទទួលព្រមរួចរាល់ហើយ គាត់ត្រូវអនុវត្តភារកិច្ចនោះភ្លាម ហើយគាត់ត្រូវទទួលបានសិទ្ធិអំណាច ដែលផ្តល់ឲ្យដោយមតកសាសន៍ ឬដែលត្រូវបានធានាដោយច្បាប់។

**ខ..សិទ្ធិអំណាចនៃអ្នកអនុវត្តមតកសាសន៍**

កុំឲ្យតែបំពាន់ដល់ខ្លឹមសារនៃមតកសាសន៍[95] អ្នកប្រតិបត្តិមតកសាសន៍មានសិទ្ធិ អំណាចក្នុងការគ្រប់គ្រងមតិក និងធ្វើរាល់សកម្មភាពផ្សេងទៀតដែលចាំបាច់ទាំងអស់ ដើម្បីអាចអនុញ្ញាតឲ្យប្រតិបត្តិមតកសាសន៍នោះបាន[96] ពោលគឺចាត់ចែងមតិក ដែលនៅសល់របស់ខ្មោចនោះ ឲ្យស្របតាម មតកសាសន៍។ សិទ្ធិអំណាចនេះ ត្រូវបានកម្រិតត្រឹមត្រូវទ្រព្យសម្បត្តិ ដែលជាចំណែកមតិក នៃមតកជននោះប៉ុណ្ណោះ[97]។

[94]សូមអានមាត្រា១២១៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ។

[95]រាល់ការធ្វេប្រហែសក្នុងភារកិច្ចឬកំហុសដោយចេតនាណាមួយ សន្តតិជនឬអ្នកពាក់ព័ន្ធនឹងផលប្រយោជន៍អាចដាក់ពាក្យប្តឹងទៅតុលាការឲ្យបញ្ឈប់ជននោះ ឬទាមទាសំណងការខូចខាតបាន(យោងតាមមាត្រា១២២៧ និង ១២២៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧)។

[96]សូមអានមាត្រា១២២០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

[97]សូមអានមាត្រា១២២២នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

អ្នកប្រតិបត្តិមតកសាសន៍ត្រូវធ្វើដោយគ្មានបង្អង់ ក្រោយពីការចូលកាន់មុខនាទីរបស់ខ្លួន នូវបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិរបស់មតកជនដែលនៅសល់ នោះទាំងអស់[98] ដើម្បីអាចធ្វើការទូទាត់បំណុលដែលមានលើ មតិកទាំងអស់នោះ រួចទើនចាត់ចែងបែងចែកទៅឲ្យសន្តតិជន ឬអច្ច័យលាភីទៅតាមចំណែកដែលមតកសាសន៍បានចែង[99]។

វត្តមាននៃអ្នកប្រតិបត្តនេះ នឹងនាំឲ្យសន្តតិជនដែលជាទូទៅ ជាអ្នកមានសិទ្ធិស្របច្បាប់ ក្នុងការស្នងមតិកពីមតកជន(ជាប្រធាននៃកសិទ្ធិលើមតិកនើ) ត្រូវបាត់បង់សិទ្ធិក្នុងការចាត់ចែងនេះវិញ ហើយសន្តតិជនទាំងឡាយ ក៏ពុំអាចធ្វើសកម្មភាពណាមួយដែលនាំឲ្យប៉ះពាល់ ឬជាការរារាំងដល់ការប្រតិបត្តិមតកសាសន៍នេះដែរ ។ដូចនវសិទ្ធិអំណាចរបស់អ្នកប្រតិបត្តិនេះហាក់ជាធំទូលាយ និងពុំមានដែនកម្រិតអ្វីដែលបញ្ញត្តដោយច្បាប់សោះឡើយ។

រាល់ការប្រើប្រាស់សិទ្ធិអំណាចសំដៅចាត់ចែងទ្រព្យមតិកណាមួយដែលផ្ទុយនឹងមតកសាសន៍ និងត្រូវពុំមានអានុភាពឡើយ[100]។

---

[98]សូមអានមាត្រា១២១៩នៃក្រម

[99]សូមមើល " *សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណីភាគ ៦ . គន្ថីទី៨ - ទី៩* រៀបរៀងដោយការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងគណៈកម្មារទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, ឆ្នាំ២០១០កំណត់ពន្យល់មាត្រា១២២០,ទំព័រទី៨០។

[100]សូមអានមាត្រា១២២១ . នៃក្រម។

# ផ្នែកទី២
# ភាពពិសេសនៃខ្លឹមសារអវិជ្ជមានរបស់លិខិត

មតកសាសន៍ មិនត្រឹមតែអាចប្រើប្រាស់ សម្រាប់បង្កើតសិទ្ធិឲ្យដល់អត្តគាហកមួយមុខប៉ុណ្ណោះទេ តែវាត្រូវក៏អាចត្រូវបានប្រើប្រាស់ សម្រាប់ដកហូត សិទ្ធិពីអត្តគាហកបានផងដែរ។ ការដកហូតនេះមាន អនុភាពតែចំពោះអត្តគាហកដែលជាសន្តតិជននៃមតកជននោះប៉ុណ្ណោះ ពីព្រោះថាមានតែ សន្តតិជន នេះទេ ដែលច្បាប់បញ្ញត្តិទទួលស្គាល់នូវសិទ្ធិទទួលបានចំណែកណាមួយនៃមតិក ដែលបន្សល់ទុក របស់ មតកជន ជាស្វ័យប្រវត្តិ។ ដូនេះ ទើបទាមទារឲ្យមានការសំដែងឆន្ទៈច្បាស់លាស់ តាមយន្តការដែល ក្រម ថ្មីឲ្យឈ្មោះថាជាការផ្តាច់មតិកពីសន្តតិជនណាមួយ(**កថាខណ្ឌទី១**)។ ប៉ុន្តែការផ្តាច់នេះ ពុំអាចបំពានបាន ជាដាច់ខាតនូវភាគបម្រុងដែលច្បាប់បានធានាឲ្យមានដល់សន្តតិជន ស្របច្បាប់ទាំងនោះ។ ការធានា ដោយច្បាប់នេះត្រូវបានចាត់ទុកដូចជាដែនកម្រិតមួយនៃការផ្តាច់មតិកនេះផងដែរ(**កថាខណ្ឌទី២**)

## កថាខណ្ឌទី១ ៖ ការផ្តាច់មតិកពីសន្តតិជនដែលច្បាប់ទទួលស្គាល់សិទ្ធិ

ការផ្តាច់នូវចំណែកណាមួយនៃមតិកពីសន្តតិជនណាម្នាក់ គឺជាការលុបចោល នូវសិទ្ធិស្របច្បាប់ ក្នុងការទទួលបាននូវមតិកនៃសន្តតិនោះ តាមឆន្ទៈនៃមតកជន។ អនុលោមតាមមាត្រា១១៥១ នៃក្រម រដ្ឋប្បវេណីឆ្នាំ២០០៧ មតកជនអាចជ្រើសរើសយន្តការមួយក្នុងចំណោមពីរយ៉ាងគឺ៖ ការប្តឹងផ្ទាល់ទៅ តុលាការនិងការសំដែងឆន្ទៈតាមការធ្វើមតកសាសន៍[101]។ ថ្វីត្បិតតែក្រមរដ្ឋប្បវេណីថ្មី ពុំបានកំណត់ នូវ ទម្រង់ណាមួយនៃការសំដែងឆន្ទៈផ្តាច់នេះយ៉ាងដូចម្តេចក៏ដោយ ក៏ជាទូទៅ តាមរយៈមតកសាសន៍ ម្ចាស់ បណ្តាំអាចបញ្ចេញឆន្ទៈថាផ្តាច់មតិកពីសន្តតិជនណាម្នាក់ ជួនកាលធ្វើឡើងដោយផ្ទាល់ (**ក**) និងជួន កាលទៀតអាចធ្វើឡើងដោយប្រយោល(**ខ**)។

### ក.ការផ្តាច់មតិកដោយផ្ទាល់ពីសន្តតិជន

ការផ្តាច់មតិកតាមទម្រង់ផ្ទាល់ គឺជាការបង្ហាញឆន្ទៈមកក្រៅរបស់មតជន សំដៅផ្តាច់មតិកពី សន្តតិជន តាមរយៈសកម្មភាពជាក់លាក់ណាមួយពោលគឺដោយកំណត់យ៉ាងច្បាស់នៅក្នុងមតកសាសន៍

[101]មាត្រា១១៥១ កថាខនណ្ឌ ទី១ ចែងថា៖ *"មតកជនកាលណានៅរស់ អាចដាក់ពាក្យសុំទៅតុលាការឲ្យផ្តាច់មតិកជនដែលត្រូវបានសន្មតថាជាសន្តតិជននោះមិនឲ្យទទួលសន្តតិកម្មបាន [....] មតកជន ក៏អាចបង្ហាញឆន្ទៈអំពីការផ្តាច់នេះ តាមមតកសាសន៍បានដែរ"* ។ ប៉ុន្តែដោយ សារតែប្រធាននៃការសិក្សារបស់យើងពុំទាក់ទងនឹងការប្តឹងនេះ យើងសូមមិនលើកយកមកបង្ហាញនៅទីនេះ អំពីយន្តការផ្តាច់មតិកដោយការប្តឹងរបស់មតកជនទៅតុលាការដោយផ្ទាល់នេះទេ។

ថាសន្តតិជនរូបណាម្នាក់នឹងមិនអាចទទួលបន្ត មតិករបស់គាត់ ក្រោយដែលគាត់ស្លាប់ទៅនោះឡើយ។ ក្នុងករណីនេះ សន្តតិជនដែលត្រូវបានប្រកាសក្នុងមតកសាសន៍ថាលុបសិទ្ធិទទួលមតិកចោលនោះ នឹងពុំអាចទទួលបាន ចំណែកណាមួយនៃមតិក ដូចដែលឆន្ទៈខ្មោចបានផ្តាំដូច្នេះដែរ។ ចំណែកឯសន្តតិជនដទៃទៀតដែលពុំមានឈ្មោះថាត្រូវផ្តាច់មតិកនោះ ត្រូវសន្មតយ៉ាងស្របច្បាប់ថាមានសិទ្ធិទទួលបានមតិក ពីខ្មោច។ក្នុងន័យនេះដែរ ប្រសិនបើម្ចាស់បណ្តាំសម្រេចផ្តាច់មតិកអំពីសន្តតិជនរបស់គាត់ទាំងអស់វិញនោះ មតិកដែលនៅសេសសល់ចុងក្រោយរបស់គាត់នឹងត្រូវធ្លាក់ទៅជារបស់រដ្ឋ[102]។

លើសពីនេះទៀត ការផ្តាច់មតិកនេះ ក៏អាចសំដែងឡើងនៅក្នុងមតកសាសន៍ ក្រោយរូបភាពជាល័ក្ខខ័ណ្ឌតម្រូវមួយ ឬច្រើនដល់សន្តតិជនណាមួយក៏បាន។ ក្នុងន័យនេះ មតកជនអាចកំណត់ថាសន្តតិជនរូបណាមួយដែលឋិតក្នុងមូលហេតុ នៃការផ្តាច់មតិកនេះ ត្រូវបំពេញល័ក្ខខ័ណ្ឌណាមួយជាថ្នូរនឹងការមិនផ្តាច់សិទ្ធិទទួលបានមតិកនេះ ហើយការដែលមិនបំពេញឲ្យបាន តាមល័ក្ខខណ្ឌតម្រុវនេះ ត្រូវចាត់ទុកថាជាការផ្តាច់មតិក ។ ប៉ុន្តែក្នុងករណីនេះ ល័ក្ខខ័ណ្ឌដែលតម្រូវដោយមតកជននោះ នឹងពុំអាចមានសុពលភាពតាមផ្លូវច្បាប់ជាដាច់ខាត់ កាលបើវាផ្ទុយនឹងគោលការណ៍ ចាំបាច់ពីតយ៉ាងគឺៈ សណ្តាប់ធ្នាប់សាធារណៈ និងភាគបម្រុងនៃសន្តតិជន [103] ។

**ខ. ការផ្តាច់មត៌កដោយប្រយោលពីសន្តតិជន**

ការសម្តែងឆន្ទៈផ្តាច់មតិកដោយប្រយោល គឺជាលទ្ធផលនៃការបង្ហាញឆន្ទៈ របស់ម្ចាស់បណ្តាំថាផ្ទេរទាំងអស់ នូវចំណែកនៃមតិករបស់គាត់ទៅឲ្យ អច្ច័យលាភីសកល[104]។ ដោយសារអច្ច័យលាភីសកលមានឧបនិស្ស័យ ទទួលយកនូវមតិករបស់គាត់ ទៅឲ្យទៅសន្តតិជនរបស់គាត់ជាហេតុអាចឲ្យ យើងបកស្រាយបានថា មតកជនរូបនោះ មានឆន្ទៈក្នុងការផ្តាច់មតិក ពីសន្តតិជនផ្ទាល់របស់គាត់ផងដែរ។ ដូចគ្នានេះដែរ ការដែលមតកសាសន៍បានបញ្ញត្ត បែងចែកមតិកពីទាំងអស់របស់ខ្លួនទៅឲ្យសន្តតិជន ឬ/និងអច្ច័យលាភីទាំងឡាយ តែមិនបានប្រគល់នូវចំណែកណាមួយដល់សន្តតិជនណាម្នាក់ ក៏អាចត្រូវបានចាត់ទុកថាមតកជនបានសំដែងឆន្ទៈផ្តាច់មតិកអំពីសន្តតិជនរូបនោះដោយប្រយោលបានផង
ដែរ ។

[102]យោងតាមមាត្រា ១៣០០ " *មតិកដែលមិនត្រូវបានចាត់ចែង តាមបញ្ញត្តិនៃមាត្រា១២៩៩ (ការចែកមតិក ឲ្យទៅជនដែលមាននិស្ស័យពិសេស)ខាងលើនេះត្រូវធ្លាក់ទៅជាទ្រព្យរដ្ឋ* ។

[103]ត្រង់ចំណុចនេះសូមអានទៅខាងមុខស្តីពីៈ "*សិទ្ធិលើភាគបម្រុងជាដែនកម្រិតនៃការផ្តាច់មតិក* " ។

[104]ត្រង់ចំណុចនេះសូនអានទៅខាងក្រោយស្តីពីៈ "*តាមរបបអច្ច័យទាន*"។

ប៉ុន្តែ ដោយហេតុថាជាការសមដែងឆន្ទៈដោយតុណ្ហីភាពរបស់ម្ចាស់បណ្តាំ នោះការផ្តាច់មតិកតាមទម្រង់នេះក៏ជាការបង្កើតឡើងនូវ មន្ទិលចំពោះភាពពិតប្រាកដនៃឆន្ទៈ[105] របស់មតកជននោះផងដែរ។ ភាពមន្ទិលនេះនឹងអនុញ្ញាតឲ្យសន្តតិជនដែលត្រូវបានផ្តាច់មតិកតាមទម្រង់ ប្រយោជន៍នេះ ទទួលបានមតិកមកវិញកាលបើអច្ច័យទាន(សកល ឬមានកម្រិត)នោះ ត្រូវប្រកាសមោឃភាព ឬមួយក៏អច្ច័យលាភី ឬសន្តតិជនឯទៀត សម្រេចថាបោះបង់អច្ច័យទាន ឬសន្តតិរបស់ខ្លួនចោល[106] ។ ករណីនេះ ក៏ជាភាពខុសប្លែកគ្នាមួយដែររវាងការផ្តាច់តាមទម្រង់ប្រយោលនេះ និងតាមទម្រង់ផ្ទាល់ ពីព្រោះតែតាមទម្រង់ផ្ទាល់ម្ចាស់បណ្តាំបានបង្ហាញអត្តសញ្ញាណ នៃសន្តតិជនដែល ត្រូវផ្តាច់មតិកនោះច្បាប់លាស់ហើយដូចនេះការបដិសេធមតិកពីអត្តគាហកដទៃទៀត រួមបញ្ចូលទាំងមោឃភាពនៃអច្ច័យទានផងនោះពុំនាំមកវិញ នូវសិទ្ធិទទួលបានមតិកឲ្យដល់សន្តតិជនដែលត្រូវបានផ្តាច់នោះបានឡើយ ដ៏រាបណាមតកសាសន៍នោះនៅតែមានសុពលភាព។

មួយវិញទៀតចំពោះទម្រង់នេះ កថាខណ្ឌទី១ នៃមាត្រា១១៥១ របស់ក្រមថ្មី បានបង្កើតឡើងនូវមូលហេតុចាំបាច់ដល់ការផ្តាច់មតិកតាមឆន្ទៈនៃមតកជននេះ[107]។ ក្នុងករណីនៃអវត្តមានមូលហេតុទាំងនេះសន្តតិជនដែលជាកម្មវត្ថុនៃការផ្តាច់នេះ អាចធ្វើបណ្តឹងទៅតុលាការ ដើម្បីសុំបដិសេធការផ្តាច់ នោះចោលបាន[108]។ ដូចនេះ បើតាមស្មារតីនៃមាត្រា ១១៥១នេះ យើងអាចចោទសួរបានថា តើក្រមនេះបានបដិសេធចោទនូវទម្រង់នៃការផ្តាច់មតិកដោយប្រយោលនេះ ឬយ៉ាង កាលបើតាមទម្រង់នេះ ជាធម្មតា ម្ចាស់បណ្តាំពុំដែលបានបញ្ជាក់នូវមូលហេតុនៃការផ្តាច់នេះសោះ? បើជាការបដិសេធនូវទម្រង់នវចោលមែន នោះតើការផ្តាច់មតិកដោយប្រយោលនេះនឹងត្រូវប្រកាសជាមោឃៈ ឬយ៉ាងណា? តើការផ្តាច់មតិកនេះ ត្រូវទុកដូចជាវិធានសណ្តាប់ធ្នាប់សាធារណៈ ដែលពុំចំណុះឲ្យឆន្ទៈរបស់មតកជន ពោលគឺចង់ផ្តាច់ត្រូវតែមានមូលហេតុ ដូចកំណត់ក្នុងមាត្រា១១៥១ តើបាន ឬយ៉ាងណា ?

[105]ត្រង់ចំណុចនេះសូមអានទៅខាងក្រោយស្តីពី៖ *"ភាពពិតប្រាកដនៃឆន្ទៈជាល័ក្ខខ័ណ្ឌគ្រឹះតែមួយគត់នៃមតកសាសន៍ "* ។

[106]ត្រង់ចំនុចនេះសូមអានទៅខាងក្រោយស្តីពី៖ *"ការបដិសេធរបស់អត្តគាហក "* ។

[107]កថាខណ្ឌទី ១ នៃមាត្រា១១៥១ចែងថា [...] មតកជនក៏អាចបញ្ចេញឆន្ទៈអំពីការផ្តាច់មតិកនេះ តាមមតកសាសន៍បានដែរ បើជនដែលត្រូវសន្មតថាជាជនដែលមានភាគបម្រុង បានប្រព្រឹត្តនូវសកម្មភាពដែលបានកំណត់ខាងក្រោមនេះ៖ ក/បើបានធ្វើបាបចំពោះមតកជន។ ខ/បើបានប្រមាថមតកជនយ៉ាងធ្ងន់ធ្ងរ ។ គ/បើអាចមតកមើលថែទាំមតកជន នៅពេលដែលមានជម្ងឺប៉ុន្តែមិនមកថែទាំ។ ឃ/បើត្រូវទទួលសាលក្រមឬសាលដិកាផ្តន្ទាទោសឲ្យជាប់ពន្ធនាគារមួយជិវិត។ ង/បើបានប្រព្រឹត្តិអំពើល្មើសធ្ងន់ធ្ងរគួរឲ្យកត់សំគាល់ជាអាទិ៍ ។

[108]កថាខណ្ឌទី ២នៃមាត្រា ១១៥១ ចែងថា ៖*" ជនដែលត្រូវសន្មតថាជាសន្តតិជនដែលបានទទួលការទាមទារ ផ្តាច់មតិកនេះអាចធ្វើវិវាទអំពីអត្ថិភាព ឬនត្ថិភាពនៃមូលហេតុនៃការការផ្តាច់មតិកនេះ នៅក្នុងការសម្រេចសេក្តីដែលបានកំណត់ នៅក្នុងកថាខណ្ឌទី១ ខាងលើនេះបាន "* ។

ជារួមទោះ ជាការផ្តាច់នេះធ្វើតាមទម្រង់ណាមួយ ក៏ដោយក៏ សន្តតិជនដែលត្រូវបានផ្តាច់មតិក នឹងត្រូវទទួលរងនូវផលវិបាកគតិយុត្តមួយដូចគ្នា ដែលការបាត់បង់នូវសិទ្ធិទទួលបានមតិក នៅក្រោយមរណភាពនៃមតកជន[109]។ ផលវិបាលនេះ នឹងអាចកើតមានបាន តែល្គឹកណាមានពាក្យបណ្តឹង ទៅតុលាការប៉ុណ្ណោះ[110]។

ប៉ុន្តែគួរកត់សំគាល់ដែរថា ខុសអំពីអភ័យព្វបុគ្គលនៃសន្តតិកម្ម[111] ការផ្តាច់មតិកពីសន្តតិជនណាម្នាក់ ពុំអាចបណ្តាលឲ្យសន្តតិជនរូបនោះ បាត់បង់នូវឋានៈជាសន្តតិជននៃមតកជនដែលច្បាប់បាន ប្រគល់ឲ្យនោះបានឡើយ។ ក្នុងន័យនេះ សន្តតិជនរូបនោះ នៅតែមានសិទ្ធិទទួលបាន មតិកពីមតកជន របស់ខ្លួនដដែល កាលបើមតកសាសន៍ត្រូវបានប្រកាសថាមោឃៈ។

ទោះជាយ៉ាងណាក្តី ដោយឈរលើមូលដ្ឋាននៃចំណងខ្សែរលោហិតរវាងពួកគេ និងមតកជន សន្តតិជននេះ គឺជាអ្នកស្នងមតិកដែលច្បាប់បានកំណត់។ ហេតុនរហើយ ទើបក្នុងរឿងមតិក ច្បាប់បាន

[109]ក្នុងន័យនេះ បើយោងតាមមាត្រា១១៥៣ ការកាន់កាប់ណាមួយលើទ្រព្យមតិក ពីសន្តតិជនដែលត្រូវបាន ផ្តាច់មតិកដោយមតកសាសន៍ត្រូវចាត់ទុកថាជាការកាន់កាប់ដោយទុច្ចរិត ចាប់ពីពេលចាប់ផ្តើមសន្តតិកម្មមក។ តែផ្ទុយទៅវិញកាលបើមានការផ្តាច់មតិកហើយ ប៉ុន្តែសន្តតិជនដទៃដែលមានសិទ្ធិលើមតិកបែរ ជាព្រមព្រៀងគ្នាបែងចែកចំណែកមតិកណាមួយឲ្យទៅសន្តតិជនដែលត្រូវបានផ្តាច់មតិកតាមមតកសាសន៍ នោះនឹងពុំត្រូវចាត់ទុកថាបំពានឆន្ទៈ របស់ម្ចាស់បណ្តាំនោះឡើយ ប៉ុន្តែនឹងត្រូវចាត់ទុកថាជាប្រទានកម្មសន្តតិជនដទៃទៀតហើយសន្តតិជនដែលត្រូវផ្តាច់មតិកនោះនឹងមានសិទ្ធិស្របច្បាប់លើទ្រព្យជាមតិកនោះ បាន(សូមអាន*" សេចក្តីកំណត់ហេតុមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណីភាគ ៦ គន្លីទី៨ -ទី៩ "* រៀបរៀងដោយក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងគណៈកម្មាការទទួលបន្ទុកការពារសេចក្តីព្រាងរដ្ឋប្បវេណី, ឆ្នាំ២០១០ . កំណត់ពន្យល់មាត្រា ១១៥២ . ទំព័រ១០ )។

[110]មាត្រា ១១៥២ ចែងថា៖ *" បើមតកជនបានធ្វើមតកសាសន៍ដូចបានកមណត់នៅក្នុងមាត្រា ១១៥១ ខាងលើនេះ អ្នកប្រតិបត្តិមតកសាសន៍ ត្រូវដាក់ពាក្យសុំទៅតុលាការឲ្យផ្តាច់មតិកពីសន្តតិជនដោយគ្មានការយឺតយ៉ាវនៅក្រោយពេលដែលមតកសាសន៍ នោះបានបង្កើតអនុភាព។ក្នុងករណីនេះការផ្តាច់មតិកពីសន្តតិជននោះមានអនុភាព ប្រតិកម្មចាប់ពីពេលដែលមតកជនបានទទួលមរណភាព "* ។

[111]យោងសន្ទានុក្រមនៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

អភ័ព្វបុគ្គលសំដៅដល់បុគ្គលដែលពុំអាចក្លាយជាសន្តតិជនឬអាចទទួលទ្រព្យសម្បត្តិតាមមតកសាសន៍បាន ។ លើសពីនេះទៀត មាត្រា១១៥០ នៃក្រមចែងថា ៖ *" បុគ្គលណាដែលបានកំណត់ដូចខាងក្រោមនេះ ពុំក្លាយជាសន្តតិជនឬអាចទទួលទ្រព្យសម្បត្តិតាមមតកសាសន៍បានឡើយ៖ ក/ បុគ្គលដែលបានទទួលទោសដោយចេតនាធ្វើឃាតឬប៉ុនប៉ងធ្វើឃាតលើមតកជនឬលើជនដែលមានលំដាប់សន្តតិកម្មមុនឬលំដាប់ស្មើគ្នាទោះដោយផ្ទាល់ក្តីឬដោយប្រយោលកក្តី ។ ខ/ បុគ្គលដែលដឹងអំពីការសម្លាប់មតកជនតែមិនបានរាយការណ៍ ឬមិនបានប្តឹង។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយចំពោះករណីដែលបុគ្គលនោះមិនអាចវិនិច្ឆ័យអំពើល្អឬអាក្រកបានឬករណីដែលអ្នកសម្លាប់ជាសហព័ទ្ធឬញាតិលោហិតខ្សែរផ្ទាល់របស់បុគ្គលនោះ។ គ/ បុគ្គលដែលបានរារាំងមតកជនក្នុងការធ្វើលុបចោលឬកែប្រែមតកសាសន៍ស្តីពីសន្តតិកម្មដោយការឆបោកឬគម្រាមកំហែង។ ឃ/ បុគ្គលដែលបានឲ្យមតកជនធ្វើលុបចោលឬកែប្រែមតកសាសន៍ ស្តីពីសន្តតិកម្មដោយការឆបោកឬគម្រាមកំហែង។ ង/ បុគ្គលដែលបានក្លែងកែបន្លំបំផ្លាញចោល ឬលាក់ទុកនូវលិខិតមតកសាសន៍ស្តីពីសន្តតិកម្មរបស់មតកជន "* ។

បង្កើតឲ្យមានយន្តការធានាមួយដែលហៅថាភាគបម្រុងសម្រាប់ពួកគេ ហើយដែលតាមយន្តការនេះ ច្បាប់បានទទួលស្គាល់នូវសិទ្ធិរបស់ពួកគេ ក្នុងការដែលត្រូវតែទទួលបាននូវចំណែក ណាមួយនៃមត៌ករបស់មតកជន។ ក្នុងន័យនេះ សូម្បីតែឆន្ទៈរបស់មតិកជនផ្ទាល់ ក៏ពុំអាចនឹងបំពានចំណែកនោះបានដែរ ដូចនេះហើយ ទើបយើងចាត់ទុកយន្តការនេះដូចជាដែនកម្រិតមួយនៃការផ្តាច់មត៌កតាមមតកសាសន៍ ពីសន្តតិជនណាមួយក៏ដោយ។

## កថាខណ្ឌទី២ ៖ សិទ្ធិលើភាគបម្រុងនៃសន្តតិជនជាដែនកម្រិតនៃការផ្តាច់មត៌ក

សិទ្ធិលើភាគបម្រុង គឺជារបបនៃការធានាមួយដោយច្បាប់ ឲ្យដល់សន្តតិជននៃមតកជន ក្នុងការទទួលបាននូវចំណែកណាមួយនៃមត៌ក តាមការកំណត់របស់ច្បាប់។ ការធានានេះនឹងអនុញ្ញាតឲ្យសន្តតិជនដែលច្បាប់បានកំណត់ អាចបដិសេធមតកសាសន៍ណាមួយ ដែលខ្លឹមសាររបស់វាបាន រំលោភលើភាគបម្រុងរបស់គាត់។ យើងអាចនិយាយមួយបែបទៀតថា មតកជនមានសេរីភាពចាត់ចែងនៃមត៌កដែលនៅសល់ពីការផាត់ទាត់ ភាគបម្រុងចេញរួចហើយប៉ុណ្ណោះ ពីព្រោះថាកាលបើមតកជនចាត់ចែងមត៌ករបស់ខ្លួនដោយបំពានលើភាគបម្រុង នោះសន្តតិជនភាគបម្រុងអាចនឹងប្តឹងទាមទារ យកភាគបម្រុងរបស់ខ្លួននោះមកវិញបាន។ ប៉ុន្តែគ្រប់ករណីទាំងអស់ សិទ្ធិលើភាគបម្រុង ទាមទារឲ្យសន្តតិជនដែលមានសិទ្ធិនោះ ចាំបាច់ត្រូវរៀបចំនិតិវិធីប្តឹងទាមទារ។បើពុំនោះសោតសិទ្ធិទាមទារភាគបម្រុងនេះនឹងត្រូវបាត់បង់ទៅដោយផុតអាជ្ញាយុកាលកំណត់[112]។

នៅក្រោយពេល ចាប់ផ្តើមសន្តតិកម្ម តាមមតកសាសន៍ បើមានការទាមទាររបស់សន្តតិជនភាគបម្រុង នើការគិតគូរ និងបែងចែកនូវចំណែកជាភាគបម្រុងនៃមត៌ករបស់ម្ចាស់បណ្តាំ នឹងត្រូវបានចាប់ផ្តើម។ បើការគិតគូររកឃើញថា ការបែងចែកតាមលិខិតបណ្តាំបានបំពានដល់ភាគបម្រុងនៃមតកជននោះនឹងមានយន្តការទាមទារ ត្រលប់មកវិញនូវចំណែកមត៌កដែលបានបែងចែករួចនោះ តាមរបៀបនៃការបន្ថយ ចំណែកដែលបានបែងចែករួចទៅនោះ មកបង្គ្រប់ភាគបម្រុងមិនខាន។ តែនេះមិនមានន័យថានឹងទាមទារឲ្យបន្ថយមកវិញ នូវរាល់ចំណែកមត៌ក ដែលបានបែងចែករួចទាំងអស់នោះឡើយ[113]ហើយនឹង

[112]មាត្រា១២៤៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ចែងថា៖ *" សិទ្ធិទាមទារឲ្យកាត់បន្ថយត្រូវរលត់ដោយអាជ្ញាយុកាល បើអំឡុងពេល ១(មួយ)ឆ្នាំបានកន្លងហួស គិតចាប់ពីពេលដែលអ្នកមានសិទ្ធិលើភាគបម្រុងបានដឹងអំពីការចាប់ផ្តើមសន្តតិកម្ម និងការកំណត់ចំណែតមត៌កអច្ច័យទានឬការទទួលផលប្រយោជន៍ពិសេសដែលត្រូវកាត់បន្ថយ។ សិទ្ធិទាមទារឲ្យកាត់បន្ថយ ក៏ត្រូវរលត់ដោយអជ្ញាយុកាលបើអំឡុងពេល៥ (ប្រាំ)ឆ្នាំបានកន្លងហួសកិតចាប់ពីពេលចាប់ផ្តើមសន្តតិកម្ម " ។*

[113]មាត្រា១២៣៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ចែងថា៖ *" អ្នកមានសិទ្ធិលើភាគបម្រុង និងអ្នកទទួលបន្តនោះអាចទាមទារឲ្យធ្វើការកាត់បន្ថយអច្ច័យទានជាអាទិ៍ ចំពោះជនដែលទទួលបានទ្រព្យសម្បត្តិ*

មិនទាមទារឲ្យកាត់បន្ថយចំពោះ គ្រប់ប្រភេទនៃទ្រព្យដែលបានបែងចែកទៅនោះដែរ[114]ពោលគឺយន្តការនេះនឹងអនុញ្ញាតឲ្យបន្ថយតាមលំដាប់លំដោយនៃប្រភេទទ្រព្យដែលបានកំណត់ដោយច្បាប់[115]ត្រឹមតែចំណែកដែលបានបំពានតែប៉ុណ្ណោះ(មិនលើស ហើយក៏មិនខ្វះ!)។ ដូចនេះ តើសន្តតិជន ប្រភេទណាខ្លះទើបមានសិទ្ធិលើភាគបម្រុងនេះ? ហើយត្រូវគណនាយ៉ាងដូចម្តេចដែរ។

យោងតាមមាត្រា១២៣០[116] នៃក្រមរដ្ឋប្បវេណីថ្មីឆ្នាំ២០០៧ ការទទួលស្គាល់សិទ្ធិលើភាគបម្រុងនេះ មិនមែនត្រូវធ្វើលើគ្រប់សន្តតិជន ទាំងអស់នោះឡើយ ពោលគឺធានាចំពោះតែសន្តតិជន លំដាប់ទី១ និងទីពីរនៃមតកជន រួមទាំងសន្តតិជនជំនួសនៃលំដាប់ទាំងពីរនេះប៉ុណ្ណោះ។ ម្យ៉ាងទៀតតាមមាត្រានេះផងដែរចំណែកនៃភាគបម្រុងដែលនឹងត្រូវទទួលបាន គឺប្រែប្រួលទៅតាមគុណភាពនៃសន្តតិជននោះ(១ ភាគ ៣ នៃចំណែកមតិករបស់មតកជន ប្រសិនបើសន្តតិជនភាគបម្រុង មានតែបុព្វញាតិរបស់គាត់ និង ១ ភាគ ២ ប្រសិនបើមានតែបច្ឆាញាតិ ឬតែសហព័ន្ធ ឬទាំងបច្ឆាញាតិនិងសហព័ន្ធ ឬទាំងបុព្វញាតិ បច្ឆាញាតិនិងសហព័ន្ធ)។ រីឯការបែងចែកភាគបម្រុងដែលបានមកនោះវិញ ត្រូវគោរពទៅតាមគោលការណ៍សមាមាត្រ ក្នុងករណីដែលមានសន្តតិជនភាគបម្រុងច្រើនរូប។

ជាឧទាហរណ៍ ក្នុងករណ៍ដែលមតកជនមានតែកូនម្នាក់ និងសហព័ន្ធ ជាសន្តតិជន នោះភាគបម្រុងសម្រាប់អ្នកទាំងពីរ គឺ ១ ភាគ ២ នៃមតិករបស់មតកជនរួចចំពោះចំណែកភាគបម្រុង ដែលម្នាក់ ត្រូវទទួលបានគឺ ១ ភាគ ៤ នៃមតិករបស់មតកជនទាំងអស់ផងដែរ ពោលគឺ ១ ភាគ ២នៃចំណែកមតិក ទាំងអស់(ជាភាគបម្រុងដែលត្រូវធានា)ចែកឲ្យគ្នា ២ នាក់ គឺ ១ ភាគ ២ទៀត (ចែងតាមសសមាមាត្រ នៃចំនួនសន្តតិជនស៊ីភាគបម្រុងនោះគឺកូន និងសហព័ន្ធ)ដូចនេះម្នាក់ៗគឺត្រូវទទួលបាន ១ ភាគ៤ នៃមតិកទាំងអស់របស់មតកជននោះ។ ផ្ទុយទៅវិញ បើក្នុងករណីដែលមានឪពុកម្តាយ និងសហព័ន្ធ រួមទាំងអស់ ៣នាក់ជាសន្តតិជន ហេតុនេះ ភាគបម្រុងគឺ ១ ភាគ ២តែដោយមានគ្នា ៣នាក់ នោះសម្រាប់ម្នាក់

---

*ឬផលប្រយោជន៍ដែលជា កម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងបាន ត្រឹមកម្រិត ដែលចាំបាច់ដើម្បីរក្សាភាគបម្រុង នោះ "។*

[114]មាត្រា១២៣១ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ចែងថា៖ *" ភាគបម្រុង ត្រូវគណនាដោយយក ទ្រព្យសម្បត្តិដែលមតកជនមាននៅពេលចាប់ផ្តើមធ្វើសន្តតិកម្ម បូកតម្លៃនៃផលប្រយោជន៍ពិសេស ដែលបានកំណត់នៅក្នុងមាត្រា១១៦៣ (ចំណែកមតិករបស់អ្នកដែលទទួលផលប្រយោជន៍ពិសេស) និងតំម្លៃទ្រព្យសម្បត្តិប្រទានកម្មដែលបានកំណត់ ក្នុងមាត្រា១២៣២ (ប្រទានកម្មដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង) នៃក្រមនេះហើយដកនូវចំនួនប្រាក់សរុបនៃកាតព្វកិច្ចចេញ "។*

[115]មាត្រា១២៣៦នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ចែងថា៖ *"ប្រទានកម្មនិងការទទួលផលប្រយោជន៍ពិសេស ពុំអាចកាត់បន្ថយបានឡើយ បើមិនបានកាត់បន្ថយពីអច្ច័យតាននិងចំណែកមតិកដែលបានកំណត់តាមមតកសាសន៍ជាមុនទេ "*

[116]មាត្រា១២៣០នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ស្តីពីអ្នកមានសិទ្ធិលើភាគបម្រុងចែងថា៖ *"១/បច្ឆាញាតិផ្ទាល់ ឬឪពុកម្តាយ ឬ ជីដូនជីតានិងហព័ន្ធរបស់មតកជនអាចធ្វើលទ្ធកម្មនូវទ្រព្យសម្បត្តិដូចខាងក្រោម ៖*

និងទទួលបានចំណែកភាគបម្រុង ១ ភាគ ៦នៃមតិកទាំងអស់របស់មតកជន។ ជាចុងក្រោយក្នុងករណីដែលមានបងប្អូនបង្កើតរបស់មតកជន និងសហព័ន្ធ ជាសន្តតិជន នោះភាគបម្រុងផ្តល់ឲ្យតែសហព័ន្ធនៃមតកជនប៉ុណ្ណោះហើយបងប្អូនបង្កើតនៃមតកជនគឺ ១ ភាគ២ ប៉ុន្តែដោយបង្កើត ពុំមានសិទ្ធិ លើភាគបម្រុងឡើយ ហេតុនេះសហព័ន្ធនោះ នឹងត្រូវទទួលបានភាគបម្រុង ១ភាគ ២ នៃមតិផងដែរ។

យ៉ាងណាមិញ បើទោះបីជាសិទ្ធិលើភាគបម្រុងនេះ ត្រូវបានច្បាប់ធានាឲ្យសន្តតិជននៃមតកជនយ៉ាងនេះក៏ដោយ ក៏សន្តតិជនភាគបម្រុងនៅតែមានសេរីភាពក្នុងការបោះបង់សិទ្ធិនេះ ចោលផងដែរ[117] ដែលយន្តការនៃការបោះបង់នេះ ត្រូវបានដើរស្រដៀងគ្នា នឹងការបោះបង់សន្តតិកម្ម ក្នុងន័យទូទៅផងដែរ។

---

ក. ១ ភាគ ៣ (មួយភាគបី) នៃទ្រព្យសម្បត្តិរបស់មតកជនក្នុងករណីដែលមានតែសន្តតិជនជាឪពុកម្តាយឬជីតាប៉ុណ្ណោះ។

ខ. ១ ភាគ ២ (មួយភាគពីរ) នៃទ្រព្យសម្បត្តិមតកជនក្នុងករណីផ្សេង។

២. ក្នុងករណីដែលមានសន្តតិជនច្រើននាក់ អ្នកមានសិទ្ធិកលើភាគបម្រុងនីមួយៗអាចទទួលភាគបម្រុងតាមសមាមាត្រនៃណែកមតិកបាន។

៣. បញ្ញត្តិនៃមាត្រា១១៥៧ (សន្តតិជនកម្មជំនួស) និងមាត្រា១១៥៨ (ចំណែកមតិកក្នុងករណីនៃសន្តតិកម្មជំនួស) នៃក្រមនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះភាគបម្រុង។

[117]មាត្រា ១២៤៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ចែងថា៖ *" ភាគបម្រុងអាចបោះបង់ទាំងអស់ ឬមួយផ្នែកបាន ។ប៉ុន្តែការបោះបង់ភាគបម្រុងនៅពេលចាប់ផ្តើមសន្តតិកម្មមានអានុភាពលុះត្រាតែបានទទួលការអនុញ្ញាតពីតុលាការ"* ។ គួរញ្ជាក់ដែរថាការអនុញ្ញាតរបស់តុលាការក្នុងន័យនៃវាក្យខណ្ឌទី២ នៃមាត្រានេះពុំសំដៅ តែដល់ការសម្រេច ជាឆន្ទានុសិទ្ធិ របស់ចៅក្រមឡើយ ប៉ុន្តែគ្រាន់តែជាយន្តការមួយអនុញ្ញាតឲ្យតុលាការអាចពិនិត្យពីភាពពិតប្រាកដនៃឆន្ទៈបោះបង់នោះ ថាពិតជាគ្មានបង្កប់វិការៈប៉ុណ្ណោះ(សូមមើល" *សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណីភាគ ៦ . គន្លឹទី៨ - ទី៩* " រៀបរៀងដោយក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងគណៈកម្មាការទទួលបន្ទុកការញរសេចក្តីព្រាងក្រមរដ្ឋប្បវេណី, ឆ្នាំ២០១០ , កំណត់ពន្យល់មាត្រា១២៤៦, ទំព័រ ១០៧ )។ ដូចនេះ ការសម្រេចដោយអំណាចឆន្ទានុសិទ្ធិណាមួយរបស់តុលាការគឺជាការរំលោភមួយយ៉ាងធ្ងន់ធ្ងរលើសេរីភាពនៃការបង្ហាញឆន្ទៈរបស់សន្តតិជនដែលមិនចង់បានភាគបម្រុង។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ដោយឥតប្រកែកបាន គ្រប់វិធានច្បាប់ទាំងអស់ពុំត្រូវមានឧបនិស្ស័យត្រឹមតែជាវិធាន លើក្រដាស់នោះទេ ប៉ុន្តែទាមទារឲ្យអាចយកទៅអនុវត្តក្នុងសង្គជាតិជាក់ស្តែងបានទៀតផង ពីព្រោះថារាល់វិធានច្បាប់ទាំងអស់មានគោលដៅតែមួយគត់ដូចគ្នា គឺបញ្ចៀសជម្លោះក្នុងសង្គម (រក្សាសណ្តាប់ធ្នាប់សារធារណៈ)។ ផ្ទុយទៅវិញ ការសិក្សាលើប្រធានបទ *" មតកសាសន៍ "* ដែលបានបង្ហាញខាងលើនេះ គឺពិតណាស់គ្រាន់តែជាការស្វែងយល់តែលើ ផ្នែកទ្រឹស្តីមួយដោយផ្អែកជាសំខាន់តែទៅលើ វិធានច្បាប់ ដែលមានប៉ុណ្ណោះ ពីព្រោះថានៅក្នុងបរិបទនៃសង្គមខ្មែរសព្វថ្ងៃ រាល់ការអនុវត្តណាមួយតាមវិធាននេះ នៅមានកម្រិតនូវឡើយហើយថែមទាំងពិបាកស្វែងរកឲ្យដឹងទៀតផង។ ការណ៍នេះ គឺជាចំណុចខ្សោយមួយ នៃការសិក្សារបស់យើងលើប្រធានបទនេះ ។ ដូចនេះ ការសិក្សាលើប្រធានបទនេះ និងនាពេលនេះ អាចផ្តល់អត្ថប្រយោជន៍ឲ្យយើងបានត្រឹមតែជាការស្វែងយល់ផ្នែកទ្រឹស្តីមួយប៉ុណ្ណោះ។

ប៉ុន្តែងអត្ថប្រយោជន៍ដ៏តិចតួចនេះ ក៏នៅតែមានតម្លៃសម្រាប់យើងជានិច្ចពិសេសក្នុង ការស្វែងយល់នូវវិធានដែលជាអនាគតក្រមរដ្ឋប្បវេណីថ្មីរបស់យើង។ ជាលទ្ធផល ការសិក្សានេះ អាចឲ្យយើងកំណត់បាននូវភាពទន់ខ្សោយពីរយ៉ាងនៃវិធានថ្មីស្តីពីមតកសាសន៍របស់យើងនេះ ទាំងលើវិធាន ដែលគ្រប់គ្រងដល់ខ្លឹមសារនៃកិច្ចនោះផង និងដល់ទម្រង់នៃកិច្ចនោះផងដែរ។

ដោយសារតែជាវិធានខ្ចីពីបរទេសផង (នយោបាយនៃជំនួយ) វិធាននៃខ្លឹមសាររបស់ មតកសាសន៍ក៏បានខ្ចីច្រើនពីបរទេសផងដែរពិសេសពីប្រព័ន្ធច្បាប់កូនកាត់ របស់ជប៉ុនដែល ជាម្ចាស់ជំនួយផ្ទាល់ក្នុងការតាក់តែងក្រមនេះ។ ការខ្ចីនេះ ពិតជាបានបណ្តាលឲ្យវិធាននេះ មានការខុសប្លែកគ្នាមួយចំនួនអំពីវិធានដែលធ្លាប់តែអនុវត្តពីមុនមក ហើយដែលផ្អែកច្រើនលើប្រព័ន្ធច្បាប់អាណានិគមន៍បារាំងផង និងលើគោលការណ៍នៃប្រពៃណីទំនៀមទម្លាប់បុរាណ ខ្មែរយើងផង[118] ។ ម្យ៉ាងវិញទៀតការខ្ចីនេះសោតក៏បានឲ្យមានឡើងនូវសញ្ញាណថ្មីៗ មួយចំនួនសម្រាប់នីតិខ្មែរផងដែរ តួរយ៉ាងដូចជាតួនាទី នៃអ្នកតតិប្រតិបត្តិមតកសាសន៍ ដែលក្រមនេះបានប្រគល់ជាមួយនឹងអំណាចក្នុងការចាត់ចែងមតិកដ៏ទូលាយ ឲ្យដល់តតិជននៃមតិក[119] នៅក្នុងបរិបទនៃសង្គមខ្មែរដែលតែងតែមិនឲ្យ តម្លៃចំពោះការបើកកកាយរឿងគ្រួសារប្រាប់អ្នកដ៏ទៃ ពិសេសអំពីរឿងអាស្រូវដូចជារឿងមតិកនេះឯង។ ហេតុនេះ តើវិធានថ្មីនេះអាចនឹងមានជម្លោះគ្នាជាមួយប្រពៃណី ទំនៀមទំលាប់ខ្មែរ ឬទេ? ហើយអាចសម្របសម្រួល ជាមួយស្ថានភាពជាក់ស្តែងនៃ ក្នុងសង្គមខ្មែរបានឬទេ។ ចំពោះវិធានដែលគ្រប់គ្រងទម្រង់ នៃមតកសាសន៍

[118]សូមអានទៅក្រោយស្តីពី ៖ *" សេចក្តីផ្តើម "* ។

[119]សូមអានទៅក្រោយស្តីពី៖ *"ការបង្កើតសិទ្ធិចាត់ចែងទ្រព្យដល់អ្នកប្រតិបត្តិមតកសាសន៍"* ។

វិញ យើងសង្កេតឃើញភាគច្រើន គឺផ្តោតសារសំខាន់លើទម្រង់ជាលាយល័ក្ខណ៍អក្សរ និងលើការដើរតួនាទីរបស់មន្ត្រីសាការី។ចំណុចទាំងពីរនេះ សុទ្ធិសឹងតែ ជាកាលំបាកគោរពតាមណាស់ សម្រាប់ពលរដ្ឋខ្មែរភាគច្រើនដែលជាអនក្ខរជនផង និងក្រីក្រផង។ តើវិធាននេះ នឹងធានាឲ្យដល់ ពលរដ្ឋដែលមានធនធានច្រើនទេ ឬយ៉ាងណា? មួយវិញទៀត ប្រសិនបើកើតវិវាទ នៃការបែងចែកមត៌កនៅមុខតុលាការ តើត្រូវប្រកាសមោឃភាពចំពោះមតកសាសន៍ ដែលធ្វើឡើងដោយផ្ទាល់មាត់មុនពេលស្លាប់ ដោយផ្អែកតាមវិធានច្បាប់ ដោយពុំចាំបាច់ខ្វល់អំពីឆន្ទៈនៃមតកជននោះ ឬយ៉ាងណាកាល បើការផ្តែផ្តាំ ដោយមាត់អាចរាប់ថាជាទម្លាប់ខ្មែរមួយរួចទៅហើយនោះ ? ទាំងអស់នេះ សុទ្ធសឹងជាបញ្ហាចោទ នៃការអនុវត្តវិធាននៃមតកសាសន៍តាមក្រមថ្មី នៅក្នុងបរិបទខ្មែរ។

បញ្ហាទាំងនេះ ច្បាស់ណាស់ ពិតជាពុំអាចស្វែងរកឃើញចម្លើយនៅក្នុងការសិក្សារបស់យើង លើប្រធានបទនេះឡើយ។ ក្នុងន័យនេះ យើងអាចអះអាងបានថា ការសិក្សារបស់យើងនេះ នៅពុំទាន់ គ្រប់គ្រាន់សម្រាប់ការយល់ច្បាស់ និងគ្រប់ជ្រុងជ្រោយមួយនៃប្រធានបទ " មតកសាសន៍ "នេះនៅឡើយទេ ។ ដូចនេះហើយទាមទារឲ្យមាននូវការសិក្សាថ្មីមួយបន្ថែមទៀតដែលត្រូវផ្តោតវិសាលភាពសិក្សាទៅលើ គ្រប់ផ្នែកទាំងអស់នៃមតកសាសន៍នេះ ទើបចាត់ទុកជាការគ្រប់គ្រាន់។

# ឯកសារពិគ្រោះ និងយោង

# ឯកសារពិគ្រោះ និងយោង

## ១.វចនានុក្រម ៖


១.១. ពុទ្ធសាសនបណ្ឌិត *"វចនានុក្រមខ្មែរ"* (ភាគ១ និងភាគ២), ភ្នំពេញ, ឆ្នាំ ១៩៦៧។

១.២. *"សទ្ទានុក្រម បារាំង-ខ្មែរ នៃពាក្យច្បាប់"*, បោះពុម្ពដោយការឧបត្ថម្ភពី ផ្នែកសហប្រតិបត្តិការ សកម្មភាពវប្បធម៌របស់ស្ថានទូតបារាំង ភ្នំពេញ ឆ្នាំ២០០៥។

១.៣. ហ៊ានសុខុម...etc *សទ្ទានុក្រមបច្ចេកស័ព្ទ ទំនើប"*, ភ្នំពេញ បោះពុម្ពឆ្នាំ១៩៩៨។


## ២. អត្ថបទច្បាប់៖


២.១.ក្រុមប្រឹក្សាធម្មនុញ្ញ *"រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា"*, ភ្នំពេញ, ឆ្នាំ ២០១០

២.២. JICA *"ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧"* និង *"សេចក្តីកំណត់ពន្យល់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី"* ភ្នំពេញ ឆ្នាំ ២០១០។

២.៣. ក្រសួងយុត្តិធម៌ *"ច្បាប់ភូមិបាល"* ភ្នំពេញ ,ឆ្នាំ១៩៩២ និងឆ្នាំ២០០១។

២.៤.ក្រឹត្យច្បាប់លេខ៣៨ស្តីពី ៖ *"កិច្ចសន្យានិងការទទួលខុសត្រូវក្រៅកិច្ចសន្យា"* ភ្នំពេញ ឆ្នាំ១៩៨៨។

២.៥. អេង សុត *"ក្រមរដ្ឋប្បវេណីសង្គមចាស់"*, ភ្នំពេញ បោះពុម្ពឆ្នាំ១៩៦៧។


## ៣.ស្នាដៃជាសៀវភៅ ៖


៣.១. បោះពុម្ព និងផ្សព្វផ្សាយដោយ ផ្នែកសហប្រតិបត្តិការ និង សកម្មភាពវប្បធម៌ នៃស្ថានទូតបារាំងសៀវភៅ *" សេចក្តីផ្តើមទូទៅនៃនីតិកម្ពុជា "*, ភ្នំពេញ, ឆ្នាំ២០០២។

៣.២. Philippe MALAURIE មានចំណងជើងថា៖*<< Les successions, Les liberalites>>*, បោះពុម្ពដោយ Edition Defrenois, ឆ្នាំ២០០៤ (ទំព័រ ២៤៣ ដល់ ២៩១)។

៣.៣. Alain Seriauxមានចំណងជើងថា៖ *<< Manuel de droit des succession et des liberalites>>,* Press Universitaires de France, បោះពុម្ពលើកទី១, ឆ្នាំ២០០៣ (ទំព័រ ៦០ ដល់៨៦)។

៣.៤. Jean Maury មានចំណងជើងថា៖ *<< Successions et Liberalites>>,* បោះពុម្ពលើកទី៤ដោយ Edition Litec, ឆ្នាំ២០០៣ (ទំព័រ ១៦៧ ដល់ ១៧៦ )។

៣.៥. Jacques Flour, Jean-Luc Aubert, Eric Savaux មានចំណងជើងថា៖ *<< Les obligations/ 1.L'actejuridique>>,* បោះពុម្ពលើកទី៩ ដោយEdition Armand Colin, ឆ្នាំ២០០០។

៣.៦. Francois Terre, Philippe Simler, Yves Lequetteមានចំណងជើងថា៖ *<< Les obligations>>,* បោះពុម្ពលើកទី១០ ដោយEdition Dalloz, ឆ្នាំ២០០៩។

៣.៧. Stephanie Porchy-Simon មានចំណងជើងថា៖ *<< Les Obligations>> ,* បោះពុម្ពលើកទី៤ ដោយEdition Dalloz, ឆ្នាំ២០០៦។

៣.៨. Philippe MALAURIE, Laurent AYNES, Philippe STOFFEL-MUNCK មានចំណង ជើងថា៖ *<< Les obligations>>,* Edition Defrenois, ឆ្នាំ ២០០៣។

៣.៩.ណូមូរ៉ា តូយូហ៊ីរ៉ូ *"សេចក្តីផ្តើមនីតិរដ្ឋប្បវេណី"* បោះពុម្ពលើទី៥ ភ្នំពេញ ឆ្នាំ ២០១១។

៣.១០.JICA *" សេចក្តីពន្យល់អំពី ក្រមរដ្ឋប្បវេណីភាគ៦"* ភ្នំពេញ ឆ្នាំ ២០១២។

៣.១១ JICA សេចក្តីពន្យល់ ក្រមរដ្ឋប្បវេណី "សន្តតិកម្ម និង មតកសាសន៍ ឆ្នាំ ២០១៣

## ៤.គេហទំព័រតាមអ៊ីធឺណិត

៤.១.http://www.particulier.ag2rlamondiale.fr/pdf/AG2RLAMONDIALE-fiche-conseil-26.pdf

៤.២. http://www.edeneo.fr/system/documents/15/original/testament.pdf?1275912207

៤.៣. http://www.petra-kuhn.de/successions_erbrecht.pdf

៤.៤. http://www.notraires-preenpail.fr/images/pdf/Le%20testament.pdf

៤.៥. http://www.duprebedard.com/pdf/Le%20testament%20200803.pdf

៤.៦.http://www.patrimonia.biz/4%20Bonnes%20raisons%20de%20faire%20un%20testament.pdf

៤.៧. http://www.advantage4u.ca/fr/documents/ps/testament.pdf

# ឧបសម្ព័ន្ធ